01086734

E1/288.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ
# សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥**

**ម៉ោង ០៩:០៥នាទី**

**សវនាការលើកទី២៦៩**

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 23-May-2017, 11:42
CMS/CFO: Sann Rada

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម ធូ មណី

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ជា ស៊ីវហ៊ង

កញ្ញា រ៉ូប៊ីន្ទ ក្រហ្វត៍ *(Ms. Robynne CROFT)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ស្រ៊ា រតនៈ

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោក ឡៃ ជុនធី

លោកស្រី ស៊ីន សុវ៉ន

លោកស្រី ជេត វណ្ណលី

លោក ហុង គឹមសួន

លោកស្រី ទី ស្រ៊ីនណា

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ូច អរុណ

លោកស្រី ស្វ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក ស្រ៊ា រតនៈ | ខ្មែរ |
| លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល | បារាំង |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោកស្រី ជេត វណ្ណលី | ខ្មែរ |
| លោក ហុង គឹមសួន | ខ្មែរ |
| លោក ឡោ ជុនធី | ខ្មែរ |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក យន់ សាវ៉ាត់ | ខ្មែរ |
| លោកស្រី យ៉ែម ខុន្នី (2-TCCP-983) | ខ្មែរ |
| លោក ប៊ុន សារឿន (2-TCCP-293) | ខ្មែរ |
| លោកស្រី អ៊ឹម វណ្ណៈ (2-TCCP-256) | ខ្មែរ |
| លោកស្រី ឡិប នាង (2-TCCP-984) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី យ៉ែម ខុន្នី** (2-TCCP-983)

សួរដោយលោក ស្រ៊ា រតនៈ ផ្តើមពី.......................................................ទំព័រ ៣

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី.......................................................ទំព័រ ១០

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ម៉ុន សារឿន** (2-TCCP-293)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី.......................................................ទំព័រ ១៩

សួរដោយលោកស្រី ជេត វណ្ណលី ផ្តើមពី.......................................................ទំព័រ ២៣

សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល ផ្តើមពី.......................................................ទំព័រ ៣៤

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី.......................................................ទំព័រ ៣៧

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី អ៊ុំ វណ្ណា**: (2-TCCP-256)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី.......................................................ទំព័រ ៤៣

សួរដោយ ហុង គឹមសួន ផ្តើមពី.......................................................ទំព័រ ៤៤

សួរដោយលោក ស្រ៊ា រតនៈ ផ្តើមពី.......................................................ទំព័រ ៥៥

សួរដោយ លោក វ៉ិចទ័រ កូប៉េ ផ្តើមពី.......................................................ទំព័រ ៦១

សួរដោយ គង់ សំអុន ផ្តើមពី.......................................................ទំព័រ ៧២

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី ឡិប នាង** (2-TCCP-984)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី.......................................................ទំព័រ ៧៧

សួរដោយលោក ឡោ ជុនធី ផ្តើមពី.......................................................ទំព័រ ៧៨

សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល ផ្តើមពី.......................................................ទំព័រ ៨៣

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី.......................................................ទំព័រ ៨៥

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៥:០៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះបន្តស្តាប់នូវសេចក្តីរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី យ៉ែម ខុន្នី ហើយនិងដើមបណ្តឹងរដ្ឋប្បវេណីចំនួនបីរូបថែមទៀត។ ហើយនៅក្នុងកិច្ចដំណើរការសវនាការនេះ មុននឹងដំណើរការៗសវនាការ អង្គជំនុំជម្រះសូមជូនដំណឹងដល់ភាគីទាំងអស់នៃរឿងក្តីថា នៅក្នុងកិច្ចដំណើរការសវនាការនៅថ្ងៃនេះ ចៅក្រមលោក យូរ ឧត្តរា ដែលជាចៅក្រមជាតិអវត្តមានដោយមូលហេតុមានធុរៈផ្ទាល់ខ្លួន គាត់មិនអាចចូលរួមកិច្ចដំណើរការសវនាការនេះបាន។ បន្ទាប់ពីយើងខ្ញុំបានពិគ្រោះយោបល់ជាមួយនឹងបណ្តាចៅក្រមពេញសិទ្ធិនៃអង្គជំនុំជម្រះសាលាដំបូង យើងសម្រេចតែងតាំងចៅក្រម ធូ មណី ដែលជាចៅក្រមបម្រុងខាងភាគីជាតិជំនួសកន្លែងចៅក្រម យូរ ឧត្តរា ដែលបានអវត្តមាននៅថ្ងៃនេះ។ សេចក្តីសម្រេចនេះផ្អែកតាមបទប្បញ្ញត្តិនៃវិធាន៣៩(៤)នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

ក្រឡាបញ្ជីសវនាការ កញ្ញា ជា ស៊ីវហ័ង ឡើងរាយការណ៍អំពីស្ថានភាព វត្តមាន អវត្តមានភាគីនិងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

[០៩:០៧:០៤]

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ដើមបណ្តឹងដែលត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃនេះមានចំនួនបួនរូបគឺ ដើមបណ្តឹងរដ្ឋប្បវេណី យ៉ែម ខុន្នី និងដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-293, 2-TCCP-256 និង 2-TCCP-984។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណកញ្ញា ជា ស៊ីវហ័ង។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា ដោយមានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃមុខឲ្យមានប្រសិទ្ធភាព ខ្លួនសូមលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥។ មេធាវីការពារក្ដីរបស់ខ្លួនបានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះមិនអាចបកស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្ដីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការបង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

[០៩:០៨:៥០]

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ បានកត់សម្គាល់ថា ស្ថានភាពសុខភាពជនជាប់ចោទ នួន ជា ឈឺចង្កេះវុំារ៉ៃវិលមុខពេលអង្គុយ គាត់មិនអាចអង្គុយយូរបាន និងផ្ដល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។ ផ្អែកលើមូលដ្ឋាននេះ និងបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា នៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនា-ការនេះ ក្នុងរយៈពេលនៃកិច្ចដំណើរសវនាការសម្រាប់ថ្ងៃនេះ។

ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅសហព្រះរាជអាជ្ញា ដើម្បីមានឱកាសអាចសួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណី យ៉ែម ខុន្នី ពាក់ព័ន្ធជាមួយនឹងស្ថានភាពទុក្ខសោកវេទនា

និងព្យសនកម្មដែលកើតមានចំពោះគាត់ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

[០៩:១០:១៤]

**លោក ស្រ៊ា រតនៈ៖**

សូមគោរពលោកប្រធាន សូមគោរពអង្គសវនាការទាំងមូល។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ស្រ៊ា រតនៈ៖**

**ស៖** សូមជម្រាបសួរលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំបាទឈ្មោះ ស្រ៊ា រតនៈ ជាសហព្រះរាជអាជ្ញារងជាតិនៃ អ.វ.ត.ក។ តាមរយៈការរៀបរាប់របស់លោកស្រីជូនអង្គសវនាការពីម្សិលមិញ លោកស្រីបានរៀបរាប់ថា លោកស្រីឡើងមកពីក្រោម ហើយដោយសារម្តាយបបួលមក ហើយត្រូវបានគេបញ្ជូនទៅព្រៃតាខាប សហករណ៍សំរោង។ តើលោកស្រីឡើងមកពីក្រោមហ្នឹង សំដៅថាឡើងមកពីណា? ហើយនៅឆ្នាំដែរ?

[០៩:១១:០២]

**លោកស្រី យ៉ែម ខុន្នី៖**

**ឆ៖** ខ្ញុំអត់ចងចាំលោកគ្រូ ដែលខ្ញុំនៅវ័យក្មេងដែរ ហើយអត់ចេះអក្សរ ខ្ញុំមិនបានចាំ។ ខ្ញុំ ម៉ែឪខ្ញុំចេះតែបបួលឡើងមក ដល់ហើយខ្ញុំចេះតែឡើងតាមម៉ែមក នៅព្រៃខាបហ្នឹង។ ដល់ហើយ មកដល់ព្រៃខាបហ្នឹង បានប្រហែលរយៈប្រហែល១០ថ្ងៃ មានខោអាវមានអីហ្នឹង ស្រាប់តែគេប្រមូលដាក់ទៅសហករណ៍។ ដល់ខ្ញុំសួរទៅបងខ្ញុំ បងហ៊ុន ហ្នឹង ថាបងខោអាវយើងម៉េចបានគេយកទៅ ចាននាំងយើង។ ដល់ហើយ បងខ្ញុំថា គេយកទៅទុកឲ្យ ដល់គេថាយកទុកឲ្យ គេឲ្យយើងទៅធ្វើការសិន។ ដល់ហើយ ខ្ញុំក៏ឃើញគេយកខោអាវខ្មៅហ្នឹងយកមកឲ្យពាក់ ខ្ញុំថាបងម៉េចពាក់ខោអាវខ្មៅអ៊ីចឹង។ ដល់ហើយ គាត់ថាចេះតែពាក់ទៅ។ ដល់គេឲ្យពាក់ម៉េចពាក់ទៅ។ ដល់ហើយបាន ពូឆន ហ្នឹងគាត់ថា មកខ្មែរក្រហមហ្នឹងគេពាក់តែអាវក្រហម -- ខ្មៅហ្នឹង គេមិនឲ្យពាក់អាវក្រឡេក្រឡាទេ។ ខ្ញុំហ្នឹងក៏ស្តាប់គាត់ ពាក់ទៅអ៊ីចឹង។ ដល់តែពាក់យូរៗទៅ គ្មានស្អីស្រាប់តែកើតចៃកើតអី។ ខ្ញុំហ្នឹងក៏រមាស់អើយរមាស់។ ដល់ហើយ ខ្ញុំថាបងអើយអាវហ្នឹងអីរមាស់មាំម្ល៉េះ។ ដល់ខ្ញុំដោះមើល ម៉ែអើយ! កើតចៃប៉ុនៗអី ដូចចៃឆ្កែ។ ហើយដល់ហើយវាត្រូវសើម ត្រូវអីហ្នឹង មិនបានស្អីផ្លាស់ ចុះតែមួយកំផ្លេហ្នឹង មួយកំផ្លេ ព្រោះទើបតែបើកឲ្យមួយកំផ្លេ។ ដល់ហើយ ខ្ញុំ បងប្អូនខ្ញុំហ្នឹងថា ម៉ែអើយម៉ែ បន្ទោសម៉ែ ដឹងម៉េចបាន ឮតែគេថាហូបបរិបូរ ហូប

ស្រាប់ ឆ្ងាញ់។ ស្រាប់តែមកតាមគេ ម៉ែឯងថាអ៊ីចឹងនេះ។ ដល់ហើយ ម៉ែខ្ញុំហ្នឹង គាត់ថាកូនអើយទ្រាំទៅ ម៉ែមិនដឹង។ ធ្វើម៉េច ឥឡូវយើងមកហួសហើយ ទៅក៏មិនដឹងទៅផ្លូវណា អីក៏មិនដឹងទៅផ្លូវណា មកស្រុកគេ ថាអ៊ីចឹង។

[០៩:១២:៥០]

**ស៖** សូមអរគុណ។ សូមលោកស្រីជួយបញ្ជាក់បន្ថែមថា នៅកាលនោះ លោកស្រី និងក្រុមគ្រួសារឡើងមកដោយការស្ម័គ្រចិត្ត ឬក៏ដោយសារមានអ្នកណា មានការរៀបចំពីអ្នកណា?

**ឆ៖** អត់មានអ្នកណាបង្ខំទេ ឡើងមក ឮគេនិយាយតែម្ដងថាទៅស្រុកលើ ទៅៗ ហើយសម្បូរហូបណាស់ ហើយគេធ្វើហូបស្រាប់ ទៅៗមិនចេះខ្វះអីហូបទេ។ ដល់តែមក ប្រែតែមកទៅ ស្រាប់តែគ្មានបបរពោត បបរដំឡូង បបរគុលចេក ស្លរត្រកួនហ្នឹងក៏គ្មានស្អី។ ចេះតែបបួលហូបហើយ។

**ស៖** នៅក្នុងសហករណ៍ព្រៃតាខាបនោះ តើលោកស្រីត្រូវបានគេដាក់ឲ្យនៅជួបជុំគ្នាជាមួយនឹងប្រជាពលរដ្ឋទូទៅ ឬក៏មានការបែងចែក? នៅត្រង់ចំណុចត្រង់នេះ តាមរយៈការសង្កេតរបស់ខ្ញុំ គឺតាមស្ដាប់សំនៀងរបស់លោកស្រី គឺមានសំនៀងបែបជាខ្មែរកម្ពុជាក្រោម។ អ៊ីចឹង តើនៅព្រៃតាខាបហ្នឹងមានការបែងចែករវាងដាក់ដាច់ពីគ្នារវាងខ្មែរកម្ពុជាក្រោម និងប្រជាជននៅខាងលើដែរឬទេ?

**ឆ៖** នៅលើជាមួយគ្នា ដល់យូរទៅបានគេឲ្យនៅម្ដុំៗ។ ដល់ហើយខ្ញុំហ្នឹង គេបំបែកទៅជាកុមារទៅ។ ទៅគេចែកបង្គី ចែកអី ចែកដងរែក ចែកអីអ៊ីចឹង បបួលគ្នាទៅរើសអាចម៍គោ។ អស់អារើសអស់អាចម៍គោហ្នឹងហើយ ទៅកាប់ទន្រ្ទានខែត្រ។ កាប់ទន្រ្ទានខែត្រហើយ ដល់ហើយអត់អាទន្រ្ទានខែត្រចិញ្ច្រាំហ្នឹងហើយអីហើយ គេឲ្យទៅរែកទៅចាក់ ចាក់ហ្នឹងគេមិនឲ្យនេះ គេបាចអាហ្នឹងទន្រ្ទានខែត្រគេមិនឲ្យចាក់ដុំជាដុំដូចដីដំបូកទេ។ គេឲ្យបាចៗឲ្យរាយ ស្រណុកឲ្យពូៗភ្ជួរ។

**ស៖** ពាក់ព័ន្ធនឹង--

[០៩:១៥:០៥]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម។ នៅពេលដែលមេធាវីជាតិបានកត់សម្គាល់នៅក្នុងការតាំងសំណួររបស់គាត់<ថាជនរងគ្រោះ--ដើមបណ្ដឹងរដ្ឋប្បវេណីមានសំនៀង

ជាខ្មែរកម្ពុជាក្រោម ខ្ញុំមិនអាចបញ្ជាក់ដោយខ្លួនឯងបានខ្ញុំងាកទៅក្រោយដើម្បីទទួលយោបល់ គឺឃើញថាដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ>មិនមានសំឡេងជាខ្មែរក្រោមនោះទេ។ <សម្រាប់ប្រតិចារិក ខ្ញុំសូមជំទាស់ក្នុងការចាត់ថាគាត់ជាខ្មែរក្រោមតាមរយៈសំនៀងភាសាដែលគាត់និយាយ>។

**លោក ស្រ៊ា រតនះ៖**

ខ្ញុំសូមឆ្លើយតបលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី គង់ សំអុន។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមកត់សម្គាល់បន្ថែមមួយទៀតទាក់ទងទៅនឹងសំណួរចុងក្រោយរបស់សហព្រះរាជអាជ្ញារងជាតិ ដែលទំនងជាបកស្រាយទៅលើអង្គហេតុច្រើន ហើយដែលបញ្ហានេះកាលពីម្សិលមិញ លោកប្រធានបានហាមឃាត់ខ្ញុំមិនឱ្យតាំងសំណួរបែបនេះទេ។ ដូច្នេះ បើសិនជាតំណាងសហព្រះរាជអាជ្ញាជាតិតាំងសំណួរបែបនេះ វាអាចធ្វើឱ្យខាងមេធាវីការពារក៏ត្រូវតែលើកនូវសំណួរបែបនោះដែរ ដើម្បីឆ្លើយតបទៅបញ្ហានេះផងដែរ។ ដូច្នេះខ្ញុំសូមឱ្យលោកប្រធាន មេត្តាពិនិត្យថាតើការតាំងសំណួរបែបនេះអាចអនុញ្ញាតឬមួយយ៉ាងណា? សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

[០៩:១៦:៥៣]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមាន<មតិយោបល់>មួយ។ មិនមានដើមបណ្តឹងរដ្ឋប្បវេណីដែល<បានមកផ្តល់សក្ខីកម្ម>កាលពីម្សិលមិញ <និង>នៅថ្ងៃនេះ<ប្រាប់ថាខ្លួនទទួលរងការឈឺចាប់ខ្លោចផ្សាដោយសារគេ>មកពី<>កម្ពុជាក្រោមទេ។ <ដូច្នេះប្រសិន>បើ<>ជាយើងគិតថា<វិសាលភាពនៃ>សំណួរ<>ពាក់ព័ន្ធទៅនឹងការឈឺចាប់<ខ្លោចផ្សានោះ សំណួរសម្រាប់អង្គហេតុត្រូវតែផ្តោតលើ>ព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះ<។ រីឯសំនៀងរបស់ដើមបណ្តឹងរដ្ឋប្បវេណីវិញនោះគឺថាពុំមាននរណាម្នាក់>មកពីកម្ពុជាក្រោម<>បញ្ជាក់ថា គាត់<ទទួលបានការ>ឈឺចាប់ដោយសារតែគេរើសអើងថា គាត់ជាកម្ពុជាក្រោមទេ។ ខ្ញុំចង់ធ្វើការកត់សម្គាល់នេះ ពីព្រោះថា<>យើងស្នើឱ្យគាត់

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មក<ថ្លែង>ពីការឈឺចាប់<ខ្លោចផ្សារបស់គាត់ដែលកើតឡើង>នៅត្រាំកក់។ ហើយយើងអាចស្តាប់សក្ខីកម្មរបស់ពួកគាត់ ហើយគ្មានអ្នកណាម្នាក់បានអះអាងថាខ្លួនឈឺចាប់ដោយសារតែខ្លួនជាកម្ពុជាក្រោមនោះទេ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហព្រះរាជអាជ្ញារងជាតិ។

[០៩:១៧:៥៤]

**លោក ស្រ៊ា រតនៈ៖**

ខ្ញុំបាទសូមឆ្លើយតបទៅនឹងការចាប់អារម្មណ៍ ការកត់សម្គាល់របស់លោកមេធាវី កូប៉េ ដែលគាត់លើកឡើងថា ខ្ញុំធ្វើការវាយតម្លៃ ហើយគាត់សន្និដ្ឋានថាសំនៀងនេះ មិនមែនជាសំនៀងរបស់ខ្មែរកម្ពុជាក្រោម។ ទី១ ខ្ញុំបាទលើកឡើងតាំងពីខាងដើម គឺមិនមែនខ្ញុំបាទឈរតែលើមូលដ្ឋានស្តាប់សំនៀងនេះទេគឺ តាមរយៈចម្លើយការរៀបរាប់របស់គាត់តាំងពីម្សិលមិញថា គាត់ឡើងមកពីក្រោមហើយគាត់មានស្រុកកំណើតនៅកម្ពុជាក្រោម។ គាត់បានបញ្ជាក់ច្បាស់ណាស់ម្សិលមិញ។ អ៊ីចឹងឈរលើមូលដ្ឋាននេះ ហើយបន្ថែមលើសំនៀងរបស់គាត់ ដែលគាត់ធ្លាប់រស់នៅកម្ពុជាក្រោម។ ហើយការស្តាប់សំនៀងនេះមិនមែនជាមូលដ្ឋានតែមួយទេ។ ហើយខ្ញុំមានការចម្លែកដែរ ដែលលោក កូប៉េ គាត់ចេះស្តាប់សំនៀងថាមិនមែនកម្ពុជាក្រោម ឬកម្ពុជាលើ ខ្ញុំមានការចម្លែកដែរ ប្លែកអារម្មណ៍ដែរ។ ហើយខ្ញុំទទួលស្គាល់ថាគាត់និយាយឥឡូវនេះមានជាប់សំនៀងរដឺនតិចតួចបំផុតពាក់ព័ន្ធនឹងកម្ពុជាក្រោមនេះ។ ហើយម្យ៉ាងវិញទៀត ចំពោះការសម្រេចលើការសាកសួរអំពីអង្គហេតុនេះ គឺជាការសម្រេចរបស់ក្រុមប្រឹក្សា។ ប៉ុន្តែខ្ញុំយល់ថា សំណួរនេះគឺមិនចាកឆ្ងាយអំពីទុក្ខសោកវេទនាដែលគាត់ទទួលបាននូវសហករណ៍ត្រាំកក់នោះទេ។

[០៩:១៩:១៥]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:២២:៣៣]

**ប្រធានអង្គជំនុំ៖**

បាទ ហើយបញ្ហាដែលលើកឡើងនេះ រឿងពាក់ព័ន្ធជាមួយនឹងការប្រើប្រាស់នូវយល់ដឹងនូវអត្ត-នោម័តិនៅក្នុងការកត់សម្គាល់អំពីភាពរដឺននៃការនិយាយស្តីរបស់ដើមបណ្តឹងរដ្ឋប្បវេណី កំណត់គោល

ដៅថាជាកម្ពុជាក្រោម ឬអត់នោះ គឺជាការមិនសមស្របទេ។ ដូច្នេះ ភាគីពាក់ព័ន្ធផ្សេងទៀត គឺលើកក្រោយមិនបាច់ មិនគប្បីលើកឡើងបញ្ហានោះទៀតទេ ហើយបញ្ហាសេចក្ដីជំទាស់របស់មេធាវីការពារក្ដីលោក ខៀវ សំផន មេធាវីជាតិ អង្គជំនុំជម្រះសូមជម្រាបថា កាលពីម្សិលមិញ អង្គជំនុំជម្រះបានសួរលោកអំពីឲ្យបង្ហាញអំពីស្ថានភាពនៃភាពពាក់ព័ន្ធ ដែលលោកលើកអំពីអង្គហេតុធ្វើទុក្ខបុកម្នេញពីរឿងជនជាតិចិន ដោយអង្គជំនុំជម្រះយល់ឃើញថា នៅក្នុងរឿងក្ដីនេះមិនបាន មិនមែនជាអង្គហេតុដែលត្រូវធ្វើការចោទប្រកាន់នៅក្នុងសំណុំរឿង០០២/០២ ជាពិសេសនៅក្នុងសហករណ៍ត្រាំកក់ ហើយនិងក្រាំងតាចាន់នុ៎ងមិនមានអង្គហេតុនុ៎ងទេ។ អ៊ីចឹងអង្គជំនុំជម្រះយល់ថា វាមិនពាក់ព័ន្ធជាមួយនឹងអង្គហេតុដែលអង្គជំនុំជម្រះកំណត់ធ្វើសវនាការនេះឡើយ។

[០៩:២៤:០៣]

ហើយបញ្ហាពាក់ព័ន្ធជាមួយនឹងព័ត៌មានផ្សេងទៀត ដែលដើមបណ្ដឹងរដ្ឋប្បវេណីបានដឹង យើងបានកំណត់រួមរួចហើយ គឺឲ្យតែនៅក្នុងវិសាលភាពនៃអង្គហេតុដែលចោទប្រកាន់ គឺអាចសាកសួរបានគ្រាន់តែអង្គជំនុំជម្រះរំឭកភាគីពាក់ព័ន្ធថា ឲ្យផ្ដោតយកចិត្តទុកដាក់ទៅលើស្ថានភាពនៃទុក្ខសោកវេទនានិងព្យសនកម្មដែលដើមបណ្ដឹងរដ្ឋប្បវេណីបានថ្លែងរៀបរាប់តាមរយៈការសួរដេញដោលរបស់ -- តាំងសំណួរសាកសួររបស់មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងឯកសារដែលគាត់បានដាក់មកហ្នឹងជាមូលដ្ឋាននៅក្នុងការតាំងសំណួរ។ និយាយរួម គឺជាសារវន្តនៅក្នុងការតាំងសំណួរពាក់ព័ន្ធនឹងបញ្ហាស្ថានភាពព្យសនកម្ម ហើយនិងស្ថានភាពទុក្ខសោកវេទនារបស់ដើមបណ្ដឹងរដ្ឋប្បវេណី។ អង្គជំនុំជម្រះមិនហាមទេ ព្រោះអង្គជំនុំជម្រះបានជម្រាបជូននៅក្នុងលិខិតផ្លូវការរួចហើយៗការអនុវត្តរបស់អង្គជំនុំជម្រះកន្លងមកក៏អនុវត្តដូច្នោះដែរ។ គ្រាន់តែឲ្យមានការផ្ដោតយកចិត្តទុកដាក់ខ្លាំងជាសារវន្តទីលើ -- ព្រោះយើងបានកំណត់ថា ដំណើរការសវនាការនេះគឺស្ដាប់សេចក្ដីថ្លែងទុក្ខសោកវេទនារបស់ -- និងស្ថានភាពព្យសនកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។ ដូច្នេះ សេចក្ដីជំទាស់ដែលលោកមេធាវីជាតិការពារក្ដីលោក ខៀវ សំផន ចំពោះសំណួរចុងក្រោយនេះ គឺអង្គជំនុំជម្រះបដិសេធ។ លោកមេធាវីអាចតាំងសំណួរបានលើបន្តទៀត។ សូមអញ្ជើញ!

កុំអាលសិនលោកសហព្រះរាជអាជ្ញារងជាតិ។ សូមអញ្ជើញលោក គង់ សំអុន!

[០៩:២៥:៥៥]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមអនុញ្ញាតលោកប្រធានបញ្ជាក់ទៅលើចំណុចមួយទៀត ពីព្រោះកាលពីម្សិលមិញនេះ សាក្សីបានលើកអំពីការបែងចែកប្រជាជននោះ មិនមែនមានន័យថាតែ ចិន ទេ គឺមានជនជាតិយួន ហើយនិងសាក្សីខ្លួនឯងផ្ទាល់។ ដូច្នេះនៅក្នុងនោះ វាមានទាំងចិន ទាំងយួន។ អ៊ីចឹងសូមលោកប្រធានបញ្ជាក់ផង។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ទាំងចិន ទាំងយួនហ្នឹង ដូចជានៅក្នុងសំណុំរឿងនេះ មិនមែនជាគោលដៅនៃការធ្វើការបែងចែកសញ្ជាតិនោះទេ។ ដូចមិនមានទេ។ ហើយអង្គហេតុនោះ វានៅឆ្ងាយពីអង្គហេតុដែលយើងកំណត់សម្រាប់ធ្វើសវនាការ។ អ៊ីចឹងហើយបានជាយើងឲ្យលោកពិចារណាថា តើវាពាក់ព័ន្ធយ៉ាងម៉េច ព្រោះលោក -- យើងចង់សួរលោក តើលោកពន្យល់យើង ដើម្បីឲ្យយើងមានមូលដ្ឋានសម្រេច ហើយលោកអត់ពន្យល់ ហើយលោកឈប់សួរតែម្តង។

អញ្ជើញសហព្រះរាជអាជ្ញារងជាតិ!

**សួរដោយលោក ស្រ៊ា រតនៈ៖**

**ស៖** ពាក់ព័ន្ធនឹងរបបអាហារដែលលោកស្រីបានលើកឡើងកាលពីម្សិលមិញ លោកស្រីថាបានទទួលនូវរបបរព្រលីត ប៉ុន្តែនៅពេលដែលគេសួរ ឆ្លើយថា "ឆ្ងាញ់" តើពេលហ្នឹងហេតុអីបានលោកស្រីឆ្លើយថាអ៊ីចឹង?

[០៩:២៧:៣៩]

**លោកស្រី យ៉ែម ខុន្នី៖**

**ឆ៖** បើមិនឆ្លើយអ៊ីចឹងទេ ធ្វើបាបធ្វើទោសទុក្ខ ដល់ហើយហ្នឹងចេះតែឆ្លើយទៅឲ្យតែហួបឲ្យរួចខ្លួន ឲ្យរស់តែមួយគ្រាៗទៅ។ គ្រាន់តែៗឆ្លើយមិននេះហ្នឹងក៏យកទៅកសាងដែរ។ ថាហួបមិនឆ្អែតហ្នឹងក៏យកទៅកសាងដែរ។ យកកុមារហ្នឹងទៅកសាងថា ថ្ងៃមុខថ្ងៃក្រោយកុំនិយាយអ៊ីចឹង។ គេឲ្យហួបឲ្យឆ្អែតៗហើយ បើគ្នាថាបើគ្នាមិនឆ្អែតអង្គុយវង់តុជាមួយខ្ញុំហ្នឹង គ្រាន់តែថាគ្នាមិនឆ្អែត ហៅគ្នាយកទៅកសាងភ្លាម។ ហើយបានតែឃើញអ៊ីចឹង បានពួកខ្ញុំហ្នឹងឆ្លើយថាឆ្ងាញ់ ថាឆ្អែតអ៊ីចឹងទៅ។ កុំឲ្យគេយកទៅកសាង ហើយបើយកទៅកសាងក៏ពិបាកដែរ នៅផ្ទញ់ផ្ទាលនៅហ្នឹង។ ចង់អ៊ីចេះចង់អ៊ីចុះ។ ហើយដល់ហើយពួកខ្ញុំហ្នឹងក៏មានសេចក្តីថា គេមកសួរអ៊ីចឹងថា ឆ្ងាញ់ទេ? ដល់ឆ្លើយថា ឆ្ងាញ់ ប៉ុន្តែមិនឆ្ងាញ់ទេ ម៉ែឪអាណាដែលហួបគល់ចេក ដែលហួបគល់ល្ហុង ដែលហួបដំឡូង ដែលហួបពោតអាក្រហមហ្នឹង

ស្ងោរហើយដាក់ចានជងអីឲ្យហូប។ អត់បាយ ជួនណានេះហូបដំឡូងស្ងោរទទេ អត់បាយ។ ខ្ញុំនិយាយតែការពិត ខ្ញុំមិនចេះបំផ្លើសបំផ្លើន បើខ្ញុំមិនចេះអក្សរ ហើយបើខ្ញុំមិននិយាយការពិតអ៊ីចឹងទេ ក៏អស់លោកមិនជឿខ្ញុំដែរ។

[០៩:២៩:០០]

**ស៖** តើលោកស្រីដែលថាកសាងហ្នឹង លោកស្រីចង់សំដៅលើអីដែរ?

**ឆ៖** កសាងហ្នឹង គេយកទៅស្ដីយើងហ្នឹងណ៎ា ហើយគេដាក់ទារុណកម្មឲ្យរែកដីអ៊ីចឹងទៀតទៅថែម ដូចថាមួយថ្ងៃហ្នឹង២០អម្រែកអ៊ីចឹង គេដាក់លើសទៅជាជាង២០ហ្នឹងទៅ។ បានពួកខ្ញុំហ្នឹងខ្លាចធ្វើអ៊ីចឹង ធ្វើវាមិនទាន់។ បើជើងអីរ៉ិនស្គមដូចឆ្អឹងនៅតែឆ្អឹង គ្មានស្អី ថាស្គមគ្រាន់តែដើរទាក់ស្មៅក៏ដួលដែរ។ ដល់តែយើងដួលទៅ ថាយើងនេះពុត ដល់យើងឈឺ ថាយើងនេះពុត ធ្វើស្អីមិនកើត។ ហើយពុតស្អី បើគ្មានជីវជាតិឲ្យឆ្ងាញ់ ឲ្យនេះផង។ ស្គមឡើងជង្គង់អីរ៉ិនមួយជង្គង់ដូចជង្គង់កុក លើសជង្គង់កុកផង អាហ្នឹងជង្គង់មនុស្ស។

**ស៖** នៅតាមរយៈការផ្ដល់ចម្លើយម្សិលមិញនេះ លោកស្រីបានបញ្ជាក់តែអំពីម្ដាយ តែអំពីមីង ប៉ុន្តែខ្ញុំបាទអត់បានស្ដាប់បានឮថាឪពុកលោកស្រីមានអ្វីកើតឡើងចំពោះគាត់សោះ។ តើគាត់មកជាមួយនឹងក្រុមគ្រួសារលោកស្រីទាំងអស់ ឬមួយក៏គាត់ក៏ត្រូវបាន -- គាត់ស្លាប់តាំងពីមុនរបបហ្នឹង?

**ឆ៖** ឪខ្ញុំស្លាប់មុន នៅតែម៉ែហ្នឹងមេម៉ាយ ដល់ទៅឃើញគេឡើងមកប្រើបអ៊ីចឹង បានគាត់នាំកូនចៅហ្នឹងឡើងមក គាត់ស្លាប់យូរហើយ។

**លោក ស្រ៊ា រតនៈ៖**

ខ្ញុំបាទអស់សំណួរហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ បន្តទៅនេះអង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក នួន ជា។ សូមអញ្ជើញ។

[០៩:៣១:១០]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណ លោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជម្រាបសួរលោកដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំមានសំណួរមួយចំនួន ហើយសំណួរខ្លះគឺសូមសួរដើម្បីបញ្ជាក់ឡើងវិញ។ បើខ្ញុំយល់មិនច្រឡំទេ លោកស្រីបាននិយាយថា លោកស្រីរស់នៅឯកម្ពុជាក្រោមក្នុងអំឡុងឆ្នាំ១៩៧៥ ប៉ុន្តែនៅក្នុងឯកសារដែលយើងបានទទួលមក គឺមើលទៅហាក់បីដូចជាថាលោកស្រីរស់នៅជាមួយឪពុកម្ដាយរបស់លោកស្រីនៅភ្នំពេញជាមួយឪពុកម្ដាយរបស់លោកស្រីក្នុងឆ្នាំ១៩៧៥ ហើយក៏ត្រូវបានជម្លៀសទៅខេត្តតាកែវ។ សូមលោកស្រីជួយបញ្ជាក់ចំណុចនេះបន្តិចបានទេ?

**លោកស្រី យែម ខុន្នី៖**

**ឆ៖** ខ្ញុំអត់បាននិយាយអ៊ីចឹងផង ខ្ញុំនិយាយពីមុនមក ពីដើមមក ខ្ញុំថាខ្ញុំមកពីកម្ពុជាក្រោមហ្នឹងតែម្ដង។ ខ្ញុំមិនដែលបានឪម៉ែខ្ញុំមកនៅភ្នំពេញផង ខ្ញុំនៅឯណាឯណោះ។ ខ្ញុំមិនដឹងភ្នំពេញម៉េចទេ ទើបតែស្គាល់ភ្នំពេញឥឡូវហ្នឹងទេ។ ខ្ញុំមិនដែលស្គាល់តែសោះភ្នំពេញ ទើបតែស្គាល់ឥឡូវហ្នឹងទេ។ បានសុខសប្បាយទៅ ខ្ញុំបាននៅស្គាល់ ពីដើមមកខ្ញុំមិនដែលស្គាល់ ត្រឹមតាកែវហ្នឹង ខ្ញុំមិនដែលស្គាល់ផង។ ទន្ទាប់ខ្ញុំមិនដែលស្គាល់ផង ទើបមកស្គាល់ឥឡូវហ្នឹង ហើយឲ្យខ្ញុំឆ្លើយថានៅពីតាកែវជម្លៀសទៅនៅតាកែវអីខ្ញុំមិនបាននិយាយទេ។

[០៩:៣២:៤៩]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធានឯកសារ <D22/3204A> សូមការអនុញ្ញាត។

**ចៅក្រម គ្លូឌា ហ្វេនស៍៖**

សូមៗលោកបង្ហាញឯកសារម្ដងទៀត។

**លោក វ៉ិចទ័រ កូប៉េ៖**

គឺឯកសារ <D22/3204A> ជាទម្រង់ព័ត៌មានបន្ថែម។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងទម្រង់ព័ត៌មានបន្ថែមនេះ គឺមាននិយាយដូចតទៅ៖ “នៅថ្ងៃទី១៧ <ខែមេសា ឆ្នាំ១៩៧៥> ឪពុកម្ដាយរបស់ខ្ញុំដែលជាអតីត<ទាហាន លន់ នល់>ត្រូវបានជម្លៀសដោយទាហានខ្មែរក្រហមចេញពីទីក្រុងភ្នំពេញទៅភ្នំដិន ខេត្តតាកែវ”។ ហើយភ្ជាប់ទៅនឹងទម្រង់ព័ត៌មានបន្ថែមនេះ គឺមានអត្តសញ្ញាណប័ណ្ណជាមួយឈ្មោះលោកស្រី និងមានស្នាមមេដៃផង។

ដូច្នេះខ្ញុំព្យាយាមចង់ដឹងស្វែងយល់ថាលោកស្រី ឬក៏ឪពុកម្ដាយលោកស្រីហ្នឹងរស់នៅឯណាដែរ ក្នុងឆ្នាំ ១៩៧៥?

**លោកស្រី យ៉ែម ខុន្នី៖**

**ឆ៖** ឪពុកម្ដាយខ្ញុំនៅតែងស្រុកក្រោមហ្នឹង។ គ្មានធ្វើអី ដល់គាត់ស្លាប់ទៅ ម៉ែខ្ញុំហ្នឹងគាត់ថាខ្ញុំនិយាយម៉េចអ៊ីចឹង ម៉ែខ្ញុំហ្នឹងគាត់មេម៉ាយ ហើយគាត់បបួលខ្ញុំមក ខ្ញុំមិនដែលដឹងភ្នំពេញហ្នឹងម៉េច មិនដែលដឹងឯណាម៉េច។ ដល់ទៅសួរខ្ញុំអ៊ីចឹងមិនដឹងឆ្លើយថាម៉េច បើខ្ញុំមិនដែលនៅ ឲ្យខ្ញុំឆ្លើយថាម៉េចទៅ? បើខ្ញុំធ្លាប់នៅកន្លែងខ្ញុំឡើងមកនៅហ្នឹង ខ្ញុំចេះតែដឹងទៅ បើមកសួរអ៊ីចឹង បើខ្ញុំមិនដឹង ខ្ញុំមិនដឹងឲ្យខ្ញុំឆ្លើយថាម៉េច ខ្ញុំក៏ចប់ដែរ ដល់អ៊ីចឹង។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតពីអង្គជំនុំជម្រះដើម្បីបង្ហាញឯកសារ <D22/3204A> ជាភាសាខ្មែរ ដើម្បីសួរដើមបណ្ដឹងរដ្ឋប្បវេណីថា នេះជាអត្តសញ្ញាណប័ណ្ណ <ហត្ថលេខា និង>ស្នាមដៃនេះជា<>របស់គាត់ដែរ ឬក៏អត់?

[០៩:៣៥:៣៥]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៣៥:៥៧]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<មុននឹងអនុញ្ញាត ខ្ញុំសុំសួរសិន បើតាមខ្ញុំដឹងថាលោកស្រីមិនចេះអក្សរទេ> តើត្រឹមត្រូវទេ<>? <លោកស្រីមិនចេះអាន ឬសរសេរទេ។> លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំសួរទៅលោកស្រីថា លោកស្រីចេះអាន ចេះអក្សរដែរឬទេ?

**លោកស្រី យ៉ែម ខុន្នី៖**

អត់ចេះអាន ខ្ញុំមិនចេះអក្សរ ខ្ញុំមិនចេះអីទាំងអស់។ បើអង្គាល់គេចុះទៅសួរចម្លើយ គេថាមានឪពុកម្ដាយស្លាប់ទេ? ខ្ញុំគ្រាន់គេសួរសំណួរអ៊ីចឹង ខ្ញុំថាពូឯងកត់ឲ្យខ្ញុំមួយមក។ ឪពុកម្ដាយ -- ម្ដាយខ្ញុំហើយនិងយាយខ្ញុំពោះមួយខ្ញុំ បាត់បង់ជីវិតនៅ ប៉ុល ពត ហ្នឹង។ ឥឡូវ --

**ប្រធានអង្គជំនុំ៖**

បានហើយ ហើយមិនសួរអ៊ីចឹងទេ។

**ចៅក្រម គ្លូឌា ហ្វេនស៍៖**

សំណួរទី២ លោកស្រីៗចេះសរសេរឈ្មោះខ្លួនឯងទេ? ឬក៏មិនចេះ<សរសេរ>ឈ្មោះ<មានន័យថា>នៅពេលចុះហត្ថលេខា<>ខ្លួនឯងបានទេ?

**ឆ៖** អត់ចេះ។

**ប្រធានអង្គជំនុំ៖**

ម៉េចទៅ វ៉ិចទ័រ។ លោក វ៉ិចទ័រ កូប៉េ តើមានប្រយោជន៍អ្វីដែរទេ ក្នុងការបង្ហាញឯកសារនោះចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីដែលគាត់អត់ចេះអក្សរ អត់ចេះអីទាំងអស់អ៊ីចឹង?

[០៩:៣៧:៤៤]

**លោក វ៉ិចទ័រ កូប៉េ៖**

នេះជាសំណួរមួយដែលល្អណាស់ លោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី លោកស្រីមានចាំ លោកស្រីបានផ្តិតមេដៃនៅលើនេះក្រដាសនេះ<ដែលជា>ទម្រង់ព័ត៌មានបន្ថែម<នូវព័ត៌មានដែលខ្ញុំទើបតែលើកមកមុននេះដែរឬទេ? តើ>លោកស្រីចាំទេ<ថាបានផ្តិតមេដៃ និងឲ្យអត្តសញ្ញាណប័ណ្ណទៅមនុស្សម្នាក់>ទេ?

**លោកស្រី យ៉ែម ខុន្នី៖**

**ឆ៖** អត្តសញ្ញាណប័ណ្ណ ខ្ញុំបានផ្តិត។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ឯកសារដែលសុំបង្ហាញដើមបណ្តឹងរដ្ឋប្បវេណី គឺទំព័រទី២នៃឯកសារ <D22/3204A>។ ខ្ញុំកំពុងលើកទៅបង្ហាញជូនអង្គជំនុំជម្រះ <>គឺមានអត្តសញ្ញាណប័ណ្ណ<របស់គាត់ដោយមានស្នាមមេដៃនៅ>ខាងក្រោយដែរ<។ ខ្ញុំគិតថាគាត់អាច>បញ្ជាក់អត្តសញ្ញាណរបស់គាត់<បាន>។

[០៩:៣៩:២១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថា មេធាវីការពារក្តីធ្វើឲ្យមានការភាន់ច្រឡំហើយ នៅពេល

នេះ។ តាមពិតទៅ ឯកសារអត្តសញ្ញាណប័ណ្ណហ្នឹង មិនមែនភ្ជាប់ទៅនឹងឯកសារ <D22/3204A> ទេ។ គឺនៅក្នុងឯកសារដើម គឺនៅក្នុងទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ គឺឯកសារ D22/3204 ទេ។ អ៊ីចឹងគឺថាឯកសារ<ទាំងពីរ>ហ្នឹង<មានកាលវេលា>ផ្សេងគ្នា។ អ៊ីចឹងខ្ញុំគិតថា វាជាការចាំបាច់ក្នុងការសួរថាតើមានពេលវេលាពីរផ្សេងគ្នា ឬក៏អត់<នោះ> ព្រោះថា ឯកសារទី១ហ្នឹងចុះខែមេសា ឆ្នាំ ២០១០ ចំណែកឯ<ទម្រង់បែបបទ>ព័ត៌មានបន្ថែមហ្នឹងគឺចុះខែមិថុនា ឆ្នាំ២០១០ ដែលធ្វើឡើងដោយអង្គភាពជនរងគ្រោះ។ ហើយទម្រង់បែបបទទី១នោះ <តាមខ្ញុំគិតថា អង្គការមិនមែនរដ្ឋាភិបាលជួយ> បំពេញ<>។ អ៊ីចឹងបើយើងមើលតាមកាលវេលាទៅគឺថាវាងាយស្រួលជាង។ មេធាវីការពារក្តីនិយាយថា អត្តសញ្ញាណប័ណ្ណហ្នឹងភ្ជាប់ទៅនឹងទម្រង់បែបបទព័ត៌មានបន្ថែម តាមពិតទៅមិនត្រឹមត្រូវទេលោកប្រធាន។ សូមអរគុណ។

[០៩:៤០:៥០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំកត់សម្គាល់ឃើញថាសវនាការលើផលប៉ះពាល់នៃឧក្រិដ្ឋកម្មនេះ វាឈានទៅដល់សវនាការទៅលើព័ត៌មាន ទៅលើតម្លៃជាភស្តុតាងនៃទម្រង់ព័ត៌មានរបស់ជនរងគ្រោះ ដែលបានដាក់ដោយអង្គភាពជនរងគ្រោះហើយ គឺមុនពេលបញ្ចប់ការស៊ើបសួរ។ ចំពោះយើង គឺយើងត្រូវតែបំភ្លឺអំពីរបៀបដែលព័ត៌មានទាំងអស់នេះត្រូវបានប្រមូល ហើយនិងអ្វីដែលយើងចង់ដាក់នៅចំពោះមុខអង្គជំនុំជម្រះជាឯកសារភស្តុតាង។ ខ្ញុំគិតថា សវនាការលើឯកសារគឺនៅពេលក្រោយទេ ឥឡូវនេះយើងកំពុងតែបំពុលសវនាការទៅលើផលប៉ះពាល់នៃឧក្រិដ្ឋកម្មហើយ។ អ្វីដែលសំខាន់ថ្ងៃនេះ គឺជាសក្ខី-កម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី។ ដូច្នេះអ្វីៗ គឺសម្រេចទៅលើអង្គជំនុំជម្រះទៅលើចំណុចនេះ។ ចំពោះខ្ញុំគឺខ្ញុំត្រូវតែបំភ្លឺអំពីបញ្ហាពាក់ព័ន្ធទៅនឹងកំហុសជាក់ស្តែងដែលមាននៅក្នុងទម្រង់ព័ត៌មានជនរងគ្រោះ ក៏ដូចជាទម្រង់បែបបទព័ត៌មានបន្ថែម<ដែលបានដាក់ចូលក្នុងសំណុំរឿងរួចហើយនោះ>។ យើងក៏ដូចភាគីផ្សេងទៀតដែរ យើងក៏ឃើញ<ភាពមិនត្រឹមត្រូវ>និងបញ្ហា<>ហ្នឹងដែរ។ ក៏ប៉ុន្តែខ្ញុំសង្ឃឹមថា<ដើមបណ្តឹងរដ្ឋប្បវេណីមានឱកាសថ្លែងទុក្ខរបស់ខ្លួន ដោយយើងមិនត្រូវប្រើប្រាស់ពេលវេលាជ្រុលហួសហេតុលើបញ្ហានេះឡើយ។ តាមពិតទៅវាសំខាន់មែន ប៉ុន្តែសម្រាប់ថ្ងៃនេះបើ>ធ្វើយ៉ាង

<នេះទៀតនោះវាបំពុលកិច្ចពិភាក្សាក្នុងអង្គជំនុំជម្រះជាមិនខាន>។

[០៩:៤២:៤៨]

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញមេធាវីអន្តរជាតិការពារក្ដីលោក ខៀវ សំផន។

**កញ្ញា អង់តា ហ្គីសសេ៖**

<តាមពិតទៅវា>មានបញ្ហាបកប្រែ <ប៉ុន្តែដល់វេនខ្ញុំហើយ ខ្ញុំត្រូវតែនិយាយ>។ <ខ្ញុំសុំនិយាយដោយខ្លីៗទេ។> ខ្ញុំយល់ថា សវនាការមិនប្រព្រឹត្តទៅដូចដែល<>មេធាវីដើមបណ្ដឹងចង់បានទេ។ <ខ្ញុំយល់ច្បាស់ណាស់ថា>គាត់ចង់<>ឲ្យ<លើក>ពិភាក្សាគ្នានៅពេលក្រោយ ក៏ប៉ុន្តែ<បញ្ហានៅត្រង់ថាចុះបើ>យើងឃើញ<ថាមានព័ត៌មាន>ផ្ទុយគ្នា<បែប>នេះ<ឲ្យយើងធ្វើយ៉ាងដូចម្ដេចទៅ?>។ អ៊ីចឹងយើងព្យាយាមធ្វើយ៉ាងម៉េច<>ឲ្យ<ខ្លីហើយខ្លឹម ប៉ុន្តែខ្ញុំមិន>ឃើញ<យើងវាយតម្លៃ>អំពីភាពផ្ទុយគ្នានៃចម្លើយនេះ<ដោយរបៀបណាឲ្យលើសពីនេះទេ ខណៈដែលដើមបណ្ដឹងរដ្ឋប្បវេណីដែលជាម្ចាស់នៃព័ត៌មាននោះកំពុងមានវត្តមាននៅក្នុងក្រចកសេះ ចំពោះមុខអង្គជំនុំជម្រះនេះស្រាប់>។ អ៊ីចឹងខ្ញុំគិតថាយើងអាចបង្ហាញបញ្ហាហ្នឹង<ឲ្យកាន់តែច្បាស់ នៅទីកន្លែងនេះតែម្ដង>។

**ប្រធានអង្គជំនុំ៖**

បានហើយ!

[០៩:៤៤:០៥]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៤៦:១១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម ក្លូឌា ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ដើម្បីស្វែងរកដំណោះស្រាយក្នុងការអនុវត្តជាក់ស្ដែង និងពិចារណានូវអ្វីដែលសហមេធាវីនាំមុខទើបតែលើកឡើងអំពីដំណើរការនៃការ គឺថាជ្រើសរើស គឺថាដូចជាមិនត្រឹមត្រូវទេ <ប៉ុន្តែដើម្បីដោះស្រាយបញ្ហាខាងលើ អង្គជំនុំជម្រះមានយោបល់ដូចតទៅ៖> លោក កូប៉េ <ការ>បង្ហាញអត្តសញ្ញាណប័ណ្ណ<ឲ្យទៅដើមបណ្ដឹងមើលថាតើគាត់ជាបុគ្គលតែមួយឬយ៉ាងណានោះ >ខ្ញុំយល់ឃើញថា<លោក

មិនត្រូវរំពឹងថាគាត់អាចបញ្ជាក់ពីស្នាមក្រយៅមេដៃបានទេ ថ្វីត្បិតតែយ៉ាងនោះក្តីក៏វាអាចជួយបំភ្លឺបានខ្លះៗផងដែរ> ក៏ប៉ុន្តែ<>មិនត្រូវតែផ្តោតតែទៅលើភាពមិនស៊ីសង្វាក់គ្នានោះទេ <ហើយ>យើងមិនបានរារាំងមិនឲ្យលោកតាំងសំណួរនោះទេ។ លោកគ្រាន់តែស្វែងរកថាវាមានបញ្ហា<នៅត្រង់ណាទៅបានហើយ ព្រោះថា>យើងត្រូវរៀបចំនីតិវិធីដែលសេសសល់សម្រាប់ថ្ងៃនេះ<ទៀតដែរ>។ <>។

[០៩:៤៧:៥២]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមជូនឯកសារនេះទៅ<មន្ត្រី>តុលាការ។

**ប្រធានអង្គជំនុំ៖**

ជូនៗទៅណា? ជូនឯកសារទៅណា? លោក វ៉ិចទ័រ កូប៉េ ជូនឯកសារទៅណា?

ម៉េចទៅមានការបកប្រែទេ?

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

បាទ អត់មានបកប្រែផង។

*(សម្រាករយៈពេលខ្លី)*

[០៩:៤៩:១០]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<លោកមេធាវី> ដើមបណ្តឹងរដ្ឋប្បវេណីកំពុងចាំឲ្យលោកសួរសំណួរហើយ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** <>លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី លោក<ស្រីស្គាល់>ឯកសារនេះទេ? <តើ>លោក<ស្រី>ឃើញ<សំណៅ>ចម្លងអត្តសញ្ញាណប័ណ្ណរបស់លោកស្រីទេ?

**លោក យ៉ែម ខុន្នី៖**

**ឆ៖** អត្តសញ្ញាណប័ណ្ណខ្ញុំមានតែមួយ គ្មានថតជាបីបួនអ៊ីចឹងផង។ នេះខ្ញុំយកមកក៏មានដែរនេះ។ មានទៅបីបួន មាននេះហ្នឹងណា អត់មាន បើខ្ញុំមានតែមួយ។ ហើយដល់ថាខ្ញុំមានពីរបីអ៊ីចឹង ខ្ញុំទៅធ្វើឯណាបានពីរបីទៅ។

**ស៖** ប្រហែលជាមានការយល់ខុសហើយ អ្វីដែលយើងកំពុងតែបង្ហាញទៅលោកស្រីនេះ គឺថាវាគ្រាន់តែជា<សំណៅ>ចម្លងអត្តសញ្ញាណប័ណ្ណហ្នឹងចេញពីអត្តសញ្ញាណប័ណ្ណដើមរបស់លោកស្រី។

<សំណួរសួរថាតើនេះជាសំណៅ ឬការថតចម្លងនៃ>អត្តសញ្ញាណប័ណ្ណដើមរបស់លោកស្រី<មែនដែរឬទេ?>

**ឆ៖** ខ្ញុំធ្វើតែម្ដងហ្នឹង។ ខ្ញុំលែងធ្វើតាំងពីយូរ ទើបតែធ្វើប៉ុន្មានខែហ្នឹង អាហ្នឹងអាធ្វើអត្តសញ្ញាណប័ណ្ណ គេថាអត្តសញ្ញាណប័ណ្ណស្អី អាវឹងៗនោះ។ អានេះធ្វើមុន ហើយអានេះមិនមែនទេ។ អានេះធ្វើមុនអាលើ។ អាក្រោមនេះមិនមែនទេ។ អានេះមិនមែនទេ។ អត្តសញ្ញាណប័ណ្ណ មិនមែនរបស់ខ្ញុំទេ។ អានេះបានរបស់ខ្ញុំពិតណ៎ា អាលើ អានេះ។ អានេះមិនមែនទេ។

**ស៖** លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី <អ្វីដែល>លោក<ស្រី>ឃើញ<នេះគឺជា>ផ្នែកខាងមុខ <>និងផ្នែកខាងខ្នង<ដែលបានថតចម្លងចេញពី>អត្តសញ្ញាណប័ណ្ណរបស់លោកស្រី<។>

**ឆ៖** ខ្ញុំគ្មាន។ ខ្ញុំឆ្លើយថាគ្មានៗ របស់ខ្ញុំតែមួយហ្នឹង ថតតែមួយហ្នឹង គ្មានផ្ដិតអីចឹង ខ្ញុំអត់មាន។

[០៩:៥១:៥៧]

**ប្រធានអង្គជំនុំ៖**

លោកស្រី ខុន្នី តាមចម្លងតាក្នុងអត្តសញ្ញាណប័ណ្ណហ្នឹង វាមានខាង -- ទាំងសងខាង ហើយអានេះគឺវាទាំងសងខាង។ បានន័យថា ម្ខាងខាងរូបថត ហើយម្ខាងទៀតអត់មានរូបថតទេ។ នេះដែលមានរូបសញ្ញានៃផែនទីនៃប្រទេសកម្ពុជានេះ ហើយនិងត្រារបស់អាជ្ញាធររាជធានីភ្នំពេញនេះ។ នេះគឺវាម្ខាងទៀត អីចឹងរបស់តែមួយទេ គ្រាន់តែគេថតចម្លងចេញ ហើយមិនអាចថតចម្លងបានល្អទេ ដោយសារថានោះត្រូវតម្រូវឱ្យថតម្ខាងដាក់ខាងលើ ហើយអាម្ខាងទៀតដាក់ខាងក្រោមអីចឹង។ លោកស្រីយល់ទេអាហ្នឹងគឺរបស់តែមួយទេ។

**លោកស្រី យ៉ែម ខុន្នី៖**

បើថា គេថតចម្លងអីចឹង ខ្ញុំយល់។ បើថាឱ្យខ្ញុំថាបន្លំក្លែងក្លាយ ថាថតអូសពីរអីចឹង ខ្ញុំនៅតែប្រកែក ដល់ឥឡូវអស់លោកថា អីចឹងខ្ញុំយល់។

**ប្រធានអង្គជំនុំ៖**

ហើយលោកស្រីគិតថា អារបស់ថតចម្លងនេះ គឺថតចម្លងចេញពីអត្តសញ្ញាណប័ណ្ណចាស់របស់លោកស្រីដែរឬទេ?

**លោកស្រី យ៉ែម ខុន្នី៖**

ថតអាចាស់ យកមកធ្វើអាថ្មី យកថា គេថា កាតអាស៊ានៗ អាកាតវឹងនោះ។ ដល់ហើយគេឱ្យខ្ញុំ

ធ្វើថ្មីទុកអាហ្នឹងទៅ។ អាថ្មីនេះ ខ្ញុំកាន់ដើររាល់ថ្ងៃ។

**ប្រធានអង្គជំនុំ៖**

តើលោកស្រីស្គាល់ទេ ថានេះជារូបរបស់លោកស្រី? រូបថតនេះ ហើយនិងអត្តសញ្ញាណដែលលោកស្រី -- អត្តសញ្ញាណប័ណ្ណដែលលោកស្រីធ្លាប់ប្រើអាចាស់ពីមុនមកនោះ តើវាដូចគ្នាហ្នឹងរូបថតនេះដែរឬទេ? អាដែលថតចម្លងនេះដែរឬទេ?

**លោកស្រី យ៉ែម ខុន្នី៖**

*(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

[០៩:៥៩:៤០]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីបន្តទៀត សំណួរទៀត។ គាត់បានទទួលស្គាល់ហើយថា នេះជាអត្ត-សញ្ញាណប័ណ្ណដែលថតចេញពីអត្តសញ្ញាណប័ណ្ណចាស់របស់គាត់។ ប៉ុន្តែឥឡូវហ្នឹង អត្តសញ្ញាណប័ណ្ណហ្នឹងគេដកហើយ គេដាក់ធ្វើថ្មីឲ្យជំនួសវិញ ដែលជាប្រភេទអត្តសញ្ញាណប័ណ្ណរឹង។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំព្យាយាមសួរ<ដោយងាយ>ៗទេ។ តើលោកស្រី និងឪពុកម្តាយរបស់លោកស្រីរស់នៅភ្នំពេញ ឬក៏អត់ទេ នៅក្នុងឆ្នាំ១៩៧៥ ហើយក្រោយមក ត្រូវបានគេជម្លៀសចេញពីភ្នំពេញ? ឬក៏លោកស្រីរស់នៅឯកម្ពុជាក្រោម ហើយក្រោយមក ទើបបានគេជម្លៀសមក?

**លោកស្រី យ៉ែម ខុន្នី៖**

**ឆ៖** ខ្ញុំនិយាយដដែលៗទៅ ពិបាកណាស់ថាខ្ញុំមិនដែលនៅភ្នំពេញ មិនដែលស្គាល់ភ្នំពេញទេ ទើបតែស្គាល់ឥឡូវហ្នឹង។ ហើយដល់មកសួរអ៊ីចឹង ខ្ញុំនៅតែពិបាកឆ្លើយ បើមិនដឹងភ្នំពេញហ្នឹងម៉េចផង ទើបតែមកស្គាល់ឥឡូវហ្នឹង។ ហើយឲ្យខ្ញុំឆ្លើយម៉េចទៀត បើខ្ញុំឆ្លើយថាអត់ស្គាល់ ទើបតែមកស្គាល់សម័យហ្នឹង ឥឡូវហ្នឹងសោះ ឲ្យខ្ញុំនៅស្គាល់ថាម៉េច។ បើពង្រឹតឲ្យខ្ញុំថាស្គាល់ បើខ្ញុំមិនស្គាល់ ឲ្យខ្ញុំឆ្លើយថាស្គាល់ម៉េច។ ទើបតែមកស្គាល់សម័យឥឡូវហ្នឹង បានកូនកាត់ដេរទៅ បានមកស្គាល់សម័យហ្នឹង។ បើកូនមិនបានមកកាត់ដេរ បែបមិនស្គាល់ទៀតផង។ សូម្បីតែតាកែវ បែបមិនស្គាល់ទៀតផង។ ខ្ញុំអ៊ីចឹងតែម្តង។

[០៩:៥៦:២៩]

**ស៖** លោកស្រី ខ្ញុំមានសំណួរចុងក្រោយ។ តើឪពុកម្ដាយរបស់លោកស្រី <>ជាអតីតជាទាហាន លន់ នល់ ឬក៏អត់ទេ នៅក្នុងឆ្នាំ១៩៧៥?

**ឆ៖** ឪខ្ញុំអត់បានមានធ្វើ អត់បានធ្វើអីសោះ។ គាត់ធ្វើអី បើគ្មានផង ក្រផង ទៅធ្វើឯណា។ គ្មានដែលធ្វើស្អីទេ។ ម៉ែឪខ្ញុំនៅធ្វើតែស្រែ នៅចិញ្ចឹមកូនហ្នឹង។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្តផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ក្រុមយើងខ្ញុំអត់មានសំណួរសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះទេ។ បាទ សូមអរគុណ។

[០៩:៥៨:១៥]

**ប្រធានអង្គជំនុំ៖**

លោកស្រី យ៉ែម ខុន្នី អង្គជំនុំជម្រះសូមអរគុណចំពោះលោកស្រី ហើយការថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្ម ដែលលោកស្រីអះអាងថា លោកស្រីបានទទួលរងក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យបានដល់ទីបញ្ចប់ហើយ។ ហើយឥឡូវនេះ លោកស្រីអាចវិលត្រឡប់ទៅកាន់ទីលំនៅ ឬក៏គោលដៅណាដែលលោកស្រីមានបំណងចង់ទៅបានហើយ។ សូមលោកស្រីធ្វើដំណើរត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។

ហើយមន្ត្រីរដ្ឋបាលតុលាការសបម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។

បាទ ឥឡូវនេះ ដល់ពេលសមស្របនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់ ដប់ប្រាំនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ០៩:៥៩ នាទី ដល់ម៉ោង ១០:១៦ នាទី)*

[១០:១៦:៥០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការតទៅនេះ ស្តាប់សេចក្តីថ្លែងរៀបរាប់ទុក្ខសោកវេទនារបស់ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-293។

មន្ត្រីរដ្ឋបាលតុលាការ អញ្ជើញដើមបណ្តឹងរដ្ឋប្បវេណីរូបនេះមកកាន់កន្លែងថ្លែងរៀបរាប់ទុក្ខសោកវេទនានៅក្នុងបន្ទប់សវនាការចំពោះមុខអង្គជំនុំជម្រះ។

*(ដើមបណ្តឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីដើមបណ្តឹងរដ្ឋប្បវេណី តើលោកឈ្មោះអី?

**លោក ប៊ុន សារឿន៖**

**ឆ៖** បាទ ខ្ញុំបាទឈ្មោះ ប៊ុន សារឿន។

**ស៖** អរគុណលោក ប៊ុន សារឿន។ តើលោកកើតនៅថ្ងៃខែឆ្នាំណា?

**ឆ៖** ខ្ញុំកើតនៅឆ្នាំ១៩៦៣។

**ស៖** អរគុណ ហើយទីកន្លែងកំណើត ទីកន្លែងលំនៅដ្ឋានបច្ចុប្បន្នរបស់លោកៗរស់នៅទីកន្លែងណា?

**ឆ៖** ខ្ញុំបាទនៅភូមិអណ្តូងក្រសាំង ឃុំស្នាមព្រះ ស្រុកបាកាន ខេត្តពោធិ៍សាត់។

**ស៖** ហើយសព្វថ្ងៃនេះ លោកប្រកបមុខរបរអ្វីដែរ?

**ឆ៖** ខ្ញុំបាទធ្វើស្រែ។

**ស៖** ឪពុកបង្កើតរបស់លោក គាត់ឈ្មោះអី? និងម្តាយបង្កើតរបស់លោក គាត់ឈ្មោះអី?

**ឆ៖** ឪពុកឈ្មោះ ប៊ុន នាង ម្តាយឈ្មោះ មាស សាង។

**ស៖** ហើយភរិយារបស់លោកឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** ប្រពន្ធរបស់ខ្ញុំឈ្មោះ ឃុន ធឿន មានកូនប្រាំមួយនាក់។

**ប្រធានអង្គជំនុំ៖**

អរគុណលោក ប៊ុន សារឿន។ ក្នុងនាមលោកជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសវនាការនេះ អង្គជំនុំជម្រះនឹងផ្តល់វេទិកាឲ្យលោកអាចថ្លែងរៀបរាប់ប្រាប់ដល់អង្គសវនាការអំពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មដែលកើតមានចំពោះលោក ជាអាទិ៍ ខូចខាតខាងផ្លូវចិត្ត ផ្លូវកាយសម្ភារៈ ដែលជាព្យសនកម្មផ្ទាល់ខ្លួន ដែលជាបច្ច័យដោយផ្ទាល់ពីបទឧក្រិដ្ឋ និងបានកើតមានឡើងពិតប្រាកដរហូតដល់សព្វថ្ងៃនេះ ដែលនាំឲ្យលោកតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងក្តីនេះពាក់ព័ន្ធនឹងបទឧក្រិដ្ឋដែលត្រូវចោទប្រកាន់ទៅលើជនជាប់ចោទចំនួនពីររូបគឺលោក នួន ជា និងលោក ខៀវ សំផន ដែលបានប៉ះពាល់ផ្ទាល់ចំពោះលោកក្នុងរបបកម្ពុជាប្រជាធិបតេយ្យចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ៧៩។

[១០:២១:០៣]

ហើយម្សិលមិញអង្គជំនុំជម្រះអត់បានទៅស្គាល់លោកបុគ្គលិកអង្គការ ធី.ភី.អូ ហើយឥឡូវនេះ អង្គជំនុំជម្រះសួរបញ្ជាក់ហ្នឹងវិញថា លោកឈ្មោះអីដែរបុគ្គលិកអង្គការ ធី.ភី.អូ? ហើយលោកមានមុខងារអ្វីនៅអង្គការនោះ?

**លោក យន់ សារ៉ាត់៖**

បាទ សូមគោរពលោកប្រធាន ខ្ញុំបាទឈ្មោះ យន់ សារ៉ាត់ ខ្ញុំជាបុគ្គលិកខាងផ្នែកប្រឹក្សាផ្លូវចិត្តដល់ដើមបណ្តឹង និងសាក្សីមកពីអង្គការធី.ភី.អូ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក សារ៉ាត់។

បាទ ជាបន្តទៅនេះតាមសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសួរអំពីស្ថានភាពទុក្ខសោកវេទនា និងព្យសនកម្មទាំងឡាយដែលកើតមានចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

សូមអញ្ជើញ!

[១០:២២:០៨]

**លោកស្រី ជេត វណ្ណលី៖**

សូមអរគុណលោកប្រធាន។ ជាដំបូងខ្ញុំសូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។ ជម្រាបសួរលោក ប៊ុន សារឿន ខ្ញុំឈ្មោះ ជេត វណ្ណលី មេធាវីដើមបណ្តឹងរដ្ឋប្បវេណី។

ជាដំបូងនេះដែរ ខ្ញុំមានបញ្ហាមួយដែលជាចំណុចកត់សម្គាល់របស់ខ្ញុំ។ ខ្ញុំសូមអនុញ្ញាតលោកប្រធានធ្វើការបញ្ជាក់ និងកែតម្រូវលើឯកសារពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីលេខ D22/1659, ERN ខ្មែរលេខ00532498, ERN ជាភាសាអង់គ្លេសលេខ 01067020 ដែលក្នុងនោះសរសេរថា "ព្រឹកឡើងគេឲ្យខ្ញុំទៅដឹកទឹកត្រីនៅថ្នស កំពង់អំពិល ដោយបររទេះទៅម្នាក់ឯង។ ទៅដល់វត្តចំប៉ាស្រាប់តែឃើញពួកយោធាឲ្យឡើងសេ.អឹម.សេ ពេលនោះមានទាហានខ្មែរក្រហមបីនាក់មកកាន់កាំភ្លើងគ្រប់ដៃដឹកខ្ញុំរហូតដល់ភ្នំខ្លែង។ រុញចុះពីឡានទៅផ្លូវជាតិ រួចចងស្លាបសេកបណ្តើរទៅដាក់មន្ទីរលើភ្នំខ្លែង ស្រុកទ្រាំង ខេត្តតាកែវ។ ទៅដល់ទីនោះ ខ្ញុំមិនស្គាល់ពួកវាទេ បានជួបនឹងគ្រូ រ៉ន គាត់ថា គាត់ជាប់នៅទីនេះយូរហើយ។ នៅពេលធ្វើការគាស់ព្រិច គាស់ព្រៃរយៈពេល៣ថ្ងៃ គាប់សួរថា ស្គាល់ក្រមាសូត្រនេះទេ? ខ្ញុំថា ស្គាល់ព្រោះជាក្រមារបស់បងខ្ញុំដែលបួសជាព្រះសង្ឃ។ គាត់ថា ងាប់ទាំងអស់។ ពេលឮដូចនេះ ខ្ញុំចេះតែដេកភ័យមិនដឹងជាថ្ងៃណាគេសម្លាប់ខ្លួនទេ។ ព្រោះនៅពេលយប់ឡើងពួកវាចាប់ដាក់ខ្នោះជើងមួយឡោស៊ីជាប់ តែអ្នកទោសដែលជាប់ធ្ងន់គឺពួកវាមិនចេញមកធ្វើការនៅខាងក្រៅទេ។ អ្នកជាប់ទោសគ្មានអនាម័យទេ ខោអាវឡើងស្អុយធុំក្លិនអាចម៍នោម ពេលយប់ឡើងមិនសូវបានដេកទេ ឮសូរតែពួកវារើ ប្រជាពលរដ្ឋស្រែកអូយ ហើយពួកវាថារំខានពួកវាដេក។

[១០:២៤:១១]

ខ្ញុំយប់ឡើងដាក់ខ្នោះជើងដែកមួយចំហៀងខាងឆ្វេងស៊កដែកពីខាងក្រោយ។ ពេលយប់ឡើងគឺកន្លែងដេករនាបប្រហោង ហើយមានឈ្លបដើរមើល បើអ្នកណាដាក់ខ្នោះតឹងហើយស្រែក ឈ្លបនោះនឹងយកដំបងឫស្សីវ៉ៃចំកណ្តាលខ្នងតែម្តង"។

តាមការដែលខ្ញុំបានប្រឹក្សាផ្ទាល់ជាក់ស្តែងជាមួយដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនលើកច្រើនសាមុនសវនាការនេះ លោក ប៊ុន សារឿន បានបញ្ជាក់ថា អង្គហេតុដែលនាងខ្ញុំអាននេះជាអង្គហេតុរបស់បងប្រុសគាត់ ឈ្មោះ ប៊ុន នន ដែលជាយោធាខ្មែរក្រហម មិនមែនជាអង្គហេតុរបស់គាត់ទេ។ ដូច្នេះ លោកប្រធាន និងអង្គជំនុំជម្រះ និងភាគីទាំងអស់មេត្តាជ្រាបទទួលយកការកែតម្រូវនេះ។ ហើយអង្គ

01086759



ហេតុនេះក៏មិនស្ថិតនៅក្នុងវិសាលភាពត្រាំកក់ដែរ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន!

[១០:២៥:២២]

**កញ្ញា អង់តា ហ្គីសសេះ៖**

លោកប្រធាន ខ្ញុំកំពុងតែភ្ញាក់ផ្អើលចំពោះវិធីនៃការធ្វើរបស់មេធាវី។ ប្រសិនបើមានការកែប្រែបែបនេះ មិនមែនមេធាវីជាអ្នកធ្វើសក្ខីកម្មខ្លួនឯងទេ គាត់ត្រូវតែសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី។ <>ខ្ញុំអត់យល់ពីវិធីសាស្ត្រ<ដែល>គាត់<កំពុងប្រើប្រាស់ក្នុងសវនាការ>ហ្នឹងទេ។ <ប្រសិនបើ> លោកស្រីមេធាវីគាត់<ចង់ធ្វើអ្វីក៏ធ្វើចុះ ដោយគាត់>ត្រូវសួរទៅដើមបណ្តឹងទៅ ដើម្បីឲ្យដើមបណ្តឹងគាត់ជាអ្នកកែតម្រូវមិនមែនលោកស្រីមេធាវី<ខ្លួនឯង>មក<អានការ>កែតម្រូវខ្លួនឯង <អស់ពីរឬបីនាទី>អ៊ីចឹងទេ។

**លោកស្រី ជេត វណ្ណលី៖**

ប៉ុន្តែ ខ្ញុំសូមឆ្លើយលោកប្រធាន។ គឺថាចំណុចនេះ យើងអាចសួរដើមបណ្តឹងដោយផ្ទាល់ លោកនឹងបញ្ជាក់ ប៉ុន្តែនេះគ្រាន់តែជាការកែតម្រូវ និងបញ្ជាក់មុនពេលដែលយើងខ្ញុំសួរសំណួរទៅដល់ដើមបណ្តឹង លោកប្រធាន។

[១០:២៦:១២]

**ប្រធានអង្គជំនុំ៖**

បាទ យើងក៏ចម្លែកដែរ មិនដែលជួបដែរ។ ប៉ុន្តែអ៊ីចេះ ទោះបីយ៉ាងណាក៏ដោយយើងអំមិញប្រគល់ឲ្យវេទិកាទៅសួរ តាំងសំណួរសាកសួរពាក់ព័ន្ធជាមួយនឹងស្ថានភាពទុក្ខសោកវេទនា និងព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ម្សិលមិញ យើងបានកាត់បន្ថយរយៈពេល១០នាទី បានន័យថា នៅតែ៣០នាទីទេ សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការសាកសួរដើម្បីជំរុញល្បឿននៃការសវនាការហ្នឹងបានដល់ទីបញ្ចប់តាមសំណើសុំរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមឲ្យប្រឹងប្រែងឲ្យបានចប់ថ្ងៃនេះ ក្រែងលោលោកស្រីប្រើ -- មេធាវីប្រើពេលវេលាខ្លះខ្ជាយឥតប្រយោជន៍ទៅ ហើយដល់ពេលអស់ពេលទៅអត់មាននិយាយបញ្ហាសារវន្តពាក់ព័ន្ធនឹងបញ្ហាអង្គហេតុ ឬក៏បញ្ហាសារវន្តដែលអង្គជំនុំជម្រះចង់ស្តាប់នៅពេលនេះ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្ទបកប្រែ និងខ្ទបកប្រែបន្ត។*

**លោកស្រី ជេត វណ្ណលី៖**

សូមអរគុណលោកប្រធាន។ លោកប្រធានអនុញ្ញាតឲ្យខ្ញុំសួរដើមបណ្តឹងពីចំណុចដែលខ្ញុំលើកឡើងអំមិញហ្នឹងបានទេ ចាស?

**ប្រធានអង្គជំនុំ៖**

សួរអីសួរទៅ ប៉ុន្តែកំណត់សវនាការនេះ គឺស្តាប់សេចក្តីថ្លែងរៀបរាប់អំពីស្ថានភាពព្យសនកម្ម ស្ថានភាពទុក្ខសោកវេទនារបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលគោលបំណងនៃការសុំមកថ្លែងនេះ ដើម្បីឲ្យអង្គជំនុំជម្រះស្តាប់រៀបរាប់អំពីទុក្ខសោកវេទនារបស់គាត់ជូនអង្គសវនាការស្តាប់។ ធ្វើយ៉ាងម៉េចឲ្យពាក់ព័ន្ធជាមួយនឹងរឿងស្ថានភាពព្យសនកម្ម និងទុក្ខសោកវេទនានេះជាចម្បងនៃការសួរ ធ្វើសវនាការនៅពេលនេះ។ បញ្ហាផ្សេងទៀត បញ្ហាបន្ទាប់បន្សំ ដែលវាលានចេញដោយសារការឆ្លើយរៀបរាប់មកវាតែងតែវាពាក់ព័ន្ធនៃអង្គហេតុ ហើយអង្គហេតុនោះហើយដែលអាចសួរនាំបាននៅក្នុងអំឡុងពេលដំណើរការសវនាការនេះ។

[១០:២៨:១៣]

**លោកស្រី ជេត វណ្ណលី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំចាប់ផ្តើមសួរដល់ដើមបណ្តឹងរដ្ឋប្បវេណី។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ជេត វណ្ណលី៖**

**ស៖** ជម្រាបសួរលោក ប៊ុន សារឿន ខ្ញុំចង់ឲ្យលោករៀបរាប់ប្រាប់ខ្ញុំចាប់ពីថ្ងៃ១៧ មេសា ៧៥ តើលោកនៅឯណា? ហើយពេលនោះលោកអាយុប៉ុន្មាន? ហើយលោកមានបងប្អូនប៉ុន្មាននាក់?

**លោក ប៊ុន សារឿន៖**

**ឆ៖** ខ្ញុំបាទនៅភូមិព្រៃឈើទាល ឃុំតាអោម ស្រុកត្រាំកក់ ខេត្តតាកែវ។ មានបងប្អូនបួននាក់ ប្រុសបី ស្រីមួយ។ បងប្រុស ប៊ុន នីម ធ្វើជាលោកសង្ឃ, បងប្រុស ប៊ុន នន ជាទាហានខ្មែរក្រហម។ ឪពុកឈ្មោះ ប៊ុន នាង ជាប្រធានក្រុមភូមិព្រៃឈើទាល។ អ៊ំ មាស អេង គាត់ជាប្រធានភូមិព្រៃឈើទាលពីសម័យ លន់ នល់។ ហើយគ្នាគាត់មានបីនាក់ទៀតឈ្មោះ ពូម៉ម ជាអនុប្រធានព្រៃឈើទាល។ ពូវុន ជាប្រធានក្រុម។

[១០:២៩:៥៣]

**ស៖** អរគុណលោក សារឿន។ តើពេលនោះមានហេតុការណ៍អីកើតឡើង? ហើយពេលនោះលោកអាយុប៉ុន្មាន?

**ឆ៖** ពេលនោះខ្ញុំអាយុ១១ឆ្នាំ។ ខ្ញុំ រយៈពេលដែលខ្ញុំនៅហ្នឹង នៅព្រៃឈើទាលហ្នឹងបានប្រហែលជាបួនប្រាំនេះទេ ពេលជម្លៀសពី១៧ចូលទៅហ្នឹង បែកភ្នំពេញហ្នឹង ខ្ញុំក៏នៅក្នុងវត្តហ្នឹង ខ្ញុំក៏បានឃើញគេចងគេអី បងអ៊ំខ្ញុំហ្នឹងទៅតាមផ្លូវវត្តចាក់ជ្រុំហ្នឹងទៅលិចទៅ មិនដឹងជាគេចងទៅខាងណា ខ្ញុំអត់ដឹងដែរ ព្រោះខ្ញុំឯវត្តនោះ។ ដល់ពេលរួចហ្នឹង ខ្ញុំក៏មកសួរម៉ែ ម៉ែគាត់ថា ដែលម៉ែ ឪទៅណា ម៉ែឃើញគេចងគេអីអ៊ីចឹង គាត់ថា ទេមិនដឹងដែរ គេថាឲ្យគាត់ទៅដឹកទឹកត្រីទឹកអីនៅឯណាទេ បើមិនដឹងដែរ។ ដល់ហើយអ៊ីចឹង ខ្ញុំថាដឹកទឹកត្រីធ្វើអី បើឃើញគេចងទៅទាំងអស់ ទាំងអ៊ំទាំងអីទាំងអស់ទៅហ្នឹងហើយ ហើយខ្ញុំនៅឯវត្តហ្នឹងជាមួយលោកបង នៅវត្តចាក់ជ្រុំហ្នឹង ខ្ញុំក៏វាមិនបានដឹងថាគាត់ហ្នឹងទៅណាទៅណី។ ដល់ឮសួរអ៊ីចឹង ម៉ែ គាត់យំ គាត់ស្រែកអ៊ីចឹងទៅ។ គាត់ថា បើគេចងអ៊ីចឹង មានតែគេយកទៅវៃចោលឯណាហ្នឹងកូន បើមិនដឹងដែរ ហើយគាត់យំ គាត់ស្រែកអ៊ីចឹងទៅ ខ្ញុំក៏យំតាមគាត់ហ្នឹង។ ដល់ពេលហ្នឹងមក ខ្ញុំក៏បកពីហ្នឹង ខ្ញុំឈប់ទៅនៅវត្ត មកនៅជាមួយគាត់ បានរយៈនោះប្រហែលជាបួនប្រាំថ្ងៃទៀតហ្នឹង គឺថាឲ្យរៀបចំអីវ៉ាន់រើសទៅនៅត្រពាំងចែង ប៉ុន្តែមិនដឹងត្រពាំងចែងឯណា បើខ្ញុំអត់ដែលស្គាល់ដែរ។

[១០:៣១:៤៥]

ក៏នាំគ្នាមួយហ្នឹង រៀបចំទៅជួបជុំគ្នានៅមួយកន្លែងហ្នឹង បានមានឈ្លបគេបីនាក់ គេបញ្ជូនខ្ញុំទៅទៅនៅត្រពាំងចែងហ្នឹងមានកាំភ្លើងមានអ៊ីចឹង ទៅចេះតែភ័យខ្លាចហើយ មិនដឹងជាគេយកទៅឯណា បើគេចងឪ ឃើញចងឪយកទៅបាត់ហើយ។ ហើយដល់នៅមួយម៉ែមួយកូនហ្នឹង ចេះតែភ័យចេះតែខ្លាចមិនដឹងថាគេយកទៅហ្នឹង គេឲ្យទៅហ្នឹងវាចោលអីៗអស់ហើយ គេរើសទៅ។ ដល់រើសទៅនៅត្រពាំងចែងហ្នឹងបានប្រហែលជាពីរបីថ្ងៃ បានធ្វើការ គេឲ្យនៅត្រពាំងចែងហ្នឹង។ ដល់ពេលធ្វើការៗអ៊ីចឹងរាល់ថ្ងៃអ៊ីចឹង រែកជីដាក់ស្រែ មើលទឹកស្រែ រហូតដល់ពេលអ៊ីចឹងមកៗនៅហ្នឹងហូបបាយហូបអី បបរនៅសាលាត្រពាំងស្វាយ សហករណ៍ត្រពាំងស្វាយហ្នឹង។ ដល់ពេលហើយអ៊ីចឹងទៅក៏ចេញមក ដើរមកៗខាងថ្នល់ក្រោម កន្លែងជិតវត្តហ្នឹងក៏ជួបពូរ៉ន។ ដល់ជួបពូរ៉ន គាត់ថា អ្អែង! គិតទៅឯណា? ខ្ញុំថា ខ្ញុំគេឲ្យមកធ្វើការ ប៉ុន្តែដល់ធ្វើការ ខ្ញុំចេះតែដើរមកក្បែរថ្នល់ហ្នឹងមក ប៉ុន្តែហួសម៉ោងគេធ្វើការ ហូបបាយហើយ។ ដល់ពេល គាត់ថា អញឃើញឪអ្អែងនៅមន្ទីរក្រាំងតាចាន់ ឃើញគេវៃធ្វើបាប ធ្វើអីហ្នឹង។ ខ្ញុំក៏

ដល់ឮសូរអ៊ីចឹង ធ្វើបាបម៉េច កន្លែងហ្នឹងគេហៅអី ក៏ខ្ញុំអត់ដឹងដែរ ឮថាគេយកទៅបាត់ៗ អ៊ីចឹងគាត់នៅរស់ទេចុះ។ គាត់ថា ឃើញនៅហ្នឹង គេធ្វើបាប គេវ៉ៃគេអីនៅហ្នឹង។ ហើយផ្ទះគាត់នៅចម្ងាយប្រហែលជា១០០ម៉ែត្រពីមន្ទីរក្រាំងតាចាន់ហ្នឹង។ ដល់ខ្ញុំឃើញហេតុផលអ៊ីចឹង ក៏ខ្ញុំទៅៗហ្នឹង ដល់ពេលអត់ទាន់បាននឹងទៅផង ក៏បបួលម៉ែបបួលអីហ្នឹងទៅៗអាកន្លែងមន្ទីរហ្នឹង។

[១០:៣៣:៥៧]

ទៅដល់ហ្នឹង ឃើញគាត់នៅរែកទឹករែកអីស្រោចដំណាំនៅហ្នឹង។ ដល់ពេលឃើញអ៊ីចឹងទៅ ខ្ញុំក៏យំក៏ស្រែក ដែលឃើញអ៊ីចឹង វារកអ្វីប្រៀបធៀបមិនបាន ឃើញគាត់មើលគាត់សឹងមិនស្គាល់។ គាត់ក៏ឃើញស្លៀកអាខោខ្មៅហ្នឹង អត់មានអាវមានអីហ្នឹង ក៏ឃើញអ៊ីចឹងទៅ មើលពីចម្ងាយទៅ សឹងតែមិនស្គាល់គាត់ ក៏នាំគ្នាអង្គុយមើល លបមើលពីផ្ទះ ពូរ៉ន ទៅហ្នឹង ហើយខ្ញុំថា នឹកឃើញសុំគេចូលទៅជួបហើយ ពូរ៉ន ថា គាត់ថាកុំសុំ។ ថាសុំទៅជួប នាំតែមានបញ្ហាដល់គាត់ ព្រោះគាត់អ្នកប្រាប់ទៅ។ បើចង់សុំចង់អី បើថាម៉េចៗនិយាយជាមួយគាត់សិន បើទៅៗវាទាក់ទងខ្លាច ក្រែងលោវាមានបញ្ហាដល់គាត់ទៅ វាពិបាកដល់គាត់។ ហើយខ្ញុំក៏សម្រេចចិត្តថា មិនហ៊ានទៅសុំ បានត្រឹមម៉ាឃើញ បានត្រឹមម៉ាយំសោកាហ្នឹង។ ដល់ពេលហ្នឹងក៏នៅកន្លែងគាត់ហ្នឹងបាន១យប់ ផ្ទះគាត់ហ្នឹង។ នៅហ្នឹងបានត្រឹមតែលបមើលគាត់ មិនហ៊ានចូលមិនហ៊ានអីទៅជិតគាត់ទេ។ ខ្លាច យប់ឡើងឮសូរតែមាត់ស្រែក តែមិនដឹងជាវ៉ៃគាត់ដែរ ឬមួយយ៉ាងម៉េច បានត្រឹមឮ បានត្រឹមសោកា។ ដល់ព្រលឹមឡើងជិតភ្លឺហ្នឹងក៏សម្រេចចិត្តចេញមកៗឲ្យទាន់ធ្វើការនៅកន្លែងសហករណ៍ហ្នឹងវិញ។ ដើបមកឯណាមួយទៅវាខ្លាចគេឃើញតាមផ្លូវណាមួយទៅខ្លាចវាមានរឿងដល់ ពូរ៉ន ណាមួយទៅវាខ្លាចខ្ញុំមកមិនទាន់ធ្វើការ គេហៅទៅកសាងក៏អីទៀត។ បានថាការងារនេះវាលំបាកណាស់ ឃើញពេលឃើញឪ ឃើញវេទនាអ៊ីចឹង វាពិបាក។

[១០:៣៦:០៨]

ប៉ុនខ្ញុំសុំទោស អំមិញដែលលោកប្រធាន ខ្ញុំអត់ទាន់បាននិយាយពីរឿងលោកបង។ ខ្ញុំនិយាយហួសបន្តិច លោកប្រធាន សុំទោស។ ពេលដែលមុនខ្ញុំទៅមន្ទីរក្រាំងតាចាន់ហ្នឹង ខ្ញុំដែលលោកបងខ្ញុំហ្នឹងនៅវត្ត តែដល់ពេលហើយខ្ញុំមកហ្នឹង ខ្ញុំបានឮអាឡានហ្នឹងសន្ធឹកឡានក៏សន្ធឹកចូលទៅកន្លែងវត្តហ្នឹង ខ្ញុំក៏វាមិនបានដឹងថាឡានហ្នឹងទៅណាដែរទេ ឃើញឡានសេ.អឹម.សេ ហ្នឹង ហើយហ្នឹង ឡានអាហ្ស៊ីបហ្នឹងឃើញបើកទៅហុយៗនៅផ្ទះ នៅខាងលិចផ្ទះហ្នឹង ខ្ញុំក៏ឃើញទៅ។ ដល់ពេលទៅៗវត្តហ្នឹងស្រាប់តែបានប្រហែលជាពីរបីថ្ងៃហ្នឹង គេឲ្យខ្ញុំជម្លៀសទៅហ្នឹង ប៉ុនខ្ញុំនិយាយផុតបន្តិចអំមិញលោកប្រធាន។ ដល់អា

ពេលហើយអ៊ីចឹងទៅក៏ទៅដល់ស្រាប់តែព្រលឹមឡើងហ្នឹង បានទៅធ្វើការពីរបីថ្ងៃហ្នឹង ខ្ញុំក៏ទៅជួបជាមួយប្រធានឈ្លបគេហ្នឹង គេថាឲ្យទៅជួយមើលអីវ៉ាន់នៅឯវត្ត។ ហើយខ្ញុំស្មានថាលោកបង នៅហ្នឹងខ្ញុំអត់បានដឹងដែរ ក៏ខំទៅហ្នឹងថាបានជួបលោកបង។ ដល់ពេលហើយអ៊ីចឹងទៅ ក៏ទៅអត់បានជួបលោកបង គេទៅណាអស់រលីង នៅសល់តែជីពរ។ វាបាត់ទៅ មិនដឹងទៅតាមឡាន ឃើញតែដានឡាន មិនដឹងគេយកទៅខាងណា ខ្ញុំអត់ដឹងដែរ។ ឃើញតែជីពរ ឃើញតែអី ហ្នឹងខ្ញុំក៏ -- គេឲ្យប្រមូលអាជីពរប្រមូលអីហ្នឹងដាក់នៅហ្នឹងឃ្លាំងនៅកេសគ្រាប់ កេសអីហ្នឹង។ ហើយឃើញព្រះអង្គ ឃើញអីហ្នឹងតាមកុដិហ្នឹង ឃើញបាក់ឃើញអីហ្នឹងក៏ប្រមូល ចេះតែប្រមូលយកមកដាក់នៅកន្លែងហ្នឹងជាមួយប្រធានឈ្លបឈ្មោះ អួច ឈ្មោះ គឿន ហ្នឹង។ ខ្ញុំក៏វាហួសចិត្តដែលបាត់លោកបងផង ណាមួយទៅកន្លែងដែលធ្លាប់គោរពបូជា ទៅជាស្ងាត់ឈឹងបាត់លោក បាត់អីអស់អ៊ីចឹងទៅ ខ្ញុំវាមានការស្ដុតអស់ហើយ វាបាត់ការ វារកនឹកឃើញអីក៏វាលែងឃើញហើយ ណាមួយបាត់ឪពុក ណាមួយបាត់លោកបង។ ហើយដឹងលោកពូដែលនៅបួសនៅវត្តចាក់ជ្រុំហ្នឹង។ ដល់ហេតុការណ៍ទាំងអស់នេះទៅវាឃើញទៅ វាដូចថា វាទុក្ខសោកបន្តរហូតគ្មានពេលទំនេរ។ វាមានតែការបាត់បង់រហូតតាំងពី៧៥ រហូតទល់គ្នានឹង៧៩។

[១០:៣៨:២២]

**ស៖** អរគុណលោក សារឿន។ ខ្ញុំចង់សួរលោកថាតើលោកកន្លងមកលោកគោរពបូជាសាសនាអីដែរ លោក?

**ឆ៖** ខ្ញុំគោរពសាសនាព្រះពុទ្ធ។

**ស៖** ចុះពេលដែលលោកឃើញការបំផ្លិចបំផ្លាញក្នុងវត្តអារាម ហើយឃើញព្រះបដិមាអីធ្លាក់បាក់បែកអ៊ីចឹង តើលោកមានអារម្មណ៍ និងទឹកចិត្តយ៉ាងម៉េចដែរ លោក?

**ឆ៖** រឿងអារម្មណ៍ខ្ញុំ វានឹកឃើញថាវាសោកស្ដាយដែរ កន្លែងធ្លាប់បូជា កន្លែងគោរព ទាល់តែទៅអត់មានលោក គ្មានមានអីអ៊ីចឹង ដឹងជាថា វាពិបាក ធ្លាប់មានបុណ្យមានទាន ដល់ពេលអត់មានបុណ្យមានទាន អ៊ីចឹងខ្ញុំក៏វាពិបាក។ ការនឹងគោរពបូជា វាដូចថា វាគ្មានអីទីពឹងអីទាំងអស់។ វាសាសនាក៏វាអស់ ណាមួយទៅវាបាត់បង់គោរពបូជា ដឹងទៅធ្វើស្អីនៅកន្លែងណាកើត វាមិនដែលជួបប្រទះ វាមិនដែលឃើញ។ ទើបតែបានជំនាន់ហ្នឹងបានខ្ញុំឃើញ របៀបរបបហ្នឹង វាដូចជាវាអស្ចារ្យពេកហើយ។

[១០:៣៩:៥៥]

**ស៖** អរគុណលោក សារឿន។ ខ្ញុំចង់បញ្ជាក់ដែរ អំមិញលោកបានបញ្ជាក់ថា ពេលដែលឪពុក

លោកត្រូវគេយកទៅក្រាំងតាចាន់ ហើយក្រោយមក បងលោកដែលជាលោកសង្ឃនោះ ត្រូវគេយកទៅទៀត។ ខ្ញុំចង់បញ្ជាក់លោកដែរថា លោកសង្ឃដែលនៅវត្តចាក់ជ្រុំហ្នឹង ត្រូវគេយកទៅទាំងអស់ ឬក៏នៅខ្លះដែរ ឬក៏ទាំងអស់ប៉ុន្មានអង្គដែរ ដែលយកទៅហ្នឹង?

**ឆ៖** ព្រះអង្គនៅហ្នឹង បើគិតទៅលោកវាមាន១៥អង្គ តែ១៥អង្គទាំងលោកបង ហើយលោកពូខ្ញុំ។ តែមិនដឹងជាយកទៅខាងណា ព្រោះបាត់ទាំងអស់ហើយ អត់មានឃើញ។ ទៅដល់នៅសល់តែវត្តកុដិអីវិនអត់មានឃើញទេ កុដិឈើបាត់អស់ នៅសល់តែកុដិថ្ម។ មិនដឹងជាគេយកទៅខាងណាខាងណី។ ហើយវិហារហ្នឹងឃើញចាក់សោជិត មិនដឹងជាដាក់ស្អីៗក្នុងហ្នឹង ខ្ញុំវាមិនបានដឹងដែរ គ្រាន់តែទៅជួយរៀបចំតែប៉ុណ្ណឹងហើយ ខ្ញុំក៏បកមកកន្លែងសហករណ៍វិញមក គេថាហើយៗយើងទៅក្រោយវិញ។ ក៏នាំគ្នាមកសហករណ៍ត្រពាំងចែងហ្នឹងវិញមក។ បានឮសួរដំណឹងថា ពូរ៉ន ប្រាប់ហ្នឹងក៏ទៅៗ ប៉ុន្តែខ្ញុំនិយាយកាត់ទៅអំមិញ វានិយាយអត់បាន--

[១០:៤១:០៩]

**ស៖** អរគុណលោក អរគុណ។ ឥឡូវ យើងចូលដល់ប្រធានបទមួយទៀត គឺថាអំមិញលោកបានបញ្ជាក់ថា លោកត្រូវគេឲ្យផ្លាស់ទីលំនៅពីកន្លែងព្រៃឈើទាល ទៅត្រាំពាំងចែង គឺថានៅតាមដំណាក់នៃការផ្លាស់ទីលំនៅហ្នឹង លោកត្រូវបាត់បង់អីដែរ? ហើយលោក ការឈឺចាប់របស់លោកព្យសនកម្មរបស់លោកយ៉ាងម៉េចដែរក្នុងពេលដែលផ្លាស់ទីលំនៅហ្នឹង? ហើយគេប្រាប់លោកថាម៉េច មុននឹងផ្លាស់ទៅ?

**ឆ៖** បាទ ពេលហ្នឹងគេផ្លាស់ឲ្យទៅហ្នឹង គេថាឲ្យយើងដូរទីលំនៅ ឲ្យជម្លៀសចេញទៅនៅខាងត្រពាំងចែង ហើយខ្ញុំថា "យី! ចុះវាទៅម៉េចទៅម៉ែ បើគោក្របីយើងនៅមួយសន្ទឹកនៅទីនេះ ហើយយកទៅយ៉ាងម៉េចទៅ?" ដល់ហើយបានឮបគេប្រាប់ថា "មិនបាច់យកទៅទេ ទុកនៅហ្នឹងហើយ យើងទៅតែ -- ទៅឯណោះមានច្រើនណោះហើយ តែរបស់អស់ហ្នឹងទុកនៅហ្នឹងហើយ។ ផ្ទះសម្បែង គោ របស់របរ ហើយនិយាយរួមទៅរបស់របរនៅផ្ទះប៉ុន្មាន គេអត់ឲ្យយកចេញទៅទាំងអស់ ឲ្យយកតែសម្ភារៈដែលថាយកទៅរួច"។

**ស៖** អរគុណលោក សារឿន។ ហើយពេលដែលលោកទៅ លោកដែលគេឲ្យមកមើលផ្ទះចាស់នោះវិញទេ? ហើយពីត្រពាំងចែងទៅព្រៃឈើទាល មានប្រហែលចម្ងាយប៉ុន្មានគីឡូពីគ្នាលោក?

[១០:៤២:៥៣]

**ឆ៖** បើនិយាយទៅពីព្រៃឈើទាលទៅត្រពាំងថែងនេះ ចម្ងាយប្រហែលជាបួនគីឡូ។ តែទៅនៅដល់ហ្នឹងហើយ គេអត់មានឲ្យមកក្រោយវិញទេ។ គេអត់មានបានឲ្យមកមើលភូមិចាស់ មកមើលស្អីៗហ្នឹងវិញអត់ទេ អត់មានបានមកទេ គេអត់ឲ្យមកទេ គិតតែខំធ្វើការ ដើម្បីបំពេញការងាររបស់បក្ស។

**ស៖** អរគុណលោក។ ហើយនៅក្នុងសហករណ៍ត្រពាំងថែង ពេលដែលលោកទៅដល់ លោកនៅក្នុងកងកុមារ ឬក៏នៅជាមួយឪពុកម្ដាយ -- នៅៗជាមួយម្ដាយ?

**ឆ៖** ពេលនោះ ខ្ញុំនៅកងកុមារ តែយប់ឡើងគេឲ្យមកសម្រាកនៅផ្ទះ ធ្វើការតាមកង តែនៅសម្រាកនៅផ្ទះយប់ឡើយ។ ពេលថ្ងៃអ៊ីចឹង ព្រលឹមឡើងចេញទៅធ្វើតាមកង។

**ស៖** តើការងារដែលលោកទទួលនៅក្នុងៗកងរបស់លោកមានអីខ្លះ? ហើយជាការងារធ្ងន់ធ្ងរ ឬក៏ជាការងារធម្មតា ដែលកុមារទូទៅទាំងអស់អាចធ្វើបាន?

[១០:៤៤:១៣]

**ឆ៖** ការងាររែកដីដំបូក។ ដីដំបូកហ្នឹងរែកដាក់ស្រែ ក្នុងអាពេលហ្នឹង គេឲ្យរែកក្នុង១ថ្ងៃហ្នឹង បើដំបូងធំ គេឲ្យតែមួយទេ គ្នាមួយកងហ្នឹង តែបើដំបូកធំ -- ដំបូងតូចគេឲ្យពីរ គេមើលតាមដំបូក ហើយបើអាចកាប់បានហើយ ថែមទៀតហើយក្នុងមួយកងកុមារខ្ញុំហ្នឹង គ្នាប្រហែលជាជាង១០នាក់ ១៥នាក់ ឬមួយ១៦-១៧ហ្នឹង តែប៉ុណ្ណឹងទេ។

**ស៖** អរគុណ លោក សារឿន ។ ប៉ុន្តែការងារដែលប្រគល់ឲ្យហ្នឹង លោកអាចក្រុមរបស់លោក កងរបស់លោក អាចបំពេញបានទេ ក្នុងការងារហ្នឹង ក្នុងការបរើដីដំបូងហ្នឹង? ហើយដីដំបូកហ្នឹង វាទន់ ឬក៏វារឹង?

**ឆ៖** សម្រេចបាន បើមិនបានក៏ត្រូវតែបានដែរ ព្រោះគេប្រាប់ថាឲ្យខំឲ្យបាន ត្រូវតែហើយ សម្រេចផែនការ។ ហើយដីដំបូកមិនមែនទន់ទេ។ គឺពាក្យថា ដីដំបូកនេះមិនមែនទន់ទេ រឹងណាស់ មិនមែនដីខ្សាច់ទេ។ កាប់ហើយបែកដៃ ពងជើងអស់ហើយ ហ្នឹងហើយដោយសារក្ដៅនៅកាប់ដី វាមិនមែនទន់ទេ ដីដំបូក សូម្បីតែអាត្រាក់ឈូសក៏វេទនាដែរ តែកម្លាំងនេះវាត្រូវតែធ្វើហើយពេលនេះ បើគេឲ្យសម្រេចផែនការហើយ បើៗយើងមិនធ្វើគេបង្អត់បាយយើង។ គេបង្អត់អាហារក្នុងមួយពេលហ្នឹង ឬមួយក៏គេដកតាម -- ដូចថា យើងធ្លាប់បានមួយចាន ដល់ពេលផុតពីមិនបានមួយចានទៅវិញហើយហ្នឹង បានតែកន្លះហើយ។ អ៊ីចឹងបានថាពិបាកណាស់ក្នុងពេលធ្វើការហ្នឹង បើយើងមិនខំគឺគេបង្អត់របបហ្នឹង បន្ថយរបបហ្នឹងបណ្ដោយ។

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

[១០:៤៦:១៥]

**ស៖** អរគុណលោក សារឿន។ ហើយចុះរបបហូបចុកគេឲ្យយ៉ាងម៉េចដែរ ចំពោះកុមារ? គេឲ្យហូបដូចនៅក្នុងកងរួម ឬក៏ហូបឯកជនម្នាក់ៗ?

**ឆ៖** ហូបតាមកងកុមារ គឺកងកុមារអ៊ីចឹង គឺគេដាក់តាមកងកុមារអ៊ីចឹង ហូបរួមហ្នឹង បាយ -- បបរៗប៊ុៗក្នុងហ្នឹង គេដួសចែកមួយផងៗ។

**ស៖** តើលោកហូបគ្រប់គ្រាន់ទេ? ចំពោះ បើប្រៀបធៀបនឹងការងារគេឲ្យរែីដីដំបូកហ្នឹង ហើយជាមួយបបរដែលគេឲ្យហ្នឹង តើវាគ្រប់គ្រាន់សម្រាប់ការងារហ្នឹងទេ? សម្រាប់កម្លាំងរបស់លោកទេ?

**ឆ៖** វាអត់សមទេ វាមិនសម ដូចយើងខំរែកដំបូក ខំធ្វើការ១ថ្ងៃៗមិនឈប់តាំងចាប់ពីម៉ោងប្រាំមួយទៅទល់ម៉ោងដប់មួយ, ចាប់ពីម៉ោងមួយទៅទល់ម៉ោងប្រាំ ហើយហូបបបរក្នុងមួយពេលមួយផង វាមិនអាចសមនឹងកម្លាំងដែលខំធ្វើហ្នឹងទេ។

**ស៖** អរគុណលោក សារឿន។ ខ្ញុំចង់សួរលោកដែរ នៅក្នុងកងកុមារហ្នឹងមានគ្រូដឹកនាំទេ មានអ្នកដឹកនាំទេ លោក សារឿន?

**ឆ៖** បាទ មាន។ មានគ្រូ មានអីហ្នឹង គេដឹកនាំសម្រាប់នាំយើងធ្វើការ តែគេឲ្យតែយើងខំធ្វើការ មិនដែលបានមានសាលាមានអីឯណា បានរៀនបានចេះដឹង អត់មាន។ មានតែនៅហ្នឹង ថ្ងៃណាមានទៅចំកន្លែងមានផ្ទះ អាហ្នឹងសម្រាកនៅផ្ទះទៅ ចំកន្លែងណាអត់ផ្ទះ ក្រោមដើមឈើគឺសម្រាកហ្នឹងសិន។

[១០:៤៨:៣៨]

**ស៖** អ៊ីចឹងគេអត់មានឲ្យរៀនអក្សរទេលោក គេឲ្យរៀនអីគេខ្លះទៅ?

**ឆ៖** គេឲ្យរៀនរែកដីដំបូក។ បើអត់មានឃើញបង្រៀនពីអក្សរផង គេប្រាប់ថាយើងបានមានគ្រូមានអ៊ីចឹងទៅ បានរៀនបានសូត្រ តែដល់ពេលចូលទៅជុំគ្នាទៅ វាមិនដែលឃើញមានសាលាមានអីឯណារៀនក្រោមដើមឈើដើមអីឯណា អត់ដែលឃើញ។ ឃើញតែយើងខំធ្វើការ ធ្វើការហើយហូបបាយ ហូបបាយហើយដល់ម៉ោងធ្វើការទៀត។

**ស៖** តើការឈឺចាប់របស់លោកយ៉ាងម៉េចដែរ? អារម្មណ៍របស់លោកក្នុងលោកជាអ្នកជាកុមារនៅពេលនុ៎ង លោកអត់បានរៀន អត់បានអី តើអារម្មណ៍ និងការឈឺចាប់របស់លោកកម្រិតណាដែរ?

**ឆ៖** និយាយពីរឿងអារម្មណ៍ វាសោកស្តាយ ដែលយើងវាល្ងង់ មិនចេះ ដោយសារមិនបានរៀនសូត្រពីជំនាន់ហ្នឹងមក ព្រោះខ្ញុំជាកុមារ។ តែអត់បានរៀនបានអីហ្នឹងគេ វាសោកស្តាយត្រង់ហ្នឹង មក

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ល្ងង់ទល់សព្វថ្ងៃហ្នឹង។

**ស៖** តើលោកឈឺចាប់ទេ ក្នុងសភាពហ្នឹង?

[១០:៥០:១៧]

**ឆ៖** បាទ ឈឺចាប់ វាឈឺចាប់នោះវាហួស វារកអីនិយាយលែងឃើញហើយ វាបើគិតទៅថា វាសោកស្ដាយវាគ្រប់វាសព្វ ណាមួយទៅវាបាត់បងបាត់ប្អូនគ្រប់សព្វ បាត់មា អ៊ំ មីង បង ឪពុកទាំងអស់ បើគិតទៅវា -- ហើយដល់មកពេលមិនបានរៀនមិនបានសូត្រ នៅតែពីរនាក់ម៉ែនិងកូន វាពិបាកដែរ។

**ស៖** អរគុណលោក។ ឥឡូវយើងឆ្លងទៅមួយគន្លាក់ទៀត គឺថាលោកបានបញ្ជាក់ថា លោកបានចេញពីត្រពាំងថែង ហើយគេមានឲ្យលោកផ្លាស់ទៅកន្លែងណាផ្សេងទៀតទេ?

**ឆ៖** បាទ មាន។ គេឲ្យខ្ញុំ ដល់ពេលហ្នឹង ធ្វើនៅធ្វើការហ្នឹង ដល់ពេលហើយអ៊ីចឹងទៅ គេបានប្រាប់ថា បងប្អូនយើងទៅនៅផ្លាស់កន្លែងហ្នឹងទៀតហើយ យើងទៅនៅកោះញ៉ែ ទៅអីហ្នឹងទៅវាមានកន្លែងទៅស៊ីបាយគេនៅហ្នឹងហើយ យើងនៅហូបបាយឯនេះគ្នាវាច្រើនពេក។ ហើយខ្ញុំក៏ហ្នឹងឃើញទៅម្ដងទៅនេះ ទៅម្ដងទៅនោះ រកកន្លែងគោលដៅមិនឃើញ ពីរនាក់ម៉ែនិងកូនហ្នឹង ចេះតែដើរស្ដាយតែអាខោអាវហ្នឹង គេឲ្យទៅត្រង់ណាទៅត្រង់ហ្នឹងហើយ។ ទៅៗដល់កោះញ៉ែហ្នឹង ទៅធ្វើការនៅហ្នឹងកោះញ៉ែហ្នឹងប្រហែលជាប្អូនគីឡូដីដែរទេ ដីវាទៅកន្លែងហ្នឹង។ ដល់តែពេលទៅនុ៎ងពីត្រពាំងថែងទៅហ្នឹង ទៅដល់ហ្នឹងមានឈ្លបមានអីគេ គេគ្រាន់តែនាំទៅ ទៅដល់ដាក់នៅនឹងផ្ទះហ្នឹងបានពីរបីថ្ងៃ ធ្វើការហ្នឹង។ គេឲ្យធ្វើដើរមើលទឹកមើលអីតាមស្រែហ្នឹង ធ្វើការបន្តហ្នឹងទាល់តែដល់ពេលផុតពីហ្នឹងទៅគេវាខ្វះអ្នកដឹកដំឡូង គេក៏ឲ្យខ្ញុំហ្នឹងជួយ ទៅជួយលើកដំឡូងដាក់រទេះពីព្រៃក្រឡាញ់មក។

[១០:៥២:០៧]

ខ្ញុំក៏ទៅៗដល់ចម្ការដំឡូងនុ៎ង ឈ្មោះគាត់ តាឌុង គាត់អ្នកនៅកាត់កាប់នៅកន្លែងហ្នឹង ចម្ការសៀង ចម្ការដំឡូងហ្នឹង។ ដល់តែពេលទៅដល់ហ្នឹងស្រាប់តែឮដំណឹងមួយផ្សេងទៀតហើយ។ ខ្ញុំក៏ពិបាក រឹតតែពិបាកឡើង គាត់ថាឥឡូវអ្អែងមក អ្អែងលើកដំឡូងហើយទៅ ចាំមកជួបមួយភ្លែត។ ឮសូរតែអ៊ីចឹងភ័យៗមិនដឹងជាគាត់ឲ្យទៅធ្វើអី ព្រោះគាត់ជានៅកន្លែងហ្នឹង ខ្ញុំវាភ័យខ្លាច។ ដល់ពេលខ្ញុំលើកដំឡូងហ្នឹងហើយ គាត់ហៅទៅក៏ដើរទៅ ដើរទៅដល់គាត់ប្រាប់ថា អ៊ំអ្អែង ហើយនិងឪអ្អែង ហើយនិងបងថ្លៃអ្អែងហ្នឹង អញឃើញគេដាក់ឡានទៅតាមប្រឡាយទៅជើងហើយ មិនដឹងទៅខាងណាទេ។ ឃើញចេញពីមន្ទីរក្រាំងតាចាន់ហើយ។ ខ្ញុំក៏ -- ដល់តែឮសូរអ៊ីចឹង ខ្ញុំក៏វាដូចជាស្លុត រកអីនិយាយជាមួយ

គាត់អត់ចេញ ក៏គាត់បានប្រាប់អ៊ីចឹង។ ខ្ញុំក៏មិនហ៊ាននិយាយអីជាមួយគាត់ ព្រោះគាត់ជាប្រធាននៅកន្លែងហ្នឹង វរៗគាត់និយាយទៅ គាត់ទាក់ទាញឲ្យខ្ញុំនិយាយពីរឿងថាខ្ញុំលបទៅកន្លែងមន្ទីរក្រាំងតាចាន់ហ្នឹង ហើយឬមួយយ៉ាងម៉េចមួយហ្នឹង វារឿងរឹតតែធំ។ អ៊ីចឹងខ្ញុំក៏មិនហ៊ាននិយាយ។

[១០:៥៣:២៥]

ក៏ខ្ញុំថា ខ្ញុំប្រញាប់ បើគោទឹមហើយៗខ្លាចវាបោលទៅកំពប់ដំឡូង ខ្ញុំក៏មកតោងអាគោហ្នឹងបរមកៗ។ គាត់ក៏ឈប់មាត់ឈប់ប្រាប់ខ្ញុំទៅ។ រហូតមកដល់ផ្ទះ ខ្ញុំក៏ប្រាប់ម៉ែ បររទេះមកៗដល់អាកន្លែងៗវត្តចាក់ជ្រុំហ្នឹងមានឈ្លបគេៗនៅចាំ គេខ្លាចខ្ញុំហ្នឹងលួចដំឡូងយកលាក់តាមផ្លូវតាមអីអ៊ីចឹង។ ខ្ញុំក៏ឃើញអ៊ីចឹងមកអាមួយរទេះនោះ គេដឹកយកទៅដាក់ត្រពាំងស្វាយទៅ បែងផ្លូវគ្នាត្រឹមហ្នឹង ហើយខ្ញុំអាររទេះហ្នឹងយកទៅដាក់ត្រពាំងចែង។ ហើយមួយរទេះទៀតហ្នឹងយកទៅដាក់វត្តបាខុង។ យកដាក់សហករណ៍តាមសហករណ៍ហ្នឹង។ ខ្ញុំក៏មកគេតាមដានខ្ញុំរហូតហ្នឹង យប់ឡើងខ្ញុំក៏ឆ្លៀតលួចប្រាប់ម៉ែថា តាឌុង គាត់ប្រាប់ថា ឪ គេបញ្ជូនចេញពីហ្នឹងទៅទៀតហើយ ប៉ុន្តែមិនដឹងជាទៅឯណាទេ។ ហើយម៉ែព្យួរអ៊ីចឹងគាត់ដេកតែយំៗតែទាំងខ្ញុំទាំងអីទាំងអស់គ្នាជាមួយគាត់ហ្នឹង។ ក៏គាត់យំអ៊ីចឹង ខ្ញុំក៏ថាមិនដឹងធ្វើយ៉ាងម៉េចបើគាត់ព្យួរ គាត់តែយំ។ គាត់មិនដឹងនិយាយប្រាប់ខ្ញុំថារបៀបម៉េច។ ដឹងថាទៅហ្នឹងដឹងតែស្លាប់ហើយ គ្មានរស់ទេ។ ហើយខ្ញុំក៏មិនជឿថា គាត់និយាយរបៀបហ្នឹងថា ហ្នឹងបើខ្ញុំទៅឃើញគាត់នៅក្រាំងតាចាន់ហើយ។ ហើយបើគាត់ថា ទៅទៀតក៏ខ្ញុំអត់ជឿដែរ ព្រោះខ្ញុំទៅឃើញច្បាស់នៅហ្នឹងហើយ ប៉ុន្តែគាត់ថាបង្វែងដានខ្ញុំ ថាឲ្យខ្ញុំនិយាយពីរឿងអីមួយហ្នឹង តែខ្ញុំមិនហ៊ាននិយាយ ខ្ញុំក៏បកមកវិញទៅ។

[១០:៥៤:៥៨]

ដល់ពេលខ្ញុំមកដល់ហ្នឹង ក៏និយាយប្រាប់ម៉ែខ្ញុំហើយ ក៏គឺថាទៅឈប់យើងការងារនៅត្រពាំងស្រង៉ែហ្នឹងឈប់ធ្វើហើយ គេឲ្យទៅជីកស្រះនៅវត្តបាខុង។ ទៅជួយជីកស្រះនៅហ្នឹង។ ខ្ញុំក៏ទៅហ្នឹងទៅទៅដល់ហ្នឹង នឹងឃើញថាទៅវត្តមានលោកដូចវត្តឯណោះអត់ ខ្ញុំចង់ដឹងដែរ ដល់ពេលទៅដល់ហ្នឹងពេលទៅដល់ស្ងាត់ឈឹង។ ឃើញតែស្រះគេបូមហើយ នៅក្រៀមៗហ្នឹង គេចាប់ផ្តើមវាស់ដីវាស់អីហ្នឹងចែកទៅ ម៉ាក្នុងបីនាក់ -- បីម៉ែត្រ បណ្តោយអ៊ីចឹងទៅគេឲ្យក្នុងម្នាក់ ហើយអាចាស់ៗហ្នឹង វា២ម៉ែត្រទទឹងអ៊ីចេះ បណ្តោយអ៊ីចេះបីជម្រៅប្រាំតឹក។ ដល់ពេលកាប់ហ្នឹងក៏ចេះតែកាប់ៗហ្នឹងទៅ ខ្ញុំចេះតែឆ្ងល់ចុះវត្តធ្លាប់មានលោកក៏ស្ងាត់ឈឹងអ៊ីចឹង ហើយព្រះវិហារហ្នឹងក៏ដឹងព្រះទៅឯណា បើអត់ឃើញ ឃើញតែវិហារទទេ។ ឆ្ងល់ ហើយវិហារនោះ វិហារធ្វើអំពីឈើ អត់ធ្វើអំពីថ្មទេ វិហារវត្តបាខុងហ្នឹង។

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

[១០:៥៥:៥៧]

ហើយអាកុដិអីក៏អត់ឃើញ ឃើញតែសាលាថ្មមួយនៅហ្នឹង ហើយឃើញឈ្លបឃើញអីគេនៅហ្នឹង។ មិនដឹងថា គេធ្វើម៉េច ខ្ញុំអត់ដឹងដែរ។ ហើយខ្ញុំចេះតែខំរែកដីហ្នឹង រែកៗទៅក៏រែកបាន១ថ្ងៃ បាន២ថ្ងៃផ្ទុះគ្រាប់ អាគ្រាប់ជំនាន់ លន់ នល់ បែបសល់បែបជ្រុះអីធ្លាក់មក ខ្ញុំមិនបានដឹងដែរ។ ចុះអាងតែកាប់ដីជីកស្រះ។ ដល់តែកាប់ទៅ វាផ្ទុះគ្រាប់ហ្នឹងរបួសពេញដៃ ពេញអីចឹងទៅក៏គេសែងយកទៅពេទ្យទៅ។ ខ្ញុំក៏ឃើញអីចឹងភ័យខ្លាចណាស់ ដឹងចំដែរឬអត់ទេ។ អីចឹងក៏ខំកាប់ចេះតែកាប់ចេះតែធ្វើហើយ ទ្រាំហើយ ឃើញខ្លាចចេះតែខ្លាចទៅ តែមិនដឹងធ្វើម៉េច។ ដល់ថ្ងៃមួយនោះ ចំម្ដាយមីងខ្ញុំ បាក់ដៃហ្នឹងខ្ទេចទៅ។ ផ្ទុះបាក់ចបបាក់អីហ្នឹងអស់ ខ្ញុំក៏ថាទៅជួយលើកគាត់ ជួយនេះគាត់ហ្នឹង ប្រឡាក់ឈាមពេញខ្លួនហើយ។ ដល់ពេលអីចឹងទៅក៏ថាជូនគាត់ទៅដែរ ទៅមើលគេយកទៅដាក់នៅកន្លែងណា។ ចុះបើបាត់គ្រប់កន្លែងពេក តែគេយកទៅទៀត មិនដឹងយកទៅចោលត្រង់ណាទៀត ចេះតែនឹកឃើញភ័យខ្លាចអីចឹង។ ក៏គេថាមិនបាច់ទៅទេ ពេទ្យគេមានហើយ យើងខំតែធ្វើការទៅ។ ក៏ខ្ញុំក៏មិនបានទៅ គេយកទៅពេទ្យ។ ដល់គេយកទៅពេទ្យអីចឹងទៅបានហ្នឹងក៏គាត់ជាមកវិញ។ មកវិញមក ស្រាប់តែមានបញ្ហាកើតឡើងទៀត។ គាត់ហ្នឹងកើតទាចទឹក ដល់កើតទាចទឹកហ្នឹង ១ថ្ងៃធំបន្តិចៗ ស្រាប់តែគេថាគាត់សីលធម៌។ គេហៅគាត់ទៅកសាង១ឆ្នាំ -- ១ថ្ងៃជា២ថ្ងៃៗអីចឹងចេះតែសួរបញ្ជាក់ថាសីលធម៌ ពេទ្យគេយកទៅពិនិត្យទៅអីហ្នឹង គេថានៅតែសីលធម៌។

[១០:៥៧:៤៧]

គាត់ហ្នឹងទៅឈរជើងនៅហ្នឹង១ឆ្នាំ អត់កើតកូនផង។ ដល់អត់កើតអីចឹងទៅ គាត់វា ទ្រាំតែគេដឹងថា គាត់កើតទាចទឹកមែនទែនហ្នឹង គាត់វាស្លាប់បាត់ទៅហើយ។ វាដល់ម៉ោងគាត់ វាទុំហើយ អាទាចទឹកហ្នឹង។ ក៏មក ដល់ពេលបាន១ឆ្នាំ ២ខែអត់កើត។ ដល់អត់កើត បានគេជឿជាក់ថា កើតទាចទឹកមែន។ វាមិនដែលកូនអាណាដល់១ឆ្នាំ២ខែអត់កើត។ ក៏គេឲ្យមកវិញ មកដល់ហ្នឹង គាត់ចេះតែរ៉ុំរ៉ៃៗដល់ហើយស្លាប់ទៅ។ វារកតែភស្តុតាងអត់ឃើញ វាអត់មានកំហុសអីទាំងអស់។ អាជំងឺហ្នឹង។

**ស៖** អរគុណលោក សារឿន។ លោក សារឿន ពេលដែលលោក សារឿន នៅកោះញ៉ែហ្នឹង តើពេលហ្នឹង លោកអត់នៅជាមួយម្ដាយទេ មែនទេ? គេអត់ឲ្យទៅផ្ទះមែនទេ?

**ឆ៖** ពេលហ្នឹងអត់បានទៅផ្ទះទេ។ ខ្ញុំហូបបាយនៅវត្ត -- នៅសហករណ៍បាខុងហ្នឹង។ គេឲ្យខ្ញុំទៅនៅលីញ៉ា នៅខាងត្បូងវត្តបាខុងហ្នឹងឆ្ងាយដែរ។

**ស៖** ហើយលោកដែលទៅជួបម្ដាយទេ? ហើយនឹកម្ដាយទេ ពេលដែលបែកពីម្ដាយបែបហ្នឹង?

**ឆ៖** ពេលហ្នឹង ខ្ញុំនឹក តែខ្ញុំលួចរត់ទៅ ពេលយប់អ៊ីចឹង ដែលគ្រូហ្នឹងអត់បាននៅទេ គេឲ្យតែប្រធានធំជាងគេហ្នឹង គេឲ្យនៅចាំ។ ពេលហ្នឹង ខ្ញុំនឹកម៉ែពេក ខ្ញុំរត់លួចរត់ទៅបីនាក់។ អាម៉ាច ហើយនិង អាអ៊ីម ហ្នឹង។ ក៏រត់ទៅ ប៉ុន្តែអាម៉ាច វានៅត្រពាំងស្វាយ ខ្ញុំនៅកោះញ៉ែ។ លួចរត់ទៅៗជួបគាត់។

[១០:៥៩:៣៨]

ទៅនឹកគាត់ ក្រែងលោបានទៅ។ បើបែកពីឪ ពីបងអស់ទៅ ខ្ញុំនឹកឃើញថាបានទៅជួបជាមួយម៉ែ គ្រាន់តែថាវាមិនសូវគិតច្រើនពេក។ ខ្ញុំចេះតែលួចរត់ទៅជួបគាត់ទៅ ហើយក្រែងលោគាត់មានអីហូប បើខ្ញុំនៅនេះខ្ញុំហូបអត់ឆ្អែត។ តែងតែទៅជួបគាត់អ៊ីចឹងទៅគាត់មានត្នោតទុំ មានអ៊ីចឹងទៅគាត់លួចលាក់ទុកឲ្យខ្ញុំហូប។ តែដល់យូរទៅ ខ្ញុំចេះតែនឹកឃើញទៅផ្ទះទៅក្រែងលោវាមានអីហូបអ៊ីចឹងទៅ ចេះតែទៅៗលួចរត់ទៅជួបគាត់ទៅ កុំឲ្យគាត់ពិបាកចិត្ត គាត់នៅម្នាក់ឯង។ ហើយពេលនោះ ខ្ញុំក៏ដើបឡើងរត់មកវិញ ធ្វើម៉េចមកឲ្យទាន់ពេលធ្វើការនៅកន្លែងកងហ្នឹងវិញ ព្រោះឆ្ងាយដែរ វាចម្ងាយបី -- ប្រហែលជាប្រាំបីគីឡូពីហ្នឹងមកកោះញ៉ែ។ ហើយដើរកាត់ព្រៃអាភូមិចាស់គេហ្នឹងអត់មានផ្ទះទេ។ គេរុះអស់ហើយ អាផ្ទះភូមិចាស់ធំៗហ្នឹង។

**ប្រធានអង្គជំនុំ៖**

បាទ បានហើយដើមបណ្ដឹងរដ្ឋប្បវេណី អស់ពេលហើយដើមបណ្ដឹងរដ្ឋប្បវេណី។

**លោកស្រី ជេត វណ្ណលី៖**

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញាមានអ្វីសាកសួរដល់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះដែរឬទេ? សូមផ្ដោតការយកចិត្តទុកដាក់តាំងសំណួរពាក់ព័ន្ធជាមួយនឹងស្ថានភាពទុក្ខសោកវេទនា និងព្យសនកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។ ព្រោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ យើងកោះអញ្ជើញគាត់ឲ្យមកថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា មិនមែនឲ្យមកឆ្លើយពាក់ព័ន្ធនឹងអង្គហេតុទូទៅជាចម្បងនោះទេ។

[១១:០១:៤៩]

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វ៉ាំងសង់ វ៉ាយស៍ ដេស្សាងឈ:**

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី តើលោកអាចប្រាប់ឈ្មោះសមាជិកគ្រួសាររបស់លោក ដែលបានបាត់ខ្លួន ឬក៏ត្រូវបានសម្លាប់នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យបានទេ? គឺមានន័យថា ឈ្មោះរបស់ឪពុកលោក ឈ្មោះបងប្អូន ឬក៏បងប្អូនថ្លៃ ឬក៏ឪពុកមា ឬក៏មីងជាដើម។

**លោក ប៊ុន សារឿន៖**

**ឆ៖** បាទ ជម្រាបបាន។ ឪពុកខ្ញុំឈ្មោះ ប៊ុន នាង ហ្នឹងគេយក -- ហើយនិង អ៊ំម៉ម ជាប្រធានភូមិ ហើយនិង អ៊ំអេង ខ្ញុំហ្នឹង មាស អេង ហ្នឹងជាប្រធានភូមិព្រៃឈើទាល។ ហើយ ពូរុន ហ្នឹងជាប្រធានក្រុមជាមួយឪខ្ញុំហ្នឹង ប៊ុន នាង ហ្នឹង។ ហើយ ប៊ុន នីម ជាព្រះសង្ឃ។ ហើយ មាស ណុប ត្រូវជាពូ។ មាស តឹក ហ្នឹងត្រូវជាមីង។ បងថ្លៃឈ្មោះ អ៊ុក។ ហើយបងប្រុសមួយទៀតឈ្មោះ នន -- ប៊ុន នន។

[១១:០៣:២៨]

**ស៖** សូមអរគុណ។ លោកអាចបញ្ជាក់បានទេ ថានៅពេលដែលឪពុករបស់លោក ប៊ុន នាង ហើយនិងពូ ហើយនិងប្អូនថ្លៃរបស់លោកនោះត្រូវបានចាប់ខ្លួន ហើយនិងបញ្ជូនទៅក្រាំងតាចាន់នោះ ថាតើមុនថ្ងៃទី១៧ <ខែមេសា ឆ្នាំ១៩៧៥> ឬក្រោយ<ពីពេលនោះទេ>?

**ឆ៖** ចាប់ទៅអាពេលបែកហ្នឹង។ ពេលបែកយើង ពួកគេហៅថាពួក១៧ៗទៅហ្នឹង។

**ស៖** សូមអរគុណ។ លោកបានឆ្លើយថា ឪពុកលោកមានតួនាទីនៅឃុំ ឬក៏នៅក្នុងភូមិគាត់ <។> ខ្ញុំ<ស្ដាប់យល់>ថា គាត់<ធ្វើជាប្រធាន។> តើត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវ។ គាត់ជាប្រធានភូមិនៅភូមិព្រៃឈើទាលហ្នឹង អ៊ំខ្ញុំហ្នឹង ហើយឪខ្ញុំជាប្រធានក្រុមជំនាន់ លន់ នល់ ហ្នឹង។

[១១:០៤:៥៥]

**ស៖** តាមរយ: តាឌុង ឬក៏អ្នកផ្សេងទៀត ឬក៏ តាវ៉ាន់ លោកមានដឹងទេថា ហេតុអ្វីបានជាឪពុករបស់លោក និងសមាជិកគ្រួសារផ្សេងទៀតរបស់លោកនោះ ត្រូវបានគេចាប់ខ្លួន?

**ឆ៖** ពេលដែលចាប់ទៅហ្នឹង គាត់បាន -- ផ្ទះគាត់វានៅជិតហ្នឹង គាត់បានចាប់ទៅហ្នឹង គាត់បានឃើញនៅកន្លែងមន្ទីរហ្នឹង គាត់មកប្រាប់ គ្រាន់តែប្រាប់ថាឃើញនៅក្នុងមន្ទីរហ្នឹង តែមិនដឹងជារឿង

អីហេតុអី គាត់អត់ដឹង គាត់គ្រាន់តែប្រាប់ថា ឃើញនៅក្នុងមន្ទីរហ្នឹង។ ពូរ៉ន គាត់ប្រាប់។

**ស៖** អម្បាញ់មិញនេះ លោកនិយាយអំពីការបង្អត់អាហារ នៅពេលដែលលោក<ធ្វើការមិនរួច>តាមការកំណត់បាន<។ ការងារនោះមាន>ដូចជាពេលដែលរែកដី<>ដំបូកជាដើម។ អ៊ីចឹងខ្ញុំចង់ដឹងថានៅឆ្នាំ១៩៧៨ នោះ តើគេមានបង្អត់អាហារលោកដោយសារមូលហេតុអ្វីផ្សេងក្រៅពីហ្នឹងទេ?

**ឆ៖** រឿងមានតែបង្អត់ បើយើងខំធ្វើការពេញលក្ខណៈដែលគេកំណត់ឲ្យហ្នឹង គេអត់ៗគេមិនបង្អត់យើងទេ។ តែបើសិនណាថាយើងធ្វើមិនហើយ គេត្រូវដកជីវភាពយើងក្នុងពាក់កណ្ដាលហើយ។ យើងធ្វើត្រូវតែហើយ សម្រេចផែនការណ៍របស់អង្គការ។

[១១:០៦:៤១]

**ស៖** សូមអរគុណ។ នៅក្នុងទម្រង់បែបបទព័ត៌មានរបស់លោក លោកថាឆ្នាំ១៩៧៨ លោកធ្វើការនៅសហករណ៍មួយផ្សេងទៀត<>គឺ <សហករណ៍>តា<គាំ> នៅ<ឃុំ>តាភេម ស្រុកត្រាំកក់ ហើយនៅពេលៗនោះ គេឲ្យៗលោកទៅឃ្វាលគោ។ តើព័ត៌មាននេះ ត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវ។ ពេលនោះ គេឲ្យខ្ញុំទៅដឹកមើលគោហ្នឹងរាកអាចម៍។ ដល់ពេលរាកអាចម៍ហ្នឹង គេបង្អត់បាយខ្ញុំ។ ហើយពេលដែលទៅដឹកអង្ករហ្នឹងបាត់អង្ករ មកវិញខ្ញុំវៃអាគោហ្នឹង វារូសអង្ករ។ ដល់រូសអង្ករទៅ គេបង្អត់បាយ គេពីរនាក់ គេឲ្យមួយនាក់ទេ។

**ស៖** ហេតុអ្វីបានជាទៅមើលគោ ហើយទៅជារាក ហើយបានជាគេបង្អត់អាហារលោកទៅវិញ? តើខ្មែរក្រហម គេបាននិយាយអ្វីខ្លះពាក់ព័ន្ធនឹងចំណុចនេះ?

**ឆ៖** ខ្ញុំអត់បានដឹងពីរឿងហេតុហ្នឹងដែរ ព្រោះខ្ញុំវាអត់ដឹង។ ឃើញគោវាកអាចម៍ ស្មានថាគោវាស៊ីស្មៅខ្ចី វាប៉ះវារាកវាអី ខ្ញុំអត់ដឹង។ តែដល់ពេលឃើញរាកអ៊ីចឹងទៅ គេថាបើគោរាកអាចម៍ ម៉េចក៏មិនប្រាប់គេ។ ហើយខ្ញុំក៏មិនបានថា ចាប់អារម្មណ៍ថាគោហ្នឹងវាមានឈឺជំងឺអីៗ ខ្ញុំវាមិនដឹង ស្មានថាវាស៊ីស្មៅខ្ចី ហើយវារាក ខ្ញុំមិនដឹង។ ដល់តែពេលគេហៅខ្ញុំទៅសួរ ហើយទៅព្រមានអ៊ីចឹង ខ្ញុំវាដូចវាឆ្ងល់។

[១១:០៨:៣០]

**ស៖** សូមអរគុណ។ នេះជាប្រធានបទចុងក្រោយ។ ខ្ញុំបានស្ដាប់ឮប្រវត្តិរបស់លោក ខ្ញុំអានពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោក។ អ៊ីចឹងខ្ញុំចង់ដឹងថា តើគេធ្លាប់បញ្ជូនលោកទៅពោធិ៍សាត់ទេ ក្នុងរបបនោះ?

**ឆ៖** ពេលនុ៎ង អត់បានទៅទេ ខ្ញុំអត់បានទៅ។

**ស៖** ខ្ញុំនិយាយបែបនេះ ពីព្រោះថាមានឯកសារមួយដែល<ធ្វើឲ្យខ្ញុំឆ្ងល់ គឺឯកសារ>លេខ D22/1659 ហើយមាន អា និងបេ ដែលជាសង្ខេបជាភាសាអង់គ្លេស ដែលថាលោកបានទៅសហករណ៍មួយនៅខេត្តពោធិ៍សាត់ នៅឆ្នាំ១៩៧៧។ អ៊ីចឹង<តើលោកអាចបញ្ជាក់ថា>ព័ត៌មាននេះជាព័ត៌មានមិនត្រឹមត្រូវទេ<>?

**ឆ៖** បាទ មិនត្រឹមត្រូវទេ ព្រោះខ្ញុំទៅនៅពោធិ៍សាត់ តែដល់តែពេលហើយទៅអ៊ីចេះ វាធ្វើទៅដល់ពេលអាព័ត៌មានហ្នឹង មិនដឹងជាយ៉ាងម៉េច បានជាមានអានៅខេត្តពោធិ៍សាត់វិញ ព្រោះខ្ញុំអត់ដែលទៅទេ ខ្ញុំទើបតែទៅ៧៩ នេះហើយ។

[១១:១០:០០]

**ស៖** តើលោកមានបាន<>រៀនអក្សរទេ ក្រោយរបបហ្នឹងមក ឬក៏លោកមិន<បានរៀន ហើយលោកប្រើពាក្យហៅខ្លួនឯងថា "ល្ងង់" រហូតដល់>ថ្ងៃនេះ<>?

**ឆ៖** បាទ អត់ចេះទេ ខ្ញុំអត់បានចេះទេ អត់ចេះសរសេរចេះអីទេ បានត្រឹមម៉ាចេះមើលទៅៗវាត្រូវកន្លែងណាដាច់ៗកន្លែងណាអត់ដាច់ ព្រោះខ្ញុំរៀនបានតិច ខ្ញុំនៅរៀនជាមួយលោក លោកបងខ្ញុំគាត់បង្រៀននៅវត្តហ្នឹង បានខ្ញីអត់បានដឹង អត់បានចេះ។

**ស៖** អ៊ីចឹងមិនដែលមានអ្នកណាម្នាក់ធ្លាប់អានឲ្យលោកស្ដាប់អំពីចម្លើយដែលថា លោកទៅពោធិ៍សាត់នៅឆ្នាំ<១៩៧៧> ហ្នឹងទេ ឬក៏លោកខ្លួនឯង<>មាន<>អាន<ឯកសារនោះដែរឬទេ? តើសុំឲ្យ>លោកផ្ដិតមេដៃនៅក្នុងឯកសារហ្នឹង<នៅពេលណា>?

**ឆ៖** ពេលហ្នឹង ខ្ញុំវាមានដែរ តែការងារហ្នឹង ខ្ញុំវានិយាយពីរឿងនៅក្រាំងតាចាន់ នៅខេត្តតាកែវ តែដល់ពេលដឹងថា ខ្ញុំនៅពោធិ៍សាត់អ៊ីចឹង វាទៅជាអ៊ីចឹងទៅ មិនដឹង ខ្ញុំអត់ដឹងដែរ ព្រោះគេឲ្យផ្ដិតមេដៃខ្ញុំចេះតែផ្ដិតទៅ ព្រោះខ្ញុំអត់ចេះ។ ខ្ញុំអត់មានបានដឹងថា គេអានឲ្យយើងស្ដាប់ម៉េចមួយៗទេ ខ្ញុំអត់បានដឹងផង។

[១១:១១:២៧]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោក។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅទៀតនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដី។

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ដំបូងគឺផ្តល់ទៅក្រុមមេធាវីការពារក្តីលោក នួន ជា ប្រសិនបើមានសំណួរអ្វីចង់សួរពាក់ព័ន្ធជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

[១១:១១:៥១]

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជម្រាបសួរលោកដើមបណ្តឹងរដ្ឋប្បវេណី។ លោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ <> តាការ៉ូ ជា<នរ>ណា លោកដើមបណ្តឹងរដ្ឋប្បវេណី?

**លោក ប៊ុន សារឿន៖**

**ឆ៖** តាការ៉ូ ហ្នឹង ខ្ញុំវាមិនដឹងជាគាត់ហ្នឹងការងារគាត់ខាងអីទេ ព្រោះគាត់អ្នកមកប្រាប់ថាឲ្យទៅរៀនសូត្រ។ គាត់ប្រាប់អ៊ីចឹង តែមិនដឹងជាគាត់ហ្នឹងមុខជំនាញគាត់ខាងអីដែរ ខ្ញុំមិនដឹងដែរ ព្រោះថាគាត់ មកដើរប្រាប់ហើយ គាត់អ្នកយកទៅដាក់នៅហ្នឹង ខ្ញុំមិនដឹងដែរ ហើយខ្ញុំវានៅតូចដែរ ខ្ញុំមិនសូវច្បាស់ដែរ ព្រោះវាខ្ញុំទើបអាយុ១១-១២ឆ្នាំហ្នឹង ខ្ញុំអត់បានចាំច្បាស់ទេ តែដល់តែពេលហ្នឹង គេថា តាការ៉ូហ្នឹងអ្នកដើរនាំយកទៅអ៊ីចឹងបណ្តោយ។

[១១:១៣:០០]

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី លោកទើបឆ្លើយទៅនឹងសំណួររបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធទៅនឹងការចាប់ខ្លួនឪពុក និងមាររបស់លោក។ នៅក្នុងទម្រង់បែបបទព័ត៌មានជនរងគ្រោះរបស់លោកៗនិយាយថា តាការ៉ូ ជាអ្នកចាប់ឪពុករបស់លោក និងចាប់អ្នកដទៃទៀតនៅក្នុងឆ្នាំ១៩៧៣។ សូមលោកបញ្ជាក់ជូនអង្គជំនុំជម្រះផងថា តើ<តាការ៉ូហ្នឹង>ចាប់ឪពុករបស់លោក<>នៅក្នុងឆ្នាំ១៩៧៣ ឬក៏នៅក្នុងឆ្នាំ១៩៧៥<>?

**ឆ៖** ពេលហ្នឹងវាឆ្នាំហ្នឹង វាចុងឆ្នាំ៧៣ហើយ តែវានៅក្នុងរបបហ្នឹង គឺរំដោះមុន។ រំដោះពីត្រឹមអង្គតាសោមមកលិច។ ហើយខាងហ្នឹងនៅលើរដ្ឋអំណាចនៅលើខាងគាត់ហ្នឹងកាន់កាប់ហើយ។

**ស៖** <លោកនិយាយថានៅចុងឆ្នាំ>១៩៧៣ហ្នឹង <>តើគេចាប់ខ្លួនគាត់នៅ<ថ្ងៃខែណាក្នុងឆ្នាំ១៩៧៣ហ្នឹង>?

01086775



**ឆ៖** គេចាប់ទៅហ្នឹង ខ្ញុំមិនដឹងថាគាត់យកទៅថ្មើរណាទេ តែខ្ញុំទៅឃើញគាត់ដើរនៅឯវត្តឯណោះ។ ក្នុងឆ្នាំ ចុងឆ្នាំ ចូល៧៤ហើយ។

**ស៖** ខ្ញុំសូមសួរបញ្ជាក់ថា លោកថានៅចុងឆ្នាំ១៩៧៣។ ឥឡូវនេះ<>លោកនិយាយថា ចុងឆ្នាំ ១៩៧៤ អ៊ីចឹង?

[១១:១៥:០៥]

**ឆ៖** មិនមែនចុងឆ្នាំ៧៤ទេ ដើមឆ្នាំ៧៤ និងចុងឆ្នាំ៧៣ហ្នឹង។

**ស៖** លោកក៏បានឆ្លើយផងដែរថានៅពេលមួយនោះ លោកបានឃើញឪពុករបស់លោកហ្នឹង កំពុងធ្វើការនៅកន្លែងមួយហៅថា ក្រាំងតាចាន់។ តើវាមានរយៈពេលប៉ុន្មានថ្ងៃដែរ ចាប់ពីពេលដែលគេចាប់ខ្លួនឪពុករបស់លោកដល់ពេលដែលលោកបានឃើញគាត់?

**ឆ៖** ពេលទៅហ្នឹង គាត់ទៅនៅហ្នឹងទាំងពីហ្នឹងមកដល់ទល់៧៥ បានខ្ញុំដឹងដំណឹងគាត់។ ពេលរំដោះហើយហ្នឹងពេញលេញហើយ។ ពេលយកអ្នកពីភ្នំពេញពីអីទៅហ្នឹង ខ្ញុំគេជម្លៀសខ្ញុំទៅនៅត្រពាំងចែងហ្នឹងបានដឹង។

**ស៖** សំណួររបស់ខ្ញុំគឺអ៊ីចេះលោក ថាតើលោកអាចប្រាប់ជូនអង្គជំនុំជម្រះ តើមានរយៈពេលប៉ុន្មានថ្ងៃ ប៉ុន្មានសប្តាហ៍ ប៉ុន្មានខែ ចន្លោះពីពេលគេចាប់ខ្លួនឪពុករបស់លោក និងថ្ងៃដែលលោកបានឃើញឪពុករបស់លោក<ធ្វើអី>នៅឯក្រាំងតាចាន់?

[១១:១៦:៤៤]

**ឆ៖** ខ្ញុំអត់បានចាំដែរលោក ព្រោះដល់តែពេលយើងចិត -- ពេលដែលរំដោះ ១៧ ទៅពីភ្នំពេញទៅពីអីទៅហ្នឹង បានខ្ញុំដឹងដំណឹង។

**ស៖** តើលោកចង់និយាយថាម៉េច ពេលថា "លោកដឹងដំណឹងអំពីឪពុករបស់លោក"<?> ខ្ញុំគិតថា លោក<និយាយថាលោក>បានឃើញគាត់?

**ឆ៖** ពេលនោះ ខ្ញុំបានដឹងដំណឹងពី ពូវ៉ន គាត់ប្រាប់ខ្ញុំហ្នឹង។ បានខ្ញុំទៅឃើញគាត់នៅក្នុងមន្ទីរហ្នឹង។

**ស៖** បើសិនជាខ្ញុំប៉ាន់ប្រមាណជាតួលេខទៅ គឺថានៅពេលដែលលោកបានឃើញឪពុករបស់លោកហ្នឹង <>គឺ<>ត្រូវបានគេឃុំខ្លួន<អស់ពេល>១ឆ្នាំកន្លះមកហើយ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ អ៊ីចឹងមែនហើយ។

**ស៖** សូមលោកជម្រាបជូនអង្គជំនុំជម្រះជាថ្មីម្តងទៀតថាតើ <>ពូរ៉ន បានដឹងថាឪពុករបស់លោកហ្នឹង គេឃុំនៅក្រាំងតាចាន់ហ្នឹងដោយរបៀបណា? តើ ពូរ៉ន បានដឹងដោយរបៀបណា?

[១១:១៨:២៥]

**ផ៖** ព្រោះផ្ទះគាត់នៅជាប់ហ្នឹង ចម្ងាយប្រហែលជា១០០ម៉ែត្រពីមន្ទីរ។ គាត់បានឃើញ ហើយគាត់មកប្រាប់ខ្ញុំ។

**ស៖** សូមលោកជម្រាបជូនអង្គជំនុំជម្រះ វាស្ថិតនៅប្រហែលជា១០០ម៉ែត្រ<តើនៅពី>ខាងជើង <ឬពីខាងត្បូង> ខាងកើត <ឬ>ខាងលិច<>?

**ផ៖** នៅពីខាងជើង ផ្ទះគាត់មានត្រពាំងទឹកមួយនៅពីខាងមុខផ្ទះ មានដើមដូងច្រើន។ ប៉ុន្តែផ្ទះហ្នឹងខ្ញុំវាមិនសូវច្បាស់ដែរ ព្រោះវានៅតូចដែរ ប៉ុន្តែឥឡូវវាខ្លាចខ្ញុំវាវង្វេងវាអីអាម៉េច មិនដឹងជើងមិនដឹងត្បូងទេ ប៉ុន្តែផ្ទះហ្នឹងវាមានពីរខ្នង តែផ្ទះហ្នឹងគឺចម្ងាយប្រហែលជា១០០ម៉ែត្រដែរ ប៉ុន្តែខ្លាចវាភ្លេចវាភ្លាំងអីទៅ វាយូរដែរហើយ ខ្ញុំវាមិនសូវបានទៅហ្នឹងញឹកញាប់ យូរៗទៅម្តង។ ដល់ទៅអ៊ីចឹងទៅខ្លាចឃើញថាខាងជើងទៅ ឬមួយក៏វាម៉េចមួយទេ ព្រោះផ្ទះហ្នឹងវាចម្ងាយប្រហែលប៉ុណ្ណឹងឯង។

[១១:១៩:៥២]

**ស៖** តើលោកកំពុងតែនិយាយថាផ្ទះ តារ៉ន ហ្នឹង គឺ១០០ម៉ែត្រចេញពីអគារគុក<ដែលអ្នកទោសស្នាក់នៅ> ឬក៏វាមានចម្ងាយ១០០ម៉ែត្រចេញពីរបង<ខាងក្រៅ>គុកក្រាំងតាចាន់?

**ផ៖** បាទ ។

**ស៖** តើសំណួរខ្ញុំសួរថា តើផ្ទះនោះវាស្ថិតនៅ១០០ម៉ែត្រពីអគារឃុំអ្នកទោស ឬក៏១០០ម៉ែត្រពីរបងគុក?

**ផ៖** ពីរបងគុក ចម្ងាយពីរបងគុកមកផ្ទះគាត់ ១០០ម៉ែត្រ ជាង១០០ម៉ែត្រទៅ បើស្មានទៅវាមិន -- វាការស្មានវាមិនអាចដូចយើងវាស់។

**ស៖** តើលោកអាចមើលឃើញផ្ទាល់ភ្នែកទេ មើលឃើញអគារដែលគេឃុំអ្នកទោស<ដែរឬទេ>?

**ផ៖** បាទ មើលឃើញខ្លះ មើលវាបាំងដើមឈើទាលដើមអី ដើមឈើទាលធំៗនៅកន្លែងហ្នឹងមានដើមឈើទាល មានជុំវិលហ្នឹង។ ហើយឃើញគាត់រែកទឹកហ្នឹង។

**ស៖** ខ្ញុំព្យាយាមស្វែងយល់ថាតើ មកដល់ថ្ងៃនេះអគារដែលលោកបានឃើញហ្នឹង គឺជាអគារ

ដែលគេហៅសព្វថ្ងៃនេះថាជាគុកក្រាំងតាចាន់។ តើលោកធ្វើម៉េចអាចដឹងថា អគារដែលលោកបានឃើញពេលនោះ ពិតជាអគារដែលគេហៅថាគុកក្រាំងតាចាន់?

[១១:២២:០១]

**ឆ៖** ខ្ញុំអត់បានដឹងថា កន្លែងហ្នឹងជាគុកជាអី ខ្ញុំអត់ដឹងដែរ ទាល់តែឮគាត់ប្រាប់ថា កន្លែងហ្នឹងគុក។ ខ្ញុំក៏ទៅៗបានឃើញអ៊ីចឹងទៅ។ ហើយខ្ញុំក៏វាមិនសូវដែលបានទៅញឹកញាប់ ទៅតែម្តងហ្នឹង។ ហើយគេប្រាប់ថាកន្លែងហ្នឹងជាគុក។ ខ្ញុំក៏មិនដឹងជាកន្លែងណា ជាកន្លែងមន្ទីរគេ កន្លែងណាជាទីគុក ខ្ញុំអត់ដឹង ព្រោះខ្ញុំមើលតែពីចម្ងាយ ខ្ញុំអត់បានចូលទៅ។

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណីលោកស្គាល់កន្លែងមួយនៅក្នុងខេត្តតាកែវ ហៅថាបូជនីយ-ស្ថាន<ឬ>កន្លែងគោរពបូជានៅក្រាំងតាចាន់<ដែរឬទេ>?

**ឆ៖** ខ្ញុំអត់បានដឹងដែរ។ ដឹងថាទៅហ្នឹង គេថាកន្លែងគុក ខ្ញុំវាមិនបានដឹងថាកន្លែងគេគោរពបូជាបូអី ខ្ញុំអត់ដែលដឹងដែរហ្នឹង។ ទើបតែឥឡូវនេះ ខ្ញុំទៅតាកែវហ្នឹងឮសួរបងស្រីខ្ញុំហ្នឹងគាត់ប្រាប់ថា កន្លែងហ្នឹងគាត់ទៅបង្សុកូលហ្នឹងពីរបីដងហើយ កន្លែងមន្ទីរឃុំឃាំងហ្នឹង កន្លែងគុកហ្នឹង គាត់ថាគាត់ទៅ។ តែខ្ញុំអត់ដែលបានទៅកន្លែងហ្នឹងទៀតទេ ទៅបានតែម្តងតាំងពីជំនាន់ហ្នឹងមក។

[១១:២៣:៤៤]

**ស៖** តើលោក<>ចាំទេ <ថាតើ> ពូរ៉ន <បានដឹងដោយរបៀបណា នៅពេលគាត់>ប្រាប់ថា អគារដែលលោកបានឃើញហ្នឹងគឺជា គុកក្រាំងតាចាន់? តើគាត់មានបានប្រាប់លោកថា គាត់ស្គាល់គុកក្រាំងតាចាន់ដោយរបៀបណាទេ?

**ឆ៖** ខ្ញុំអត់ដឹងដែរ មិនដឹងគាត់ដឹងពីម៉េចទេ ព្រោះគាត់ថាឃើញឪខ្ញុំនៅហ្នឹង គាត់ប្រាប់ថា កន្លែងនៅក្នុងគុក ឃើញមានអ្នកទោសអ៊ីចឹង គាត់ថាគុកទៅ។ បើខ្ញុំក៏ឃើញទៅឃើញអ៊ីចឹង ក៏ខ្ញុំថាគុកដែរ។

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណីដោយសារថាវាមានគុកច្រើន អ៊ីចឹងហើយបានជាខ្ញុំសួរថា អគារដែលលោកបានឃើញនៅពេលនោះពិតជាអគារគុកក្រាំងតាចាន់សព្វថ្ងៃនេះ ឬក៏អត់? លោកសូមផ្តល់មូលហេតុមើលថាតើហេតុអ្វីបានលោកគិតថា វាជាគុកក្រាំងតាចាន់ ឬក៏ដោយសារតែលោកឮឈ្មោះគុកក្រាំងតាចាន់នៅពេលក្រោយមកទេ?

**ឆ៖** ពេលហ្នឹង ខ្ញុំដឹងតាំងពីខ្ញុំទៅហ្នឹងនោះ។ បើគាត់ហៅថាគុកក្រាំងតាចាន់ បើគាត់ប្រាប់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អ៊ីចឹង ខ្ញុំឲ្យទៅប្រាប់លើសហ្នឹងម៉េចបាន។

**ស៖** ខ្ញុំនឹងចូលទៅប្រធានបទមួយទៀត ដែលជាប្រធានបទចុងក្រោយរបស់ខ្ញុំ។ ប្រសិនបើមិនខុសទេ គឺថាលោកមានអាយុ១២ឆ្នាំនៅក្នុងឆ្នាំ១៩៧៥។ តើពិតឬទេ?

**ឆ៖** ពេលហ្នឹងខ្ញុំអាយុ១១។ ១២ឆ្នាំ ខ្ញុំទៅនៅត្រពាំងថែងហើយ -- ទៅនៅកោះញ៉ែហើយ។

**ស៖** តើលោកបានទៅរៀនសូត្រនៅសាលាទេ នៅពេលដែលលោកមានអាយុ៦ឆ្នាំ, ៧ឆ្នាំ ឬក៏នៅអាយុណាមួយមុនដល់<អាយុ១១ ឬ>១២ឆ្នាំនុ៎ង?

**ឆ៖** ខ្ញុំអត់បានទេ ខ្ញុំនៅវត្ត នៅជាមួយលោកបង។ ខ្ញុំនៅតាមលោកបងរហូត។

**ស៖** ដូច្នេះនៅមុនឆ្នាំ១៩៧៥ លោកមិនបានទៅរៀនសូត្រនៅឯសាលាទេ។ តើត្រឹមត្រូវដែរទេ?

[១១:២៦:៣៩]

**ឆ៖** បាទ អត់បានទៅទេ ខ្ញុំនៅវត្ត នៅរៀនជាមួយលោកបងខ្ញុំ ប៉ុន្តែវារៀនបានតិច វាមិនបានចេះដឹងច្រើន។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ ហេតុអ្វីបានជាលោក<>បន្ទោសទៅរបបខ្មែរក្រហម<ថាមិនបានផ្តល់ការអប់រំ ហេតុអ្វីក៏លោកមិនបន្ទោសរបបមុន>ឆ្នាំ១៩៧៥<ផងដែរទៅ>?

**ឆ៖** ព្រោះពេលហ្នឹង វាអត់បានរៀនបានសូត្រហ្នឹងមកពីវាសង្គ្រាមវាច្រើន។ បន្តិចសង្គ្រាមនេះ បន្តិចសង្គ្រាមនោះ ឮសូរតែបាញ់គ្នា ខ្ញុំអត់ហ៊ានទៅរៀន ខ្លាចគ្រាប់ផ្លោងត្រូវ ព្រោះសាលារៀន វានៅឯអង្គរកាងណោះ វាឆ្ងាយ។ ហើយម៉្លោះហើយ ខ្ញុំវាពិបាកដើររៀនសូត្រដែរ ម៉្លោះហើយវាខ្លាចគ្រាប់ខ្លាចអីអ៊ីចឹង ម៉្លោះហើយវាមិនបានរៀន។ ត្រូវទៅនៅជាមួយលោកបងនៅវត្ត។ បានរៀនបានតិចតួច។

ហើយមកសម័យហ្នឹង វាចំអាពេលដែលរដ្ឋអំណាច គាត់អ្នកកាន់កាប់ពេញលេញហើយ បានខ្ញុំបន្ទោសទៅខាងហ្នឹង។

**ស៖** តើលោកយល់ស្របជាមួយខ្ញុំ<ដែរឬទេ>ថា សង្គ្រាមក៏ជាមូលហេតុមួយដែលនាំឲ្យលោកមិនបានទៅរៀន<សូត្រផង>ដែរ<>?

[១១:២៨:៣៥]

**ឆ៖** បាទ ពិតមែន។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកដើមបណ្ដឹងរដ្ឋប្បវេណី។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណ លោកប្រធាន។ ក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន អត់មានសំណួរសម្រាប់សាក្សី -- ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះទេបាទ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះសូមអរគុណលោក ប៊ុន សារឿន។ ការថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មដែលលោកអះអាងថា លោកបានទទួលរងនៅក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យបានដល់ទីបញ្ចប់ហើយ។ លោកអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅវិញបានហើយ។ ហើយសូមលោកធ្វើដំណើរត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោក ប៊ុន សារឿន វិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅវិញបានហើយ។ ហើយលោក ឃួន -- លោក យន់ សារ៉ាត់ បុគ្គលិករបស់អង្គការ ធី.ភី.អូ អាចសម្រាកបានហើយ។

បាទឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយនៅរសៀលនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់សេចក្ដីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-256។ សូមភាគីនិងសាធារណជនជ្រាប។

អង្គជំនុំជម្រះបង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ ហើយនិងបង្គាប់ឱ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឱ្យបានមុនម៉ោងមួយនិងសាមសិបនាទី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:៣០ នាទី ដល់ម៉ោង ១៣:៣១ នាទី)*

[១៣:៣១:៤៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការតទៅនេះ អង្គជំនុំជម្រះធ្វើសវនាការស្ដាប់សេចក្ដីរៀបរាប់ទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-256។

មន្ត្រីរដ្ឋបាលតុលាការអញ្ជើញដើមបណ្ដឹងរដ្ឋប្បវេណីមកកាន់កន្លែងថ្លែងរៀបរាប់អំពីទុក្ខសោកវេទនានៅចំពោះមុខអង្គជំនុំជម្រះ។

*(ដើមបណ្ដឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្ដីលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី តើលោកលោកស្រីឈ្មោះអី?

**លោកស្រី អ៊ឹម វណ្ណៈ៖**

**ឆ៖** ចាស នាងខ្ញុំឈ្មោះ អ៊ឹម វណ្ណៈ លោកប្រធាន។

**ស៖** អរគុណលោកស្រី អ៊ឹម វណ្ណៈ។ តើលោកស្រីកើតនៅថ្ងៃខែឆ្នាំណា លោកស្រីចាំដែរទេ?

**ឆ៖** ចាស ខ្ញុំកើតខែ១០ ឆ្នាំ១៩៦៧ លោកប្រធាន។

**ស៖** បាទអរគុណ ហើយសព្វថ្ងៃនេះលោកស្រីរស់នៅទីកន្លែងណា?

**ឆ៖** ខ្ញុំរស់នៅភូមិធ្នង់រលើង ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ។

**ស៖** បាទអរគុណ ហើយលោកស្រីប្រកបមុខរបររកស៊ីធ្វើអ្វីដែរ សព្វថ្ងៃនេះ?

**ឆ៖** ចាស ខ្ញុំធ្វើស្រែ លោកប្រធាន។

**ស៖** លោកស្រីអាចប្រាប់ដល់អង្គជំនុំជម្រះបានដែរទេ តើឪពុកបង្កើតរបស់លោកស្រីឈ្មោះអី ហើយម្ដាយបង្កើតរបស់លោកស្រីគាត់ឈ្មោះអីដែរ?

**ឆ៖** ឪពុកបង្កើតរបស់នាងខ្ញុំឈ្មោះលោកតា អ៊ឹម ចក់ និងម្ដាយឈ្មោះ ណាន ប៉ែន។

**ស៖** ចុះប្ដីលោកស្រីវិញគាត់ឈ្មោះអី ហើយលោកស្រីមានកូនប៉ុន្មាននាក់?

**ឆ៖** ប្ដីរបស់ខ្ញុំឈ្មោះ នាង សុផន ខ្ញុំមានកូនប្អូននាក់។

[១៣:៣៥:០៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយលោកស្រី អ៊ឹម វណ្ណៈ ក្នុងនាមលោកស្រីជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងរឿងក្ដីនេះ អង្គជំនុំជម្រះផ្ដល់វេទិកាឲ្យទៅលោកស្រីអាចថ្លែងរៀបរាប់ប្រាប់ដល់អង្គសវនាការអំពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មដែលកើតមានចំពោះលោកស្រីជាអាទិ៍ ការខូចខាងផ្លូវចិត្តផ្លូវកាយ សម្ភារៈដែលជាព្យសនកម្មផ្ទាល់ខ្លួនដែលជាបច្ច័យដោយផ្ទាល់អំពីបទឧក្រិដ្ឋ និងបានកើតមានពិតប្រាកដដល់សព្វថ្ងៃនេះ ដែលនាំឲ្យលោកស្រីតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរឿងក្ដីនេះដែលពាក់ព័ន្ធជាមួយនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ទៅលើជនជាប់ចោទទាំងពីររូបគឺលោក នួន ជា និង ខៀវ សំផន ដែលបានប៉ះពាល់ផ្ទាល់ចំពោះលោកស្រីក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ គឺចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ៧៩។

ហើយជម្រាបភាគី និងសាធារណជនថា លោកស្រី ឆាយ ម៉ារីដែត ជាបុគ្គលិកអង្គការ ធី.ភី.អូ នៅអង្គុយក្បែរដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងអំឡុងពេលដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះថ្លែងរៀបរាប់អំពីសេចក្ដីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មរបស់ខ្លួន។ ហើយតាមសំណើរបស់ដើម -- របស់មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីដើម្បីសាកសួរអំពីស្ថានភាពព្យសនកម្ម និងទុក្ខសោកវេទនាទាំងឡាយដែលកើតមានចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។

សូមអញ្ជើញបាទ។

[១៣:៣៦:៤៨]

**លោក ហុង គឹមសួន៖**

បាទ សូមអរគុណលោកប្រធាន។ ជាដំបូងខ្ញុំបាទសូមគោរពលោកប្រធាន សូមគោរពលោកស្រីលោកចៅក្រមក្នុងសាលជំនុំជម្រះជាទីគោរព។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោក ហុង គឹមសួន៖**

**ស៖** ជម្រាបសួរអ្នកស្រី អ៊ឹម វណ្ណៈ! ខ្ញុំបាទឈ្មោះ ហុង គឹមសួន ជាមេធាវីតំណាងដើមបណ្ដឹង

រដ្ឋប្បវេណី មកពីអង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ហើយក៏ជាមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២ នេះផងដែរ។

ខ្ញុំសូមសួរបន្តិច អំមិញលោកស្រីទើបនឹងជម្រាបជូនលោកប្រធានថា ស្រុក -- ទីលំនៅបច្ចុប្បន្នអ្នកស្រីនោះរួចហើយ ឥឡូវនេះខ្ញុំចង់សួរថាតើទីលំនៅកំណើតរបស់អ្នកស្រីនៅភូមិឃុំស្រុក ខេត្តណាដែរ?

[១៣:៣៧:៣២]

**លោកស្រី អ៊ឹម វណ្ណៈ៖**

**ឆ៖** ចាស ទីលំនៅកំណើតរបស់នាងខ្ញុំ ភូមិផ្ទង់រលើង ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវដដែល។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមសួរបន្តិចថា មុនពេលដែលរបបកម្ពុជាប្រជាធិបតេយ្យ ឬរបបខ្មែរក្រហមចូលដល់ចូលកាន់កាប់ប្រទេសកម្ពុជាទាំងមូលហ្នឹង តើអ្នកស្រី និងក្រុមគ្រួសារហ្នឹងរស់នៅទីកន្លែងណាដែរ?

**ឆ៖** ចាស នាងខ្ញុំរស់នៅខេត្តតាកែវ។

**ស៖** លោកស្រីបញ្ជាក់បានទេ ខេត្តតាកែវហ្នឹង នៅចំណុចអី ទីប្រជុំជន ជាភូមិជាឃុំអីបានទេ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតបលោកស្រី អ៊ឹម វណ្ណៈ។

**លោកស្រី អ៊ឹម វណ្ណៈ៖**

**ឆ៖** ចាស នៅក្នុងទីរួមខេត្តតាកែវហ្នឹងតែម្ដង។

**សួរដោយលោក ហុង គឹមសួន៖**

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងនៅពេលដែលខាងក្រុមខ្មែរក្រហមចូលដល់ទីក្រុងតាកែវ តើក្រុមគ្រួសារអ្នកស្រីនៅរស់នៅកន្លែងហ្នឹង ឬក៏ទៅនៅកន្លែងផ្សេងទៀត? ហើយកន្លែងនោះជាកន្លែងណាដែរ?

**ឆ៖** ចាស ពេលខ្មែរក្រហមទៅដល់ ពួកនាងខ្ញុំក៏ដេញ -- ខ្មែរក្រហមក៏ដេញពួកនាងខ្ញុំហ្នឹងឲ្យចេញពីទីរួមខេត្តមកនៅធ្វើដំណើរដោយថ្មើរជើងមកនៅភូមិឈើទាល ស្រុកត្រាំកក់ ខេត្តតាកែវដែរ។

[១៣:៣៩:០៨]

**ស៖** បាទ អរគុណ។ អ្នកស្រីរស់នៅក្នុងភូមិឈើទាល ស្រុកត្រាំកក់ហ្នឹង មានផ្លាស់ប្តូរទីលំនៅទៅទីណាទៀតទេ?

**ឆ៖** ចាស ត្រូវបានមេកងខាងភូមិឈើទាលនោះជម្លៀសឲ្យមកភូមិអង្គនារាយណ៍ ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវដដែល។

**ស៖** អ្នកស្រីអាចជម្រាបជូនអង្គសវនាការបានទេ ថាពេលណាផ្លាស់ប្តូរទីលំនៅមកនៅខាងអង្គនារាយណ៍វិញ? ឆ្នាំណា?

**ឆ៖** ឆ្នាំពាក់កណ្តាល៧៥។

**ស៖** ហេតុអ្វីបានអ្នកស្រី និងក្រុមគ្រួសារមិនត្រឡប់ទៅនៅភូមិកំណើតវិញ?

**ឆ៖** ពីព្រោះពួកខ្ញុំ គេត្រូវកំណត់ឲ្យទៅនៅទីនោះ មិនអាចទៅនៅស្រុកកំណើតបានទេ។

**ស៖** បាទ សូមអរគុណ។ នៅពេលដែលអ្នកស្រីបានមករស់នៅអង្គនារាយណ៍ តើនៅពេលនោះអ្នកស្រីធ្វើអ្វី ឬក៏ខាងអាជ្ញាធរនៅតំបន់អ្នកស្រីរស់នៅហ្នឹងឲ្យអ្នកស្រីធ្វើអ្វីដែរ?

**ឆ៖** កាលពីខ្ញុំមកដល់ភូមិអង្គនារាយណ៍នោះ ខ្ញុំរស់នៅជុំឪពុកម្តាយបងប្អូន ក៏ប៉ុន្តែដល់តែឆ្នាំ១៩៧៦ហ្នឹង នាងខ្ញុំបានគេបញ្ជេញឲ្យទៅកងកុមារ កងចល័តកុមារនៅវត្តលាយបូរ។

**ស៖** អ្នកស្រីអាចជម្រាបជូនឲ្យច្បាស់ជាងហ្នឹងបានទេ ថាតើរបៀបនៃការឲ្យនៅកងកុមារនោះ តើកងចល័តកុមារ ឬក៏កងកុមារនៅក្នុងភូមិ ក្នុងសហករណ៍បាទ?

[១៣:៤១:១៩]

**ឆ៖** កងចល័តកុមារនោះមិនមែននៅសហករណ៍ទេ នៅដាច់ចេញដោយឡែក។ កងមានកងពីរកង កងទី១ កងទី២។ កងចល័តហ្នឹងគឺមនុស្សដែលធំបន្តិច អាយុចាប់ពី៨ទៅ៩ឆ្នាំហ្នឹងចូលកងចល័ត។

**ស៖** លោកស្រីអាចជម្រាបបានទេ អំពីរបៀបនៃការចូលកងចល័តហ្នឹង តើមកដោយការជ្រើសរើស ដោយស្ម័គ្រចិត្ត ឬក៏ឲ្យមកចូលដោយរបៀបណាដែរ?

**ឆ៖** ចាស មិនមែនស្ម័គ្រចិត្តទេ ពួកវាបង្ខំឲ្យតែយើងចេញមកនៅកង មិននៅផ្ទះបានទេ។

**ស៖** អ្នកស្រីនិយាយថា “ពួកនោះ ឬពួកវានោះ” តើអ្នកណាគេអ្នកដែលឲ្យអ្នកស្រីមកនៅកងចល័តកងកុមារ?

**ឆ៖** អ្នកដែលបង្ខំកុមារឲ្យពួកខ្ញុំចេញមកនោះឈ្មោះ តារិត មេភូមិ។

**ស៖** មេភូមិនោះឈ្មោះភូមិអី?

**ឆ៖** ឈ្មោះភូមិអង្គនារាយណ៍។

**ស៖** បាទ សូមម្តងទៀត។

**ឆ៖** មេភូមិនោះឈ្មោះ តាវិត នៅភូមិអង្គនារាយណ៍។

**ស៖** បាទ សូមអរគុណ។ ពេលដែលអ្នកស្រីត្រូវបានមេភូមិបញ្ជូនឲ្យមកនៅកងចល័តកុមារនោះ តើកងកុមារនោះនៅចំណុច ឬនៅភូមិឃុំ ឬតំបន់ ឬក៏ស្រុកអីដែរ?

**ឆ៖** នៅកងចល័តកុមារនោះគេហៅថា តំបន់ -- ស្រុក១០៥ តំបន់១៣។ នាងខ្ញុំចាំបានតែប៉ុណ្ណឹង។

[១៣:៤៣:២៩]

**ស៖** បើគិតមកដល់ឥឡូវនេះ តំបន់១៣ ឬស្រុក១០៥ហ្នឹងឈ្មោះជាសាមញ្ញខុសពីលេខហ្នឹងមាន អ្នកស្រីចាំបាន ឈ្មោះអីដែរ?

**ឆ៖** ចាស ឈ្មោះស្រុកត្រាំកក់។

**ស៖** បាទ សូមអរគុណ។ នៅពេលនោះកងកុមារ ឬក៏កងចល័តកុមារអ្នកស្រីហ្នឹងត្រូវបានគេឲ្យធ្វើការអីដែរ?

**ឆ៖** ចាស គេឲ្យពួកខ្ញុំទៅសែងដីប្រឡាយជាមួយកងនារី។

**ស៖** បាទ សូមអរគុណ។ អ្នកស្រីអាចរៀបរាប់បានទេ តើការរបៀបនៃការងារសែងដីហ្នឹងនៅចំណុចឈ្មោះអី ឬក៏គេហៅទំនប់ប្រឡាយឈ្មោះអី នៅតំបន់ ឬចំណុចណាដែរ?

**ឆ៖** ចាស គេឲ្យខ្ញុំទៅសែងដីប្រឡាយនោះនៅ គេហៅថា ប្រឡាយព្រៃធាតុ នៅឃុំលាយបូរហ្នឹងដែរ។

**ស៖** បាទ សូមអរគុណ។ អ្នកស្រីអាចរៀបរាប់បានទេ របៀបនៃការធ្វើការងារជីកប្រឡាយ ឬក៏លើកដីធ្វើទំនប់នៅកន្លែងនោះ? តើគេឲ្យអ្នកស្រីធ្វើរបៀបយ៉ាងម៉េច ឬក៏សែងដី កាប់ដី រែកដី ធ្វើយ៉ាងម៉េច សូមជម្រាបអង្គសវនាការបន្តិច?

[១៣:៤៥:១០]

**ឆ៖** ចាស គេឲ្យពួកខ្ញុំទៅជីក សែងដីប្រឡាយហ្នឹង ចាប់តាំងពីម៉ោងប្រាំមួយព្រឹករហូតដល់ម៉ោងដប់មួយកន្លះថ្ងៃត្រង់។ បើពួកខ្ញុំធ្វើមិនហើយ គេមិនឲ្យបាយហូបទេ ពីព្រោះគេដាក់កំណត់កុមារហ្នឹងឲ្យគ្នា១០នាក់ហ្នឹងឲ្យហើយដីចំនួន១០គូប១០ម៉ែត្រការ៉េហ្នឹង។ តែពួកខ្ញុំជួនកាលក៏ធ្វើហើយ ជួន

កាលក៏ធ្វើមិនហើយ។ បើកាលណាជួបប្រទះដីទន់ទៅ ពួកខ្ញុំក៏បានធ្វើក្នុង១ថ្ងៃទល់យប់ហ្នឹងហើយ។ បើថាដីរឹងទៅ កុមារខ្ញុំធ្វើមិនបានទេ។ បើធ្វើមិនបានគេមិនឱ្យបបរហូបទេ។

**ស៖** បាទ សូមអរគុណ។ សូមអ្នកស្រីបញ្ជាក់ឱ្យបានច្បាស់បន្តិច អំមិញអ្នកស្រីថា កុមារដែលអ្នកស្រីទៅធ្វើការលើកទំនប់ ឬក៏លើកដីហ្នឹង គេឱ្យធ្វើ១០ម៉ែត្រគូប។ តើគេកំណត់របៀបយ៉ាងម៉េច ប៉ុន្មាននាក់ ឬក៏ជាក្រុម ឬក៏ជាកងយ៉ាងម៉េចដែលឱ្យលើក១០ម៉ែត្រគូបនោះបាទ?

**ឆ៖** ចាស ក្នុងមួយក្រុមមានគ្នា១០នាក់។

**ស៖** បាទ សូមអរគុណ។ ចុះអ្នកស្រីថា បើពេលលើកមិនហើយ ឬក៏ពេលធ្វើហើយខ្លះ ធ្វើមិនហើយខ្លះអ៊ីចឹង គេអត់ឱ្យបាយ ឬបបរ។ គេឱ្យហូបបាយ ឬឱ្យហូបបបរ?

**ឆ៖** ចាស គេឱ្យហូបតែបបរប៉ុណ្ណោះ មិនមានបាយហូបទេ។

[១៣:៤៦:៥៦]

**ស៖** ម្ហូបអាហារដែលអ្នកស្រីទទួលនោះបានឆ្អែតទេ?

**ឆ៖** ចាស ហូបមិនដែលបានឆ្អែតទេ បបរតែមួយវែកសប៉ុណ្ណោះ។

**ស៖** បាទ សូមអរគុណ។ នៅពេលដែលអ្នកស្រីហូបអត់ឆ្អែត តើអ្នកស្រីមានស្អីដែលអាចយកមកបន្ថែមចំពោះការខ្វះខាតម្ហូបអាហារហ្នឹងទេ?

**ឆ៖** ចាស មាន ពួកក្មេងៗខ្ញុំកាលណាដែលស្រេកឃ្លានពេកដើរទៅក្បែរៗព្រៃហ្នឹង សុំគេទៅបត់ជើងធំ ហ្នឹងប៉ុន្តែការពិតមិនមែនបត់ជើងធំទេ ពួកខ្ញុំទៅបេះស្លឹកថ្នឹងបួតយកមកដាក់ហោប៉ៅលួចហូបពេលកាលណាដែលស្រេកឃ្លានពេក។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងខាងមេកើយ ឬក៏មេកង មេក្រុម គេអនុញ្ញាតឱ្យអ្នកស្រី រកអាហារបន្ថែមអ៊ីចឹងដែរទេ?

**ឆ៖** ចាស អត់មានទេ គេបើសិនជាគេដឹងក៏គេចាប់វ៉ៃធ្វើបាបដែរ។ លួចបេះហ្នឹងដោយសារតែកំបាំងភ្នែកគេ បានពួកខ្ញុំលួចបេះបាន។

**ស៖** ខ្ញុំសុំសួរអ្នកស្រីបន្តិច ពាក្យថា "បើគេឃើញគេហ្នឹងធ្វើបាប" ហ្នឹង។ អ្នកស្រីធ្លាប់ទទួលរងទុក្ខទារុណកម្មដោយសារកំហុសអ្វីខ្លះដែរទេ ក្នុងអំឡុងសម័យខ្មែរក្រហម ឬកម្ពុជាប្រជាធិបតេយ្យនោះ?

[១៣:៤៨:៤៨]

**ឆ៖** ចាស នាងខ្ញុំធ្លាប់រងទារុណកម្មវ៉ៃវាងកាយនាងខ្ញុំ ពីព្រោះនាងខ្ញុំដើរ ដូចថាសុំច្បាប់មកផ្ទះបានតែមួយដងទេក្នុង១ខែ តែនាងខ្ញុំនឹងរឭកឪពុកម្ដាយពេក នាងខ្ញុំលួចរត់មកក៏មាន គេចាប់បាន គេវាយធ្វើបាបទៅ។

**ស៖** អ្នកស្រីរៀបរាប់ឲ្យបានពិស្ដារបន្តិចបានទេ របៀបនៃការពាក្យថា "ធ្វើបាប ធ្វើទារុណ-កម្ម" របៀបយ៉ាងម៉េចដែរ?

**ឆ៖** ចាស គេវាយធ្វើបាប ធ្វើទារុណកម្មហ្នឹងមកពីគេបាត់យើងពីកង យប់ឡើងគេដើររាប់ចំនួនមនុស្ស បើសិនជាមិនឃើញយើងនៅកន្លែងនោះ យើងម៉ោងបីភ្លឺឡើង ឡើងទៅវិញ លួចរត់មកហើយ ម៉ោងបីភ្លឺឡើងទៅវិញ ទម្រាំដើរដល់កងវាម៉ោងប្រាំ។ ទៅដល់ហ្នឹង យើងមិនទាន់បានធ្វើការផងគេសួរយើងយប់មិញយើងទៅណា? ហើយឆ្លើយប្រាប់គេថា ខ្ញុំសុំមិត្តបង ខ្ញុំសុំទៅមើលម្ដាយខ្ញុំឈឺ។ តែគេថាយើងហ្នឹងចង់តែទៅផ្ទះ ទៅផ្ទះហ្នឹងមានបានអីមក ម៉ែឪហ្នឹងជួយស៊ីយើងបាន នៅធ្វើការជាមួយអង្គការទៅ។ ហើយយើង ពួកខ្ញុំហ្នឹងក៏ឮសូរសម្ដីគេនិយាយអ៊ីចឹង ពួកខ្ញុំក៏នឹងឃើញភិតភ័យក្នុងខ្លួន។ គេថា "ឥឡូវបើអ្នកណាមិនគោរពវិន័យ ចាប់វាចងវ៉ៃហើយ ចាំឲ្យវាទៅធ្វើការ"។ មេកងបញ្ជាអ៊ីចឹង ពួកកុមារទាំងអស់ហ្នឹង គេចាប់នាងខ្ញុំហ្នឹងចង ហើយវ៉ៃធ្វើបាបទៅ។

[១៣:៥០:២២]

**ស៖** មេកង ឬក៏អ្នកគ្រប់គ្រងហ្នឹងជាអ្នកណា? ជាមេភូមិ ឬក៏ជាឈ្លប ឬក៏ជាយោធា អ្នកស្រីអាចជម្រាបបានទេ?

**ឆ៖** ចាស មេកងហ្នឹងស្រីឈ្មោះ សារូ។

**ស៖** អរគុណ។ តើនៅពេលដែលគេចាប់អ្នកស្រីចងវាយធ្វើបាបហ្នឹង គេធ្វើយ៉ាងម៉េច? គេយកដំបងវ៉ៃ ឬក៏ទាត់ធាក់ ឬម៉េច អាចនិយាយពិស្ដារជាងហ្នឹងបានទេ?

**ឆ៖** ចាស ពេលគេចាប់នាងខ្ញុំវ៉ៃធ្វើបាបហ្នឹង ម្ដងជាពីរដង នាងខ្ញុំពុំទាន់មានជំងឺទេ។ ដល់តែពេលលើកទី៣ នាងខ្ញុំ គេវាយធ្វើបាបខ្លាំងពេក នាងខ្ញុំធ្លាក់ខ្លួនឈឺជាទម្ងន់។ ខ្ញុំឈឺគ្រុនក្ដៅៗយប់ៗអ៊ីចឹងថ្ងៃ -- យប់ក៏ក្ដៅ ថ្ងៃក៏ក្ដៅដែរ សុំគេឈប់ គេមិនឲ្យខ្ញុំឈប់ទេ តែខ្ញុំទៅសុំថ្នាំពេទ្យ មិនដែលបានថ្នាំពេទ្យទេ បានតែម្សៅដំឡូងមី។ ហើយខ្ញុំធ្លាប់ឮអ្នកម្ដាយខ្ញុំថា បើសិនជាឈឺឲ្យច្របាច់ស្លឹកស្ដៅហ្នឹងផឹកទៅព្រោះយើងគ្មានថ្នាំសង្កូវព្យាបាលទេកូន។ តែនាងខ្ញុំក៏ទៅបេះស្លឹកស្ដៅច្របាច់ផឹក។ តែទៅជួបប្រទះនឹងឈ្លបម្នាក់ថាក្មេងកុមារមិនធ្វើការ គេមករាយការណ៍ប្រាប់អង្គការៗចាប់នាងខ្ញុំចងភ្ជាប់នឹងដើមឈើ

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

ហើយនាំគ្នាវ៉ៃធ្វើបាបនាងខ្ញុំកុមារហ្នឹងចំនួន២០នាក់ ទាំងខ្លួនខ្ញុំមានជំងឺជាប់ខ្លួន។

[១៣:៥២:៣២]

មិនត្រឹមតែប៉ុណ្ណឹង វាមិនមែនវ៉ៃនឹងដៃទេ សូម្បីតែឫស្សីជាប់នឹងដែកគោល វាវ៉ៃនាងខ្ញុំមានស្លាកស្នាមលុះសព្វថ្ងៃ វ៉ៃកំភួនជើងខ្ញុំមុតហូរឈាម ចងនាងខ្ញុំសន្លប់នៅនឹងដើមឈើមិនដឹងខ្លួន។ គេចងខ្ញុំចោល១យប់ទល់ភ្លឺ។ លុះត្រាភ្លឺឡើង ខ្ញុំដឹងខ្លួនៗខ្ញុំហូរឈាមពេញខ្លួន។ ចាប់បោកក្បាលខ្ញុំនឹងដើមឈើ។ ពេលខ្ញុំឈឺចាប់ ខ្ញុំត្រូវការថ្នាក់ថ្នមអំពីឪពុកម្ដាយ តែរកឪពុកម្ដាយមិនឃើញ។ ពេលនោះស្រែកដង្ហោយហៅក៏គ្មានអ្នកណាមកជួយខ្ញុំៗមានតែម្នាក់ឯង គ្មានអ្នកណាមកជិតខ្ញុំទាំងអស់។ មើលទៅឃើញតែអ្នកធ្វើបាប។ ខ្ញុំរកអ្នកណាមិនឃើញ ខ្ញុំនឹងឃើញដល់ឪពុកម្ដាយ នឹងឃើញដល់បងប្រុសម្នាក់ ដែលគាត់បានជួយបីបាច់ថែរក្សាខ្ញុំ។ ខ្ញុំនៅដាច់ចេញពីឪពុកម្ដាយខ្ញុំ បងខ្ញុំនោះគាត់ប្រហែលជា១ខែ គាត់លួចមកមើលខ្ញុំម្ដង បានត្នោតទុំបានដំឡូងដុតមកផ្ញើខ្ញុំ ដាក់ហោប៉ៅខោ។ ពេលថ្ងៃត្រង់ លួចមកមើលខ្ញុំមួយភ្លែតៗ ដើម្បីយកមកឲ្យប្អូនហូប។ ហើយលួងលោមខ្ញុំកុំឲ្យខ្ញុំយំ កុំឲ្យខ្ញុំនិយាយអី ឲ្យខ្ញុំខំប្រឹងធ្វើការ ខ្លាចអង្គការយកទៅសម្លាប់ចោល "អូន ខំប្រឹងធ្វើការទៅ"។

[១៣:៥៤:១៨]

**ស៖** បាទ អរគុណ។ សូមចូលរួមសោកស្ដាយចំពោះអំពើដែលធ្វើលើអ្នកស្រី។ ចុះបងប្រុសដែលអ្នកស្រីថាបានមកជួយលួងលោម ឬក៏ផ្ដល់ម្ហូបអាហារខ្លះហ្នឹង គាត់នៅឯណាពេលហ្នឹង? ហើយគាត់ឈ្មោះអី?

**ឆ៖** ចាស បងប្រុស គាត់ឈ្មោះ អ៊ុម ម៉ាច ត្រូវបាន ប៉ុល ពត សម្លាប់បាត់ហើយ។

**ស៖** អ្នកស្រីអាចជម្រាបជូនអង្គជំនុំជម្រះបានសវនាការបានទេថា អ៊ុម ម៉ាច ជាបងប្រុសត្រូវបានខ្មែរក្រហមយកទៅសម្លាប់។ អ្នកស្រីដឹងរបៀបណា ឬក៏អាចជម្រាបជូនលើសពីនេះបានទេ?

**ឆ៖** ចាស នៅពេលនាងខ្ញុំដើររួចបានទៅធ្វើការនឹងគេ គាត់ក៏ -- ខ្ញុំក៏បានដំឡូងដុតមួយមើម ខ្ញុំលួចគេបានដំឡូងដុតមួយមើមហ្នឹង ខ្ញុំក៏ទៅរកគាត់ ពេលថ្ងៃបាយហើយថ្ងៃត្រង់ហ្នឹង។ ខ្ញុំនៅកងបៀតកន្លែងគាត់ធ្វើការហ្នឹង ខ្ញុំទៅរកគាត់។ ទៅរកគាត់ ទៅដល់សួរគេ ដើរអើតមើលកន្លែងគាត់ធ្វើការមិនឃើញគាត់ៗខ្ញុំក៏សួរគេអ្នកស្រុក អ្នកភូមិនៅជាមួយគាត់ហ្នឹងឈ្មោះ សុវណ្ណ សួរគេទៅថាឃើញបងប្រុសខ្ញុំទេ? គេថា គេហៅកេសខ្ញុំមកខ្សឹប គេថាកុំមាត់ឮពេក ចាំបងប្រាប់ថា បងប្រុសអូនឯង មេកងស្នើដាក់ឡានយកទៅបាត់ហើយ។ ខ្ញុំសួរគាត់ថា គេយកគាត់ទៅណា? គាត់ថាគាត់ក៏មិនដឹងដែរ ឃើញ

ដាក់ឡានមកលិចមក។

[១៣:៥៦:០៣]

**ស៖** បាទ សូមអរគុណ។ មកដល់ចំណុចនេះ ខ្ញុំចង់សួរអ្នកស្រីបន្តិចនៅក្នុងពាក្យបណ្តឹងរបស់អ្នកស្រី ឯកសារលេខ D22/86, ERN 00353455 ជាភាសាខ្មែរ និង ERN លេខ 00450336 ជាភាសាអង់គ្លេស ជាមួយនឹងឯកសារមួយទៀតគេហៅថាព័ត៌មានបន្ថែមគឺ D22/86a ERN 00579245 ជាភាសាខ្មែរ។ ខ្ញុំបាទមានតែមួយច្បាប់ជាភាសាខ្មែរ។

ចំណុចនេះ ខ្ញុំគ្រាន់តែចង់ប្រៀបធៀបបន្តិចថា ក្នុងពាក្យបណ្តឹងដែលអ្នកស្រីបានដាក់ពាក្យជាមួយនឹងអង្គការឌី.ស៊ី.ខេម នោះ ថាបងប្រុសអ្នកស្រីហ្នឹងបាត់ខ្លួន ឬក៏ត្រូវបានចាប់ខ្លួន ដោយសារមេកងគេស្នើ ឬក៏គេយកទៅដូចអ្នកស្រីមានរៀបរាប់អម្បាញ់មិញ។ តើអ្នកស្រីដឹងថា តើមូលហេតុយ៉ាងម៉េចទេ ដែលបាន ដែលត្រូវបានគេស្នើ ឬក៏គេចាប់យកទៅនោះ?

[១៣:៥៧:១៥]

**ឆ៖** ចាស ខ្ញុំបានសួរបងប្រុសឈ្មោះ សុវណ្ណ និងបងប្រុសម្នាក់ឈ្មោះ កិល ហ្នឹង គាត់ប្រាប់ខ្ញុំថា គេចាប់ខ្លួនគាត់ទៅហ្នឹង មកពីខ្ញុំសួរគាត់ថា គាត់មានកំហុសអី? គាត់ខ្សឹបប្រាប់ខ្ញុំថា កាលណោះគេបោកថាគាត់ហ្នឹង -- គេចោទប្រកាន់គាត់ថាគាត់ទៅបោកស្រូវយប់ៗហ្នឹង សង្កត់ដៃនារីនៅនឹងក្តារបោកស្រូវ ខុសសីលធម៌។ តែការពិតគាត់មិនមែនខុសសីលធម៌ទេ ពួកវាចេះតែចោទប្រកាន់ទៅលើគាត់។

**ស៖** បាទ អរគុណ។ អ៊ីចឹងនៅក្នុងពាក្យទម្រង់បែបបទព័ត៌មានបន្ថែម ដែលខ្ញុំជម្រាបជូនអំមិញនៅក្នុងឯកសារ D22/86a នៅក្នុងទំព័រ ERN 00579245 អ្នកស្រីបានបញ្ជាក់ថា "បងប្រុសអ្នកស្រីហ្នឹងត្រូវបានចាប់ខ្លួន ដោយសារគាត់ធ្វើជាអតីតទាហាន លន់ នល់"។ ម៉េចបានពាក្យពីរហ្នឹងខុសគ្នាទៅវិញ? សូមអ្នកស្រីជម្រាបអង្គសវនាការបន្តិចមើល?

**ឆ៖** ចាស ពេលនោះបានជានាងខ្ញុំមិនទាន់បានព័ត៌មានអំពីថា បងប្រុសនាងខ្ញុំធ្វើជាទាហាន លន់ នល់ នោះនាងខ្ញុំកាលពីមុនឮសួរថា គេថាបងប្រុសនាងខ្ញុំខុសសីលធម៌ សង្កត់ដៃនារីនៅនឹងក្តារ។ តែទើបតែនាងខ្ញុំដាក់ពាក្យបណ្តឹងហើយ អ្នកម្តាយខ្ញុំថា "កូនបងប្រុសរបស់កូនឯងមិនមែនខុសសីលធម៌ទេ បងប្រុសកូនឯងអតីតជាទាហាន លន់ នល់។ កូនដឹងទេ?" ដល់ពេលខ្ញុំធ្វើព័ត៌មានបន្ថែមនេះ ចុងក្រោយខ្ញុំដាក់ថាអ៊ីចឹង ព្រោះអតីតបងខ្ញុំជាទាហាន លន់ នល់។ ខ្ញុំដឹងពីរនាក់ម្តាយខ្ញុំប្រាប់ខ្ញុំថាអ៊ីចឹង។

[១៣:៥៩:១០]

**ស៖** អ៊ីចឹងថា កាលដែលអ្នកស្រីបានជម្រាបជូនខាងអង្គការ ឌី.ស៊ី.ខេម ធ្វើពាក្យទម្រង់បែបបទបណ្តឹងដំបូងហ្នឹង គឺបានដឹងដោយសារគេប្រាប់ថា គេចោទថាបងប្រុសអ្នកស្រីហ្នឹងខុសសីលធម៌ទេ តែក្រោយពេលដាក់ពាក្យហើយទើបម្តាយអ្នកស្រីប្រាប់ថា គឺដោយសារបងស្រីរបស់អ្នកស្រីធ្វើជាទាហាន។ អ៊ីចឹងមែនទេ?

**ឆ៖** ចាស អ្នកម្តាយរបស់ខ្ញុំអ្នកប្រាប់ហ្នឹង គាត់ថា គេតាមដានពីរឿងទាហានហ្នឹងយូរហើយ។ កូនឯងមិនដឹងទេ គេតាមដានបងកូនឯងយូរហើយពីរឿងទាហានហ្នឹង ប៉ុន្តែគេរកលេសចោទបងកូនឯងមិនបាន ប៉ុន្តែឥឡូវគេថា បងកូនឯងខុសសីលធម៌អ៊ីចឹងទៅ ដើម្បីយកសម្លាប់ ងាយស្រួលនឹងយកទៅសម្លាប់។

**ស៖** បាទ សូមអរគុណ។ ចំណុចមួយទៀតដែរ នៅក្នុងឯកសារពាក្យបណ្តឹងអ្នកស្រីដដែលដែលអ្នកស្រីបានប្រើពាក្យមួយថា "ប្រហែលជាគេយកបង អ៊ឹម ម៉ាច ហ្នឹង យកទៅដាក់នៅគុកក្រាំងតាចាន់"។ ក្នុងសម័យនោះ អ្នកស្រីស្គាល់គុកតាចាន់តែម្តង ឬក៏ពេលណាមួយដែលអ្នកស្រីស្គាល់ឬក៏ប្រហែលជាគុកក្រាំងតាចាន់នោះបាទ?

[១៤:០០:៣០]

**ឆ៖** ចាស ពេលនោះ នាងខ្ញុំពុំស្គាល់ថា កន្លែងណាជាគុកក្រាំងតាចាន់ទេ។ ទើបតែបានអ្នកស្រុកគេមកពីស្រុកលើហ្នឹង គេនិយាយតៗគ្នាថា អ្នកដែលយើងទៅលិចហ្នឹង យកទៅដាក់គុកក្រាំងតាចាន់ហើយ។ បានខ្ញុំសន្និដ្ឋានថាបងខ្ញុំស្លាប់នៅគុកក្រាំងតាចាន់។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីនៅសល់១០នាទីទៀត រួមទាំងមាន ប្រសិនបើមានសំណួររបស់ដើមបណ្តឹងរដ្ឋប្បវេណីចំពោះជនជាប់ចោទតាមរយៈប្រធានអង្គជំនុំផងដែរ ១០នាទីនេះ។ សូមជ្រាប។

**លោក ហុង គីមសួន៖**

បាទ សូមអរគុណលោកប្រធាន ខ្ញុំបាទក៏បានតាំងម៉ោងខ្លាចហួសដែរ។ សូមអរគុណច្រើនលោកប្រធានបាទ។

**សួរដោយលោក ហុង គីមសួន៖**

**ស៖** អ៊ីចឹងខ្ញុំសូមសួរអ្នកស្រីទៀត ដោយសារយើងពេលវេលាក៏មានកំណត់។ ទាំងនេះគឺជាការដែលអ្នកដែលគេធ្លាប់ស្គាល់គុកក្រាំងតាចាន់ ឬក៏គេដឹងអំពីរបៀបដែលយើងមនុស្សទៅនៃជំនាន់ខ្មែរ-

ក្រហមហ្នឹង ទើបអ្នកស្រីបានប៉ាន់ប្រមាណតាមគេ អ៊ីចឹងអ្នកស្រី?

**លោកស្រី អ៊ឹម វណ្ណៈ៖**

**ឆ៖** ចាស ខ្ញុំឮសួរគេប្រាប់អ៊ីចឹង ខ្ញុំក៏នឹកឃើញថា បងខ្ញុំដឹកទៅតាមឡានទៅលិចហ្នឹងគ្មានកន្លែងគុកឯណាច្រើនជាងហ្នឹងទេ។ បើគេថាក្រាំងតាចាន់ គឺបងប្រុសខ្ញុំប្រហែលជាស្លាប់នៅទីនោះ។ ខ្ញុំរាល់ពេលរដូវភ្ជុំបិណ្ឌចូលឆ្នាំ ខ្ញុំទៅធ្វើបុណ្យឧទ្ទិសកុសលឲ្យគាត់ និមន្តលោកបង្សុកូលឲ្យគាត់រៀងរាល់ឆ្នាំ ១ឆ្នាំពីរដង។

**សៈ** បាទ អរគុណ។ ខ្ញុំសូមសួរអ្នកស្រីមួយទៀត ទាក់ទងជាមួយនឹងក្នុងប្រវត្តិនៃការរស់នៅរបស់លោកស្រីថា បានត្រូវបានខាងមេកងប្រើឲ្យអ្នកស្រីហ្នឹងទៅកាប់ដើមទន្រ្ទានខែត្រ ទៅរើសអាចម៍គោ ទៅកាប់ដីដំបូកជាដើម។ អ៊ីចឹងនៅក្នុងអំឡុងឆ្នាំណាដែលអ្នកស្រីបានត្រូវផ្លាស់ប្តូរការងារពីលើកទំនប់ ឬក៏ជីកប្រឡាយ ហើយទៅកាប់ទន្រ្ទានខែត្រវិញនោះបាទ?

[១៤:០២:៤៤]

**ឆ៖** ចាស នៅឆ្នាំ៧៧ ចុងឆ្នាំ៧៧ នាងខ្ញុំទៅកាប់ទន្រ្ទានខែត្រ។ ក្នុង១ថ្ងៃគេឲ្យកាប់ឲ្យបានប្រាំបីបាច់ បើមិនបានដូចការកំណត់របស់ប្រធានកង គេមិនឲ្យហូបបបរទេ។ ហើយបើកាប់ បើរើសអាចម៍គោ ឲ្យរើសឲ្យបានបីបាវឆ្នូត បើរើសមិនបានគេមិនឲ្យហូបបាយដែរ។ តែនាងខ្ញុំរើសមិនបានគ្រប់កំណត់រាល់ថ្ងៃទេ។ ថ្ងៃណានាងខ្ញុំមានអាចម៍គោរើសក៏រើសបានទៅ បើរើសមិនបាននាងខ្ញុំទៅលួចនៅនឹងកន្លែងតាៗគាត់ចិញ្ចឹមគោ ទើបខ្ញុំរួចខ្លួនបានបបរហូប។

**សៈ** បាទ ខ្ញុំសូមសួរអ្នកស្រីទាក់ទងជាមួយនឹងពេលវេលានៃការធ្វើការងារជាកងកុមាររើសអាចម៍គោ ឬកាប់ទន្រ្ទានខែត្រ មាននៅក្នុងពាក្យបណ្តឹងដែលអ្នកស្រីបានជម្រាបជូនអ្នកយកព័ត៌មានថាពេលអ្នកស្រីរើសអាចម៍គោ ឬក៏ទៅកាប់ទន្រ្ទានខែត្រនោះ បានជួបព្រឹត្តិការណ៍មួយ ដែលឃើញពួកឈ្លបនាំមនុស្សទៅសម្លាប់នោះ។ តើយ៉ាងម៉េចដែរ អាចជម្រាបជូនបន្តិចបានទេ?

[១៤:០៤:០៥]

**ឆ៖** ចាស ខ្ញុំទៅរើស ទៅកាប់ទន្រ្ទានខែត្រនៅម្តុំវត្តឫស្សីទេព នៅភូមិច្រេស ឃុំរកាក្នុង។ នាងខ្ញុំឃើញឈ្លបចំនួនប្រាំពីរនាក់បណ្តើរមនុស្សចំនួន១៥នាក់។ ពួកខ្ញុំហ្នឹងមួយក្រុមហ្នឹង បំបែកជាពីរប្រាំនាក់ទៅចូលខាងនេះ ប្រាំនាក់ចូលខាងនោះ តែពួកខ្ញុំកាច់ទន្រ្ទានខែត្របានគ្រប់ចំនួនហើយ ពួកខ្ញុំក៏បបួលគ្នាចូលទៅបេះផ្លែរពាក់ទុំ។ ពេលនោះ ខ្ញុំឃើញឈ្លបបណ្តើរមនុស្សចាស់ មានកាន់គល់ឫស្សី។ គ្នាបីនាក់

កាន់គល់ឫស្សី គ្នាបួននាក់កាន់កាំភ្លើង ស្ពាយកាំភ្លើងនៅនឹងស្មា តែអ្នកស្ពាយកាំភ្លើងនោះរាងតូចៗទេ កាំភ្លើងចង់អូសដី។ ពួកខ្ញុំឃើញអ៊ីចឹង ពួកខ្ញុំភ័យខ្លាចណាស់ ខ្ញុំលាក់ខ្លួនក្នុងគុម្ពោតរពាក់ចំនួនប្រហែលជា២០ម៉ែត្រពីកន្លែងឈ្លបសម្លាប់មនុស្សនោះ។ ពួកខ្ញុំឃើញឈ្លប់ចាប់ម្តងម្នាក់ៗវាយក្បាលនឹងគល់ឫស្សី ស្រែកយំទ្រហឹងពេញទាំងព្រៃទាំងអស់។ ពួកខ្ញុំឃើញអ៊ីចឹងភ័យខ្លាំងណាស់ ខ្ញុំពួនក្រាបដល់ដីញាក់ ខ្ញុំភ័យពេក ខ្ញុំសន្លប់បាត់ស្មារតី។ កុមារទាំងបួននាក់នោះ ឃើញខ្ញុំសន្លប់ក៏នាំគ្នាច្របាច់ ហើយបិទមាត់ទាំងអស់គ្នាមិនហ៊ានស្រែកទេ ព្រោះខ្លាច បើសិនជាពួកវាឃើញខ្ញុំក៏វាសម្លាប់ពួកខ្ញុំចោលដែរ។ ឃើញឈាមបាចពាសពេញនឹងព្រៃឈើទាំងអស់។

[១៤:០៥:៣៦]

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំសូមសួរអ្នកស្រីទាក់ទងជាមួយនឹងការឈឺចាប់របស់អ្នកស្រីក្រោយពេលអ្នកស្រីរួចផុតពីរបបកម្ពុជាប្រជាធិបតេយ្យ ឬរបបខ្មែរក្រហមមក តើសុខភាពរបស់អ្នកស្រី ឬអារម្មណ៍របស់អ្នកស្រីយ៉ាងម៉េចដែរ?

**ឆ៖** ចាស ខ្លួនខ្ញុំសព្វថ្ងៃមានជំងឺជាប់ខ្លួនរហូត។ ខ្ញុំពុំបានរៀនសូត្រដូចគេឯងទេ នាងខ្ញុំរៀនបានតែត្រឹមថ្នាក់ទី៤ ទី៥ប៉ុណ្ណោះ ពីព្រោះនាងខ្ញុំមានជំងឺជាប់ខ្លួនផង ណាមួយឪពុកម្តាយចាស់ មិនបានរៀនសូត្រទេ។

**ស៖** បាទ អរគុណ។ ចុះចំពោះក្រុមគ្រួសារ អ្វីដែលអ្នកស្រីសោកស្តាយបំផុត ឬក៏នឹកចងចាំជានិច្ចនោះ តើអ្នកណាខ្លះបាទ?

**ឆ៖** ចាស ការនឹករឭកៗស្រលាញ់ទាំងអស់ ក៏ប៉ុន្តែធូន់ចិត្តជាងគេបងប្រុសម្នាក់ដែលគាត់ស្លាប់ទៅហ្នឹង គាត់ធ្លាប់យកលួចនេះលួចនោះគេយកមកឱ្យហូបរហូត គាត់មកសួរសុខទុក្ខខ្ញុំរហូតជាងបងប្អូនទាំងអស់។

[១៤:០៦:៥៧]

**ស៖** តើសព្វថ្ងៃនេះ អ្នកស្រីបានធូរស្រាលអំពីការនឹកនាដល់គាត់ ឬក៏មានអារម្មណ៍ធូរស្រាល ឬក៏នៅតែនឹកឃើញនៅតែឈឺចាប់ដែរទេ?

**ឆ៖** ចាស ខ្លួនខ្ញុំសព្វថ្ងៃនេះ ឲ្យតែខ្ញុំនឹកឃើញអំពីរឿងស្លាប់របស់បងប្រុសខ្ញុំ ហើយនិងធ្វើបាបរាងកាយខ្ញុំៗនឹកឃើញថ្មើរម៉ានប្រៀបដូចជាកើតថ្មីៗនៅនឹងភ្នែករបស់នាងខ្ញុំ។

**ស៖** បាទ ជាចុងក្រោយនេះ តើអ្នកស្រីមានជាសំណូមពរ ឬជាសំណួរអ្វីសម្រាប់លើកឡើងសួរ

ទៅកាន់ជនត្រូវចោទទេ? ប៉ុន្តែសំណូមពរ ឬសំណួរទាំងអស់នេះ គឺអ្នកស្រីសុំទៅតាមរយៈលោកប្រធាន ដើម្បីឲ្យលោកយកពាក្យសម្តីរបស់អ្នកស្រីនោះបន្តទៅទៀត។ តើមានទេ?

**ឆ៖** ចាស ខ្ញុំចង់ខ្ញុំសំណូមពរពីលោកប្រធានចាសចាស។ ចាស ខ្ញុំសូមសំណូមពរឲ្យលោកប្រធានជួយរកយុត្តិធម៌ដាក់ទោសអ្នកដែលសម្លាប់ខ្មែរគ្នាឯងហ្នឹងឲ្យដាក់គុកអស់មួយជីវិតលោកប្រធាន ហើយនាងខ្ញុំសូមសំណូមពរមួយទៀត សូមឲ្យមេធាវីរបស់ខ្ញុំជួយ ស្អីទេ ភ្លេចទៅ។

**ស៖** បាទ ដូចជាសំណង ឬក៏អ្វីចង់បាន តើយ៉ាងម៉េច?

**ឆ៖** សំណងៗតាម សំណងសមូហភាព និងសំណងផ្លូវចិត្ត។

**ស៖** មានជាសំណួរអ្វីផ្សេងទៀតទេ?

**ឆ៖** ចាស អត់មានទេ។

**លោក ហុង គឹមសួន៖**

បាទ សូមអរគុណលោកស្រីដែលបានរៀបរាប់អំពីទុក្ខសោកវេទនារបស់អ្នកស្រីបានជម្រាបជូនដល់អង្គសវនាការ។ សូមអរគុណ លោកប្រធាន ខ្ញុំបាទ សូមបញ្ចប់ប៉ុណ្ណេះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហព្រះរាជអាជ្ញា។ បាទតំណាងសហព្រះរាជអាជ្ញា សូមអញ្ជើញ។

**លោក ស្រ៊ា រតនៈ៖**

សូមគោរពលោកប្រធាន សូមគោរពអង្គសវនាការទាំងមូល ជម្រាបសួរលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ស្រ៊ា រតនៈ៖**

**ស៖** ខ្ញុំសូមសួរបញ្ជាក់លោកស្រីឡើងវិញ អំពីចំណុចចុងក្រោយដែលលោកស្រីជម្រាបជូនអង្គសវនាការមុននេះ ពាក់ព័ន្ធនឹងករណីដែលលោកស្រីទៅឃើញឈ្លបប្រាំពីរនាក់នាំអ្នកទោស -- នាំមនុស្ស ១៥នាក់ទៅសម្លាប់។ តើនៅពេលនោះអ្នកស្រីស្ថិតនៅក្នុងសហករណ៍ណា ស្ថិតនៅក្នុងកងចល័តណាមួយណាដែរបាទ?

[១៤:០៩:៥១]

**លោកស្រី អ៊ឹម វណ្ណៈ៖**

**ឆ៖** ចាស ខ្ញុំស្ថិតនៅកងចល័តនៅខាងកើតថ្នល់រទេះភ្លើងនៅក្នុងឃុំរកាក្នុង។

**ស៖** បានន័យថា នៅពេលនោះអ្នកស្រីដូរពីកងចល័តក្នុងភូមិនារាយណ៍ទៅក្នុងភូមិរកាក្នុងវិញ?

**ឆ៖** ចាស ខ្ញុំបានដូរពីក្នុងភូមិអង្គនារាយណ៍ហើយ ទៅភូមិរកាក្នុងម្តង ព្រោះទីនោះទន្រ្ទានខែត្រច្រើនម្ល៉ឹង។

**ស៖** លោកស្រីទៅតាមការចាត់តាំងមួយរយៈ ដើម្បីទៅកាត់ទន្រ្ទានខែត្រ ឬមួយក៏ត្រូវបានចាត់តាំងឲ្យនៅទីនោះជាកងចល័តពេញសិទ្ធិតែម្តង?

**ឆ៖** ចាស ខ្ញុំទៅនៅទីនោះជាកងចល័តពេញសិទ្ធិ។

**ស៖** ពី -- អ៊ីចឹងចន្លោះពីភូមិនារាយណ៍ទៅភូមិរកាក្នុងហ្នឹង តើមានចម្ងាយឆ្ងាយពីគ្នាប៉ុន្មានដែរ?

[១៤:១១:២១]

**ឆ៖** ប្រហែលជា៣០គីឡូដី។

**ស៖** ពាក់ព័ន្ធនឹងរបបអាហារនៅក្នុងកងចល័តដែលអ្នកស្រីបានលើកឡើងពីមុនដំបូងនោះ គឺពាក់ព័ន្ធនឹងបបរ តើអ្នកស្រីទទួលបានរបបអាហារជាបបរហ្នឹង បបរបែបម៉េចដែរបាទ?

**ឆ៖** ចាស បបរដែលខ្ញុំទទួលបានសព្វដងពេលដែលខ្ញុំនៅកងនោះ បបររាវខ្លះទៅ បបរខាប់ៗហ្នឹងខ្លះទៅ មិនមែនបានតែខាប់ៗរហូតទេ បបររាវទឹក និងហូបជាមួយសម្លព្រលឹត។

**ស៖** ចុះនៅពេលដែលធ្វើការមិនគ្រប់តាមលក្ខខណ្ឌ លោកស្រីបញ្ជាក់ថា អត់បានទទួលរបបអាហារ អត់បានទាល់តែសោះ ឬក៏ត្រូវបានកាត់បន្ថយ?

**ឆ៖** ចាស បបរនោះអត់បាន ក្នុង១ថ្ងៃហ្នឹងបានហូបតែថ្ងៃត្រង់ទេ ពេលល្ងាចគេអត់ឲ្យហូបទេ។ ត្រូវពួកខ្ញុំពេលណាដែលអត់ គេបង្អត់ហ្នឹង ខ្ញុំហេវពេកក៏ទៅលួចដំឡូងកន្លែងតាៗគាត់ដាំទៅ ជួនក៏ទៅឃើញតាៗនៅកន្លែងហ្នឹងក៏អត់ហ៊ានលួចដែរ បើគាត់ទៅបាត់ទៅក៏លួចដកដំឡូងហ្នឹងហូប មិនបានដំឡូងឆ្អិនទេ ហូបដំឡូងឆៅ។

**ស៖** ពាក់ព័ន្ធនឹងលក្ខខណ្ឌការងារ ម៉ោងពេលលោកស្រីបានបញ្ជាក់ជូនអង្គសវនាការមុននេះបន្តិច ថាធ្វើការពីម៉ោងប្រាំមួយព្រឹកដល់ម៉ោងដប់មួយកន្លះថ្ងៃត្រង់។ លោកស្រីធ្វើការតែមួយព្រឹកហ្នឹងឬក៏រសៀលមានការងារបន្ថែមទៀតដែរ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១៤:១៣:៤៣]

**ឆ៖** ពេលរសៀលខ្ញុំធ្វើការរហូតដល់ម៉ោងប្រាំកន្លះ។

**ស៖** ផុតអំពីនោះទៅ មានការងារពេលយប់ទេ?

**ឆ៖** ចាស ពេលយប់មានឲ្យកុមារមកកាប់រណ្ដៅដាំដូង។

**ស៖** តើការងារកាប់រណ្ដៅហ្នឹងមានលក្ខណៈបែបណាដែរ ចំពោះលោកស្រីផ្ទាល់?

**ឆ៖** ចាស ការកាប់រណ្ដៅដាំដូងនោះ វាមិនស្រួលទេ ពីព្រោះកុមារវាឲ្យកាប់តាំងពីម៉ោងប្រាំមួយរហូតដល់ម៉ោងដប់យប់ ឲ្យបានគ្រប់ចំនួន បើយើងកាប់មិនបាន វានៅបង្ខំយើងឲ្យយើងកាប់ទាល់តែបាន។ វាហួសកម្លាំងកុមារនឹងធ្វើ។ ពួកខ្ញុំនឿយហត់យ៉ាងណាក៏មិនប៉ានប្រកែកដែរ។

**ស៖** តើលោកស្រីទទួលការងាររបៀបនេះ ក្នុងរយៈពេលយូរប៉ុន្មានណាដែរ?

**ឆ៖** ចាស ខ្ញុំទទួលការកាប់រណ្ដៅនេះពេលយប់ហ្នឹង ក្នុង១ខែហ្នឹង ខ្វះតែពីរបីថ្ងៃទេ ចន្លោះដែលពួកនាងខ្ញុំមិនធ្វើ។

[១៤:១៥:៣៦]

**ស៖** នេះលោកស្រីសំដៅទៅលើកងចល័តនៅភូមិណាដែរ?

**ឆ៖** កងចល័តនៅកាលខ្ញុំជីកប្រឡាយនៅភូមិជ្រៃ។

**ស៖** ខ្ញុំៗចង់ជម្រាបសួរលោកស្រី គឺពាក់ព័ន្ធនឹងការងារពេលយប់ដែលលោកស្រីថាដាំ ជីករណ្ដៅដាំដូង។ តើលោកស្រីទទួលការងារពេលយប់នេះនៅសហករណ៍ណាមួយជាក់លាក់ ឬក៏ក្នុងអំឡុងពេលមួយរបបចាប់ពីឆ្នាំ ចាប់ពីថ្ងៃទី១៧ មេសា រហូតដល់ឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ៧៩ ហ្នឹងលោកស្រីទទួលការងារដូចៗគ្នានេះរហូត ឬមួយក៏មានលក្ខខណ្ឌការងារតែដាំ តែការដាំដូងពេលយប់នៅសហករណ៍ជាក់លាក់ណាមួយ?

**ឆ៖** ចាស ខ្ញុំគេឲ្យទៅកាប់រណ្ដៅដាំដូងហ្នឹងសហករណ៍បៀតភូមិជ្រៃហ្នឹងតែម្ដង។

**ស៖** ចុះក្រៅពីសហករណ៍ភូមិជ្រៃហ្នឹង តើមានលោកស្រីបានធ្វើការ លោកស្រីត្រូវបានតម្រូវឲ្យធ្វើការងារពេលយប់អីចឹងដែរឬទេ?

**ឆ៖** ចាស មានគេឲ្យមកផ្លាស់កងមកនៅម្តុំវត្តខ្នារ១ហ្នឹងគេឲ្យពួកខ្ញុំហ្នឹងកាប់រណ្ដៅ។ ពេលថ្ងៃកាប់ទន្រ្ទានខែត្រ រើសអាចម៍គោ រែកដីដំបូក។ ពេលយប់ឲ្យខ្ញុំមកកាប់រណ្ដៅដាំដូង និងចេកនៅវត្តខ្នារបៀតវត្ត នៅម្តុំវត្តខ្នារ។

**ស៖** អ៊ីចឹងជារួមទៅបានន័យថាការងារជាអចិន្ត្រៃយ៍ បានន័យថាការងារជារៀងរហូតមក គឺធ្វើលោកស្រីត្រូវធ្វើការទាំងថ្ងៃទាំងយប់។ អ៊ីចឹងមែនទេ?

[១៤:១៧:៥០]

**ឆ៖** ចាស ធ្វើទាំងថ្ងៃទាំងយប់។

**ស៖** ពាក់ព័ន្ធនឹងករណីមួយទៀត គឺនៅក្នុងកងចល័តដែលលោកស្រីបានបញ្ជាក់ជូនអង្គសវនាការមុននេះបន្តិចថា លោកស្រីត្រូវបានក្មេងនៅក្នុងកងជាមួយគ្នាចាប់ចង និងវ៉ៃដំ។ តើហេតុអ្វីបានជាកុមារទាំងនោះមានសិទ្ធិវ៉ៃដំលោកស្រី?

**ឆ៖** ចាស កុមារទាំងនោះមានសិទ្ធិវ៉ៃខ្ញុំហ្នឹង ពីព្រោះមេកងបញ្ជាឲ្យចាប់ចងវ៉ៃទៅ។ មេកងបញ្ជាឲ្យវ៉ៃ ត្រូវតែវ៉ៃ។

**ស៖** មានន័យថា យ៉ាងដូចម្ដេច? បានន័យថានៅក្នុងកងលោកស្រីហ្នឹង កុមារទាំងអស់ក្រៅពីលោកស្រីត្រូវតែមកវ៉ៃលោកស្រី នៅពេលទទួលបញ្ជាហ្នឹង?

**ឆ៖** កងកុមារខ្ញុំនោះចំនួន១០០នាក់ៗហ្នឹងមិនមែនវ៉ៃខ្ញុំទាំង ១០០នាក់ហ្នឹងទេ វ៉ៃខ្ញុំចំនួនប្រហែលជា២០នាក់ទេ។

**ស៖** ចុះហេតុអ្វីទើបលោកស្រីទទួលបានទទួលទណ្ឌកម្មបែបនេះ?

**ឆ៖** បានជាគេដាក់ទណ្ឌកម្មខ្ញុំបែបនេះ មកពីខ្ញុំសុំគេទៅផ្ទះគេមិនឲ្យទៅ ទៅមើលអ្នកម្ដាយឈឺគេមិនឲ្យទៅ ខ្ញុំក៏លួចរត់ទៅ។

**ស៖** តើលោកស្រីទទួលទណ្ឌកម្មបែបនេះ ញឹកញាប់ទេក្នុងអំឡុងពេលក្នុងរបបកម្ពុជាប្រជាធិបតេយ្យនេះ?

[១៤:១៩:៥៧]

**ឆ៖** ចាស ខ្ញុំទទួលទណ្ឌកម្មនេះញឹកញាប់ដែរ តែមិនមែនតែខ្ញុំម្នាក់ទេ កុមារទាំងអស់ក៏ទទួលដូចខ្ញុំអ៊ីចឹងដែរ មិនមែនទាំងអស់ទេ តែសឹងនឹងគ្រប់គ្នាទទួលដូចខ្ញុំអ៊ីចឹងដែរ គ្រាន់តែតិច និងខ្លាំង។

**ស៖** តើលោកស្រីអាចជម្រាបបានទេថា អ្នក២០នាក់ហ្នឹងជាៗកុមារប្រភេទអីដែរ ដែលមានសិទ្ធិដែលៗត្រូវបានគេចាត់តាំងឲ្យវាយដំ? ហើយកុមារប្រភេទអីដែរ ដែលត្រូវបានដែលគេដាក់ទណ្ឌកម្មឲ្យទទួលរងការវ៉ៃដំបែបនេះ?

**ឆ៖** ចាស កុមារមូលដ្ឋានមានសិទ្ធិវ៉ៃពួកអ្នក១៧ មេសា គឺអ្នកមូលដ្ឋាន។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** អ៊ីចឹងបានន័យថា កុមារផ្សេងទៀតដែលក្រៅពីលោកស្រី ហើយទទួលទណ្ឌកម្មបែបហ្នឹង ក៏សុទ្ធតែជាកុមារថ្មីៗដែរ អត់មានអ្នកមូលដ្ឋានទេ?

**ឆ៖** ចាស អត់មានអ្នកមូលដ្ឋានទេ។ អ្នកទទួលរងទារុណកម្មហ្នឹងសុទ្ធតែពួកថ្មីទាំងអស់ អត់មានពួកមូលដ្ឋានទេ។

[១៤:២១:២៤]

**ស៖** នៅក្នុងឯកសារ D22/86, ERN ភាសាខ្មែរ 00353456 ដល់ 57 និង ERN ជាភាសាអង់គ្លេស 00450337 លោកស្រីលើកឡើងថា កុមារប្រហែល១០នាក់ទៀតក៏រងគ្រោះដូចខ្ញុំដែរ ដោយសារតែស្អប់ និងគុំកួន។ តើមូលហេតុស្អប់ និងគុំកួននេះជាមូលហេតុចម្បងដែលនាំឲ្យទទួលទណ្ឌកម្ម ឬក៏មានមូលហេតុផ្សេង? ហើយតើគុំកួនក្នុងរូបភាពបែបណាដែរ?

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណី កុំអាល់ទាន់ឆ្លើយតប។ សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ យើងបានស្ដាប់ជិត<>៥៥នាទីហើយ ហើយខ្ញុំមើលនាឡិកាទៅ <។ តាមកាលវិភាគគឺថាយើង>នៅសល់ម្នាក់ទៀតនៅឡើយ។ <តើយើងនៅចំណាយពេល១០នាទីទៀតដើម្បី>សួរយកភស្តុតាង<តូចៗកំប៉ិកកំប៉ុក>តែប៉ុណ្ណោះ<ទៀតមែនទេ?> ដើមបណ្ដឹងរដ្ឋប្បវេណីបានឆ្លើយជាច្រើនចំណុច ហើយ<ប្រសិនបើសហព្រះរាជអាជ្ញាបន្តសួរបែបនេះទៀតនោះ>រយៈពេល ១០ ទៅ១៥នាទីខាងមុខទៀត<ក៏មិនចប់ដែរ ខ្ញុំដូចជារង្វេងហើយ>។

[១៤:២៣:១២]

<>អង្គជំនុំជម្រះ បានណែនាំចំនួនប្រាំពីរដងហើយ ទៅដល់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញាឲ្យផ្ដោតតែទៅលើផលប៉ះពាល់ ទៅលើជនរងគ្រោះ ក៏ប៉ុន្តែបែរទៅសួរលម្អិត ដើម្បីស្វែងរកភស្តុតាងទៅវិញ។ ដូច្នេះក្នុងរយៈពេល១០ ទៅ១៥នាទី មិនគួរសួរសំណួរបែបនេះតទៅទៀតទេ។ ដូច្នេះខ្ញុំគិតឃើញថា នេះមិនមែនជាវិធីមួយដែលសមស្របនៅក្នុងកិច្ចដំណើរការនីតិវិធីបែបនេះនោះទេ។

**លោក ស្រ៊ា រតនៈ៖**

សូមជម្រាប លោកប្រធាន នេះជាសំណួរចុងក្រោយបំផុតរបស់ខ្ញុំ។ នៅក្រោយពេលគាត់ឆ្លើយ

សំណួរនេះចប់ គឺខ្ញុំអស់សំណួរ បាទ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញបាទ។

[១៤:២៤:០១]

**សួរដោយលោក ស្រ៊ា រតនៈ៖**

**ស៖** ខ្ញុំសូមរំឭកសំណួរឡើងវិញថាតើអ្វីដែលខ្ញុំលើកឡើងអម្បាញ់មិញនេះ តើការស្អប់ និងគុំកួនហ្នឹងយ៉ាងដូចម្ដេចដែរ? មានន័យថាម៉េចគុំកួន ហើយនិងស្អប់ហ្នឹងបាទ?

**លោកស្រី អ៊ឹម វណ្ណៈ៖**

**ឆ៖** ចាស ពួកមូលដ្ឋានដែលស្អប់គុំកួនកុមារដូចគ្នានោះ មកពីពួកខ្ញុំជាអ្នកថ្មីហ្នឹងចូលកាលពី៧៣-៧៤ហ្នឹង ពួកនាងខ្ញុំអ្នកថ្មីហ្នឹង មានអ្នកខ្លះកូននាយទាហានជាន់ខ្ពស់អ៊ីចឹងទៅ អ្នកខ្លះកូនមេឃុំអ៊ីចឹងទៅ។ ដល់តែពេលពួកខ្ញុំបែកទៅចូលជាមួយពួកចាស់ឆ្នាំ១៩៧៥ហ្នឹង ពួកវាស្អប់ខ្ពើមពួកខ្ញុំថា ពួកខ្ញុំហ្នឹងពួកមីថ្មីសុទ្ធ មីថ្ពុតសី។ ឃើញពួកខ្ញុំហ្នឹង គឺវាឃើញមិនបានទេ ឃើញវាស្អប់គុំកួន វាថាឲ្យតែមានកំហុសអីបន្តិច វានឹងចាប់វាយធ្វើបាបហើយ។

[១៤:២៥:០៥]

**លោក ស្រ៊ា រតនៈ៖**

ខ្ញុំបាទអស់សំណួរហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះ ផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក នួន ជា។

**លោក វ៉ិចទ័រ កូប៉េ៖**

<សំណួររបស់>សហព្រះរាជអាជ្ញា គឺថាមិនចាំបាច់ឆ្លើយទៅនឹងសំណួរដែលយើងបានសួរទៅនោះទេ<។> តើយើងខ្ញុំនៅមានរយៈពេលតែ១០នាទី<?> តើខាងយើងខ្ញុំមានរយៈពេលប៉ុន្មានដែរ? បើសិនណាពេលខ្ញុំនៅសល់ពេលតែ១០នាទីទេ ខ្ញុំឈប់សួរហើយ អង្គុយចុះហើយ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកមេធាវី តើលោកត្រូវការពេលវេលាប៉ុន្មាន? សំណួរពាក់ព័ន្ធទៅនឹងចំណុចនេះ លោកត្រូវការពេលប៉ុន្មាន?

**លោក វិចទ័រ កូប៉េ៖**

ជាការអនុវត្តជាក់ស្តែង គឺយើងត្រូវសួរបញ្ហាដែលពាក់ព័ន្ធ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកត្រូវការប៉ុន្មាន?

**លោក វិចទ័រ កូប៉េ៖**

ខ្ញុំប្រហែលជាត្រូវការ៤៥នាទីដូចសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខដែរ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ចុះក្រុមមេធាវីការពារក្តីលោក ខៀវ សំផន?

**លោក គង់ សំអុន៖**

ខ្ញុំប្រហែលជាមានសំណួរបន្តិចបន្តួចទេ លោកប្រធាន។

[១៤:២៦:៤០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:២៧:៣២]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសម្រេចឱ្យផ្តល់ពេលវេលា៤០នាទី សម្រាប់ភាគីមេធាវីការពារក្តីទាំងពីរក្រុម។

**លោក វិចទ័រ កូប៉េ៖**

បាទ សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វិចទ័រ កូប៉េ៖**

**ស៖** ជម្រាបសួរលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំមានសំណួរមួយចំនួនសួរទៅកាន់លោកស្រី។ ដំបូងខ្ញុំសូមសួរលម្អិតអំពីមេកងរបស់លោក<ស្រី។ លោកស្រី>និយាយថា មេកងរបស់លោកស្រី<>ឈ្មោះ <សារ៉ូ>។

**លោកស្រី អ៊ឹម វណ្ណៈ៖**

**ឆ៖** ចាស មេកងរបស់ខ្ញុំមិនមែនឈ្មោះ សារុន ទេ ឈ្មោះ សារ៉ូ។

**ស៖** បាទ សូមទោសចំពោះការអាន<>របស់ខ្ញុំ បាទ<គឺខ្ញុំថា> សារ៉ូ <ហ្នឹងឯង>។ តើលោកស្រីអាចនិយាយរៀបរាប់លម្អិតបន្តិចបានទេអំពីមេកង<>រូបនេះ?

**ផ៖** ចាស មេកងរបស់ខ្ញុំឈ្មោះ សារ៉ូ នោះ បង្ខំឲ្យធ្វើការគ្មាន -- ទាំងយប់ទាំងថ្ងៃ។

**ស៖** សំណួររបស់ខ្ញុំមិនពាក់ព័ន្ធទៅនឹងអ្វីដែលគាត់ឲ្យលោកស្រីធ្វើការ<នោះទេ ប៉ុន្តែខ្ញុំចង់សួរថាគាត់ជានរណា>? អាយុ<ប៉ុន្មាន?> ឈ្មោះ<អ្វី? ទាំង>នាមត្រកូល <និង>នាមខ្លួន <>តើគាត់ជាសមាជិកបក្សកុម្មុយនីស្តកម្ពុជាដែរ ឬក៏យ៉ាងណា? ភាពលម្អិតទាក់ទងទៅនឹងបញ្ហាទាំងនេះ។

[១៤:២៩:៤០]

**ផ៖** ចាស ខ្ញុំមិនស្គាល់នាមត្រកូលរបស់ សារ៉ូ នោះទេ ខ្ញុំស្គាល់ច្បាស់គេហៅថា បងសារ៉ូៗ តែអីចឹង អត់ដែរឮនាមត្រកូលថាអ្វីទេ។

**ស៖** តើគាត់មានអាយុប៉ុន្មានដែរ?

**ផ៖** ចាស ក្នុងពេលនោះ ខ្ញុំក៏អត់ដឹងថា គាត់អាយុប៉ុន្មានដែរ។

**ស៖** <>លោកស្រី <ស្មានមើល៍ តើគាត់>មានអាយុប្រហែលប៉ុន្មានឆ្នាំដែរ?

**ផ៖** បើតាមតែខ្ញុំស្មានគាត់មានអាយុប្រហែលជា៥៤ទៅ៥៥ឆ្នាំ មកដល់ឥឡូវនេះ។

**ស៖** ខ្ញុំមិនពូកែ<>ខាង<នព្វន្តទេ>។ នៅពេលនោះ តើមេកងហ្នឹងអាយុប្រហែល១៥ឬក៏អាយុប្រហែលជា២០ឆ្នាំ?

**ផ៖** កាលពីសម័យនោះ គាត់ប្រហែលជាអាយុ១៥ឆ្នាំតែប៉ុណ្ណោះ។

**ស៖** លោកស្រីដឹងទេថា មេកងរបស់លោកស្រីហ្នឹងមានឪពុកម្ដាយដែរឬទេ?

**ផ៖** ចាស គាត់មានឪពុកម្ដាយ។

**ស៖** លោកស្រីដឹងថា<>ឪពុកម្ដាយរបស់មេកងហ្នឹងជាសមាជិកបក្សកុម្មុយនីស្តកម្ពុជាដែរឬទេ?

[១៤:៣១:៥០]

**ផ៖** ចាស ម្ដាយរបស់មេកងឈ្មោះ សារ៉ូ នោះ គាត់ជាមេចុងភៅ។

**ស៖** លោកស្រីធ្លាប់ដែលឃើញ សារ៉ូ នេះនិយាយទៅកាន់កម្មាភិបាលខ្មែរក្រហម ឬកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាណាម្នាក់ដែរទេ?

**ផ៖** ចាស ខ្ញុំរវល់តែធ្វើការមិនបានឃើញ សារ៉ូ នេះទៅនិយាយទេ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្សែបកប្រែ និងខ្សែបកប្រែបន្ត។*

**ស៖** លោកស្រីធ្លាប់ឮអ្នកដទៃនិយាយថា មាន<គេ>ណែនាំ <គេ>បញ្ជាទៅដល់មេកងរបស់លោកស្រីឲ្យធ្វើយ៉ាងម៉េចៗចំពោះកងហ្នឹងទេ?

**ឆ៖** ចាស ខ្ញុំអត់ដឹងទេ។ ពេលគេត្រូវបញ្ជាគេហៅមេកងទៅប្រជុំបាត់ ខ្ញុំអត់ដឹងទេ។

**ស៖** លោកស្រីធ្លាប់ដែលឃើញកម្មាភិបាលខ្មែរក្រហមដទៃទៀត <ដើរតាម> សារ៉ូ នៅពេលដែលលោកស្រីធ្វើការ<ដែរឬ>ទេ?

**ឆ៖** ចាស មាន។ មានឈ្មោះ សារ៉ែម ជាប្រធានលើ សារ៉ូ ហ្នឹងទៀត។

**ស៖** តើឈ្មោះ សារ៉ែម អ៊ីចឹងឬ? ហើយតើបើឈ្មោះ សារ៉ែម ហ្នឹង តើ សារ៉ែម ជាអ្នកណា?

**ឆ៖** សារ៉ែម ហ្នឹងជាប្រធានលើមេ -- លើ សារ៉ូ ហ្នឹងទៀត ហើយប្រធានកុមារទាំងអស់។

[១៤:៣៤:០០]

**ស៖** តើលោកស្រីអាចជម្រាបបន្តិចទេ អំពីឈ្មោះ សារ៉ែម ហ្នឹង សារ៉ែម ហ្នឹងជា<នរ>ណា?

**ឆ៖** សារ៉ែម ហ្នឹងជាប្រធាន។ ខ្ញុំដឹងតែត្រឹមជាប្រធានអ្នកមក -- ជាប្រធានក្តាប់កុមារទាំងអស់ៗចំនួន២០០នាក់។ សារ៉ូ ហ្នឹងកាន់១០០នាក់ ឈ្មោះ ម៉ុម នោះកាន់១០០នាក់។ សារ៉ែម ហ្នឹងគេគ្រប់គ្រងលើកុមារទាំងអស់ហ្នឹង។ ខ្ញុំដឹងតែត្រឹមប៉ុណ្ណឹង។

**ស៖** ហើយចុះតើ សារ៉ែម និង សារ៉ូ <>ទាំងពីរនាក់ធ្វើជាប្រធានកង<រហូត>តាំងពីឆ្នាំ១៩៧៥ ដល់១៩៧៨ ឬក៏អត់ទេ?

**ឆ៖** ចាស ខ្ញុំមកនៅកងហ្នឹងពីឆ្នាំ១៩៧៦ ខ្ញុំជួបតាំងពី៧៦ រហូតដល់៧៩ ហ្នឹង។ លុះត្រាតែវៀតណាមចូលទៅហ្នឹងរត់បែកគ្នាអស់ទៅ។

**ស៖** លោកស្រីជម្រាបពីខាងដើមអំពីរឿងរ៉ាវមួយគឺថាលោកស្រីត្រូវបានគេវាយដំ។ សូមលោកស្រីជម្រាបអង្គជំនុំជម្រះឲ្យបានលម្អិតបន្តិចអំពីហេតុការណ៍ហ្នឹង តើរឿងនេះវាកើតឡើងនៅប្រហែលជាអំឡុងពេលណាដែរ?

**ឆ៖** ចាស គេវាយធ្វើបាបខ្ញុំហ្នឹង ឆ្នាំ -- ចុងឆ្នាំ៧៧។

[១៤:៣៦:១០]

**ស៖** តើសារ៉ូ និង សារ៉ែម មានវត្តមានទាំងអស់គ្នា<>នៅពេលដែលរឿងរ៉ាវនោះវាកើតឡើងចំពោះលោកស្រី<ដែរឬទេ>?

**ឆ៖** ពេលដែលគេវាយធ្វើបាបខ្ញុំហ្នឹង សារ៉ូ -- សារ៉ែម ហ្នឹងគេបញ្ជាប្រាប់ សារ៉ូ ហ្នឹងឲ្យមើល

ឈ្មោះខ្ញុំហ្នឹងនៅកន្លែងណា អីកន្លែងណា គេប្រើឲ្យ សារូ ហ្នឹងមកចាប់ខ្ញុំហ្នឹងតាមដែលគេប្រាប់ហ្នឹងមក។ សារូ ហ្នឹងគេបញ្ជាឲ្យពួកមូលដ្ឋានមកចាប់ខ្ញុំតាមបំណងរបស់គេចង់ធ្វើ។

**ស៖** ដូច្នេះ នៅពេលដែលគេវាយដំលោកស្រី គឺថាទាំង សារូ <និង>សារ៉ែម មានវត្តមាននៅទីនោះ<ដែរ>។ តើអ៊ីចឹងមែនទេ?

**ឆ៖** ជួនក៏នៅ ជួនក៏មិននៅ មិនមែនវាយដំតែម្ដងទេ វាច្រើនដង។

**ស៖** តើលោកស្រីដឹងទេថា សារ៉ែម មានដែលធ្លាប់ទាក់ទងជាមួយនឹងមេៗរបស់គាត់ដែរឬទេថ្នាក់លើមេៗរបស់គាត់ដែរទេ?

**ឆ៖** ចាស ខ្ញុំអត់ដែលដឹងទេ។

**ស៖** លោកស្រីដឹងថា សារូ ឬក៏ សារ៉ែម ហ្នឹងធ្លាប់ត្រូវបានគេដាក់ទណ្ឌកម្មដោយសារតែគេការធ្វើការវាយដំលោកស្រី <និងធ្វើបាបអ្នកឯទៀតនៅក្នុងកងហ្នឹង>ដែរ<ឬ>ទេ?

**ឆ៖** ចាស អត់មានទេ។

[១៤:៣៧:៥៣]

**ស៖** លោកស្រីដឹងថា គេមិនដែលដាក់ទណ្ឌកម្មអ្នកទាំងនុ៎ង<>ដោយរបៀបណា?

**ឆ៖** ពីព្រោះខ្ញុំមិនដែលឃើញគេមានរងទារុណកម្មអ្វីទាំងអស់។

**ស៖** <តើ>លោកស្រី<ជានិច្ចកាល>ដឹងថា ពួកអ្នកទាំងនោះនៅទីណាដែរទេ?

**ឆ៖** ចាស ខ្ញុំដឹង សារូ នៅភូមិសីមា ឯ សារ៉ែម នៅភូមិខ្នារ។

**ស៖** ឥឡូវខ្ញុំសូមចូលទៅប្រធានបទមួយថ្មីទៀត។ សក្ខីកម្មខាងដើមរបស់លោក<ស្រី>អំពីៗបងប្រុសរបស់លោកស្រី ម្ដាយរបស់លោកស្រីបានប្រាប់លោកស្រីថា បងប្រុសរបស់លោកស្រីត្រូវបានគេតាមដានមួយរយៈ ហើយគេក៏បានយកលេសដើម្បីចាប់ខ្លួនបងប្រុសរបស់លោកស្រី បើសិនជាខ្ញុំរៀបរាប់ប៉ុណ្ណឹង តើវាត្រឹមត្រូវដែរទេ?

**ឆ៖** ចាស ត្រឹមត្រូវ។

**ស៖** តើម្ដាយរបស់លោកស្រីធ្លាប់<ប្រាប់លោកស្រីថាគាត់>ដឹង<>គេបានតាមដានបងប្រុសរបស់លោកស្រីហ្នឹង <>ដោយរបៀបណាដែរទេ?

**ឆ៖** ចាស ខ្ញុំអត់ដឹងដែរ ពីព្រោះគាត់ឈឺនៅផ្ទះ គេចេះតែមកសួរគាត់អំពីកូនធ្វើអីខ្លះ កូនធ្វើអីប៉ុន្តែខ្ញុំអត់បានដឹងទេ។

[១៤:៤០:០១]

**ស៖** <តើ>លោកស្រីដឹងថា<>នៅក្នុងសហករណ៍ នៅក្នុងឃុំ ឬនៅក្នុងស្រុក<នោះ>គេដឹងអំពីប្រវត្តិរូបរបស់បងប្រុសលោកស្រី<>ដែរទេ?

**ឆ៖** ចាស គេដឹងៗទាំងអស់គ្នាថាគាត់ជាទាហាន លន់ នល់។

**ស៖** ហើយចុះលោកស្រីមានដឹងថា<គេដឹងរឿងនោះតាំងពីពេលណាមក? តើថាគេដឹងតាំងពីដើមមកឬ? ដឹងភ្លាមៗក្រោយថ្ងៃទី១៧ ខែមេសា>ឆ្នាំ១៩៧៥<>?

**ឆ៖** ចាស ខ្ញុំអត់បានដឹងទេ។

**ស៖** ខ្ញុំសូមសួរតាមរបៀបផ្សេងវិញ។ តើគេ<ដឹងថាគាត់ជាអតីតទាហានលន់ នល់ មួយរយៈហើយឬ>មុននឹងគេចាប់ខ្លួនគាត់<>?

**ឆ៖** គេបានដឹងហើយ ក៏ប៉ុន្តែគេមកសួរអ្នកម្ដាយខ្ញុំ អ្នកម្ដាយខ្ញុំគាត់ចេះតែលាក់។ គេស៊ើបសួរអ្នកជិតខាងទៀត តែខ្ញុំអត់បានដឹងថាគេមកសួរអ្វីៗពីម្ដាយខ្ញុំ ខ្ញុំអត់បានដឹងទេ។ ទើបតែដល់ពេលបងប្រុសខ្ញុំបាត់ខ្លួនទៅ រហូតដល់ពេលខ្ញុំធ្វើពាក្យបណ្ដឹងហើយ ទើបអ្នកម្ដាយខ្ញុំប្រាប់ថា គេមកស៊ើបការណ៍យូរហើយ។ គេចង់យកគាត់ទៅសម្លាប់ តែរកវិធីសម្លាប់គាត់មិនឃើញ លុះត្រាតែគេចោទគាត់ ថាគាត់ខុសសីលធម៌សង្កត់ដៃស្រីអីចឹងទៅ បានយកទៅសម្លាប់បាន។

[១៤:៤២:០២]

**ស៖** តើលោក<ស្រី>ដឹងថា<បងប្រុសរបស់លោកស្រីពាក់ស័ក្តិប៉ុន្មានដែរ ពេល>គាត់ធ្វើជាទាហាន លន់ នល់ <នោះ>?

**ឆ៖** ចាស ខ្ញុំអត់បានដឹងទេ។

**ស៖** តើនៅក្នុងនៅពេលដែលគាត់ធ្វើទាហាន លន់ នល់ តើលោកស្រីដឹងថាគាត់មានធ្វើសកម្មភាពអីខ្លះទេ?

**ឆ៖** ចាស ខ្ញុំអត់ដឹងទេ។

**ស៖** តើលោកស្រីធ្លាប់បានឃើញគាត់ស្លៀកឯកសណ្ឋានទាហានទេ មុនឆ្នាំ១៩៧៥?

**ឆ៖** ធ្លាប់ឃើញ។

**ស៖** ដូច្នេះមិនមានអ្វីគួរឲ្យសង្ស័យនោះទេ ថាគាត់ពិតជាទាហាន លន់ នល់។ តើត្រឹមត្រូវដែរទេ?

**ឆ៖** ចាស។

**ស៖** តើលោកស្រីមានដឹងទេ ថាគាត់មានបានប្រាប់ទៅអាជ្ញាធរមូលដ្ឋានក្រោយថ្ងៃ១៧ មេសា ៧៥ នៅពេលដែលគេធ្វើប្រវត្តិរូបនោះ ថាគាត់ធ្វើជាទាហាន លន់ នល់? <>

**ឆ៖** ចាស គាត់អត់បានប្រាប់ទេ។

[១៤:៤៣:៥៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

សូមអរគុណលោកប្រធាន។ ចម្លើយត្រូវបានផ្តល់រួចទៅហើយលោកប្រធាន។ ខ្ញុំយល់ថា មេធាវីការពារក្តីមានពេល៤៥នាទី ដែលសួរហ្នឹង គឺសួរទៅឲ្យដើមបណ្តឹងស្មានទៅលើអ្វីដែលគាត់មិនដឹងនៅសម័យនោះ <ព្រោះថាគាត់មានអាយុទើបតែ៨ឆ្នាំប៉ុណ្ណោះ>។ <ខ្ញុំគិតថាគ្រប់ភាគីទាំងអស់ត្រូវតែគោរពលើភាពពាក់ព័ន្ធ> យើងមានពេលខ្លីណាស់ យើងនៅមានដើមបណ្តឹងម្នាក់ទៀត<>។ <យើងស្នើសុំឲ្យភាគីទាំងអស់សួរដេញដោលកន្លែងណាពាក់ព័ន្ធក្នុងពេល១០នាទីតែប៉ុណ្ណោះ។> ខ្ញុំសង្ឃឹមថា មេធាវីការពារក្តីធ្វើដូចតែយើងដែរ គឺថាសួរតែសំណួរពាក់ព័ន្ធទៅបានហើយ ដើម្បីស្វែងរកការពិត។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមឆ្លើយតបលោកប្រធាន។ សំណួរទាំងនេះគឺមានការពាក់ព័ន្ធណាស់។ ខ្ញុំធ្លាប់បានឮ<ដើមបណ្តឹងរដ្ឋប្បវេណី>និយាយថា បងប្រុសរបស់គាត់ហ្នឹងគឺថាត្រូវបានគេតាមដានអស់មួយរយៈ <ហើយក៏>គេ<រក>លេស<>ចាប់ខ្លួនបងប្រុសរបស់គាត់។ ដូច្នេះខ្ញុំសួរចង់ដឹងថា គេចាប់ខ្លួននោះគឺដោយសារអី? <>ដោយសារតែ<>គាត់ធ្លាប់ធ្វើជាទាហាន លន់ នល់ <មិនមែនជាលេសតែមួយនោះទេ ហើយនេះគឺពាក់ព័ន្ធផ្ទាល់ជាមួយគោលនយោបាយទាក់ទិនទៅនឹងអតីតទាហាន និងអ្នករដ្ឋការលន់ នល់នោះ>។ <សូមលើកឡើងម្តងទៀតថា>អង្គជំនុំជម្រះបានផ្តល់ពេល ៤៥នាទីទៅឲ្យខាងសហព្រះរាជអាជ្ញា និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី។ ហើយខាងយើងខ្ញុំក៏<ទទួល>បាន<>ពេលវេលាប្រហាក់ប្រហែលគ្នានេះដែរ <ខ្ញុំគិតថាខ្ញុំពិតជាមានសិទ្ធិសួរដើមបណ្តឹងរដ្ឋប្បវេណីរូបនេះហើយ>។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធសេចក្តីជំទាស់។ សូមអញ្ជើញ!

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំជឿថាលោកស្រីបានឆ្លើយសំណួរខ្ញុំរួចមកហើយ។ គឺថាលោកស្រីឆ្លើយថា បងប្រុសរបស់លោកស្រីមិនបានប្រាប់គេថា គាត់ធ្វើទាហាន លន់ នល់ ទេ នៅពេលដែលគេធ្វើប្រវត្តិរូប។ តើត្រឹមត្រូវទេ?

**លោកស្រី អ៊ុម វណ្ណៈ៖**

**ឆ៖** ចាស។

[១៤:៤៦:១៥]

**ស៖** តើវានៅពេលក្រោយ ឬក៏យ៉ាងណា<>ទើបអាជ្ញាធរមូលដ្ឋានដឹងថា បងប្រុសរបស់លោក<ស្រីធ្លាប់>ធ្វើជាទាហាន លន់ នល់?

**ឆ៖** ពេលក្រោយមកបានគេដឹងៗហ្នឹងដឹងដោយសារខ្សែរយៈគេស៊ើបសួរបងប្អូនជីដូនមួយ និងអ្នកជិតខាង គេស៊ើបសួរដឹងហ្នឹង។

**ស៖** ខ្ញុំយល់។ ចម្លើយរបស់លោកស្រីថា ម្ដាយរបស់លោកស្រីថា ទោះជាយ៉ាងណាក៏ដោយគឺគេ<>រកលេសដើម្បីចាប់ខ្លួនបងប្រុសរបស់លោកស្រី តើអ៊ីចឹងទេ?

**ឆ៖** ចាស។

**ស៖** <>តើម្ដាយរបស់លោកស្រី<ដឹងដោយរបៀបណាថា> គ្រាន់តែធ្វើជាទាហាន លន់ នល់ គឺថាមិនអាច<>ឲ្យគេចាប់ខ្លួនអ៊ីចឹងទេ?

**ឆ៖** គាត់អត់បានដឹងទេ។

**ស៖** ខ្ញុំសួរថាតើម្ដាយរបស់លោកស្រីដឹងពី<>ណាថា <បងប្រុសរបស់លោកស្រីនោះ>ត្រូវបានគេដាមដានមួយរយៈ <ហើយគេក៏រក>លេសចាប់ខ្លួនគាត់នោះ?

**ឆ៖** គាត់ដឹងអំពីពួកមូលដ្ឋានត្រូវជាបងប្អូនរបស់គាត់។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមើលទៅនាឡិកាទៅ លោកប្រធានដល់ម៉ោងសម្រាកហើយ ឬក៏អនុញ្ញាតឲ្យខ្ញុំសួរបន្តទៀត?

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ម៉ោងសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ។

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

01086805


មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក ហើយឱ្យអញ្ជើញគាត់រួមទាំងមន្ត្រីអង្គការ ធី.ភី.អូ មកកាន់កន្លែងដែលគាត់ថ្លែងរៀបរាប់ទុក្ខសោកវេទនានេះ នៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងបី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៨ នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០១:៣៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណី។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមបន្តសួរលឿនទេ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកស្រី ខ្ញុំសូមសួរលោកស្រីសំណួរ<មួយ>ចំនួនទាក់ទងទៅនឹងការសម្លាប់ដែលលោក<ស្រី>បានឆ្លើយមុនសម្រាកនេះ។ នៅពេលនោះ លោកស្រីមានអាយុ១០ឆ្នាំ ត្រឹមត្រូវទេ គឺនៅពេលដែលលោកស្រីបានដឹងអំពីការសម្លាប់នោះ គឺលោកស្រីមានអាយុ១០ឆ្នាំ។ មែនទេ?

**លោកស្រី អ៊ុម វណ្ណះ៖**

**ឆ៖** ខ្ញុំអាយុ៩ឆ្នាំ។

[១៥:០២:៤៤]

**ស៖** តើកុមារៗដទៃទៀត មានបានមើលឃើញការសម្លាប់នេះទេ?

**ឆ៖** អត់ទេ។

**ស៖** តើលោកស្រីអាចជម្រាបជូនតុលាការថា លោកស្រីបានទៅទីនោះ<តែម្នាក់ឯងដោយរបៀបណា> ហើយ<>បាន<>ទៅ<ប្រទះ>នឹងក្រុមឈ្លបហ្នឹងដោយរបៀបណាដែរទេ?

**ឆ៖** ចាស ខ្ញុំចូលទៅបេះពពាក់ កាច់ទន្ទ្រានខែត្រហើយ ទៅបេះពពាក់ហ្នឹង បានជាខ្ញុំឃើញ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** តើលោកស្រីស្គាល់កងឈ្លបនោះទេ? ធ្លាប់ដែលបានឃើញមុខពួកឈ្លបនោះពីមុនទេ?

**ឆ៖** ចាស អត់ដែលឃើញទេ ហើយក៏អត់ស្គាល់ដែរ។

**ស៖** តើលោកស្រីបានដឹងថា <ពួកនោះ>ជាកងឈ្លប<>ដោយរបៀបណា?

**ឆ៖** ខ្ញុំឃើញតែស្ពាយកាំភ្លើង ហើយនិងកាន់គល់ឬស្សីហ្នឹង។ ឈ្លប គេថា ឈ្លបៗអីចឹង ខ្ញុំដឹងឮសួរតែគេថាអីចឹង ខ្ញុំអត់មានដឹងដោយរបៀបណាទេ ខ្ញុំដឹងតែគេថា ឈ្លបៗអីចឹងទៅ។

**ស៖** <លោកស្រីនិយាយថា "គេថា" លោកស្រីចង់មានន័យថាម៉េច? ខ្ញុំគិតថាលោកស្រីបានឃើញព្រឹត្តិការណ៍ហ្នឹងតែម្នាក់ឯងទេ។>

[១៥:០៤:៥៧]

**ឆ៖** ខ្ញុំអត់ឮពីអ្នកណាទេ ធ្លាប់តែឲ្យតែបាត់មនុស្ស គេថាឈ្លបមកចាប់ ហើយដល់ហើយខ្ញុំឃើញគាត់ហ្នឹង ក៏ទ្រង់ទ្រាយមានកាំភ្លើងអីចឹង ខ្ញុំថាឈ្លបអីចឹងទៅ។

**ស៖** <ក្រៅពីមានកាំភ្លើង>តើវាមាន<>សញ្ញាណាមួយ<>ដែលអាចសម្គាល់ថាជាឈ្លប ដូចជា ខោអាវ ឬក៏របៀបដែលពួកគេនិយាយ សូមលោកស្រីជួយរៀបរាប់<បន្ថែមបន្តិចទៀតបានទេ>?

**ឆ៖** ចាស មិនមែនសម្គាល់ដោយអ្វីទេ ខ្ញុំឃើញស្លៀកពាក់ខោអាវខ្មៅ មូលជើងខោ ជួតក្បាលក្រមា។ ស្ពាយកាំភ្លើង កាន់ឫស្សីហ្នឹង ហ្នឹងហើយ ខ្ញុំថាជាឈ្លបអីចឹងទៅ។

**ស៖** លោកស្រីថា <មនុស្ស>ដែលគេ<បណ្ដើរ គេឃាម ហើយក្រោយមកត្រូវគេសម្លាប់នោះជាមនុស្ស>មកពីភូមិរបស់លោកស្រី តើត្រឹមត្រូវទេ?

**ឆ៖** ចាស ពីព្រោះពីភូមិខ្ញុំហ្នឹង គេចាប់ពីយប់ហ្នឹង ឃើញបាត់មនុស្សប្រហែលជា១០នាក់ ក៏ប៉ុន្តែខ្ញុំមិនស្គាល់ឈ្មោះទេ ផ្ទះនៅជួរជង្ហែគ្នាជាមួយផ្ទះម្ដាយរបស់ខ្ញុំ។

[១៥:០៧:០៨]

**ស៖** លោកស្រី<ដើមបណ្ដឹងរដ្ឋប្បវេណី> គឺថាវាសំខាន់ណាស់ ដែលលោកស្រីបានជម្រាបមកយើងនូវអ្វីដែលលោកស្រីបានឃើញផ្ទាល់ភ្នែក។ នៅពេលដែលលោកស្រីឃើញអ្នកភូមិទាំងអស់ហ្នឹង<--ខ្ញុំសួរអីចេះវិញ>។ នៅពេលដែលលោកស្រីឃើញ<គេបណ្ដើរ>អ្នកទាំងនោះ<>តើលោកស្រី<ធ្វើយ៉ាងដូចម្ដេចទើប>ដឹងថា <អ្នកទាំងនោះ>ជាអ្នកភូមិរបស់លោកស្រី<>?

**ឆ៖** ខ្ញុំដឹង ដោយខ្ញុំសុំមេកងទៅផ្ទះ។ កាលពីយប់ហ្នឹង ឃើញ ឮសួរគេចាប់អ្នកផ្ទះខាងត្បូងខ្ញុំខាងជើងខ្ញុំចំនួន១០ផ្ទះ ក៏ប៉ុន្តែខ្ញុំស្គាល់តែប្រពន្ធ ប្ដីខ្ញុំអស់ស្គាល់ទេ។ ប្រពន្ធនោះក៏ខ្ញុំស្គាល់បានប្រហែល

ជាពីរបីនាក់ទេ។

**ស៖** ខ្ញុំយល់នូវអ្វីដែលលោកស្រីកំពុងតែនិយាយ ប៉ុន្តែសំណួរខ្ញុំ នៅពេលដែលលោកស្រីពួននៅគុម្ពោតព្រៃនោះ លោកស្រីឃើញ<មនុស្ស។ តើ>នៅពេលដែលលោកស្រីបានឃើញគេនៅពេលហ្នឹង លោកស្រីធ្វើម៉េចបានដឹងថា<មនុស្សទាំងអស់នោះជាអ្នក>ភូមិរបស់លោកស្រី?

**ឆ៖** ចាស ខ្ញុំធ្លាប់ឃើញគាត់ កាលដែលមាន -- ពេលដែលខ្ញុំទៅផ្ទះយប់ៗហ្នឹង ខ្ញុំធ្លាប់ឃើញគាត់ពីមុនមក។ ស្គាល់មុខគាត់ ប៉ុន្តែខ្ញុំអត់ស្គាល់ឈ្មោះ។

**ស៖** តើលោកស្រីធ្លាប់និយាយប្រាប់រឿងនេះទៅដល់អ្នកដទៃទៀតទេ ទាំងនៅពេលនោះក្តី ទាំងនៅពេលហ្នឹងភ្លាមៗក្តី ឬក៏ពេលក្រោយមកទៀត<ដែរឬទេ>?

[១៥:០៩:១៣]

**ឆ៖** ខ្ញុំអត់មាននិយាយប្រាប់អ្នកណាទៀតទេ ពីព្រោះខ្ញុំអត់ហ៊ាននិយាយទេ តែខ្ញុំដឹងខ្លាចឮទៅដល់មាត់គេ គេនឹងយកទោសពៃរ៍ដល់ខ្ញុំទៀត។

**ស៖** ខ្ញុំដឹងថា លោកស្រីខ្លាច <>នៅពេលដែលលោកស្រីបានឃើញ <ឬក៏ក្រោយ១ឆ្នាំ ឬ២ឆ្នាំ>ហ្នឹង ប៉ុន្តែចង់ដឹងថា<>តើក្រោយឆ្នាំ១៩៧៩ លោកស្រីធ្លាប់បាននិយាយរឿងរ៉ាវនេះប្រាប់អ្នកដទៃទេ?

**ឆ៖** ខ្ញុំអត់បាននិយាយប្រាប់អ្នកណាទេ។

**ស៖** មិនមែនសូម្បីជាមួយនឹងសមាជិកគ្រួសារជិតដិតហ្នឹងក៏លោកស្រីមិននិយាយប្រាប់ដែរ ឬក៏យ៉ាងណា?

**ឆ៖** អត់ទេ។

**ស៖** ក្រោយឆ្នាំ១៩៧៩ តើលោកស្រីមាននៅ<ចំណាំមុខមនុស្ស>ដែលលោកស្រីថា ជាឈ្លប<នោះដែរឬទេ? តើលោកស្រី>ធ្លាប់បានជួប<គេ>នៅក្នុងភូមិ ឬជួបនៅទីកន្លែងណាមួយ<>ដែរទេ?

**ឆ៖** អត់ដែលជួបទេ។

**ស៖** តើលោកស្រីអាចឱ្យតម្រុយណាមួយ<ដែលញ៉ាំងឱ្យយើងស្វែងរកការបញ្ជាក់ពីរឿងរ៉ាវលោកស្រីបានដែរឬទេ? តើយើងធ្វើយ៉ាងដូចម្តេចដើម្បី>រកភស្តុតាងណាដែលវាស៊ីចង្វាក់គ្នាទៅនឹងរឿងរ៉ាវរបស់លោកស្រីនេះបានដែរឬទេ?

[១៥:១១:៣៦]

**ផ៖** ខ្ញុំអត់មានដែលបានជួបតាំងពីនោះមក ខ្ញុំអត់មានដែលជួបទៀត។ ខ្ញុំអត់មានពាក្យអីឆ្លើយ ព្រោះខ្ញុំអត់បានជួបអ្នកទាំងអស់ហ្នឹងទៀតផង។

**សៈ** សូមអរគុណលោកស្រី។ ប្រធានបទចុងក្រោយរបស់ខ្ញុំនេះ គឺលោកស្រីបានឆ្លើយពីខាងដើមថា លោកស្រីត្រូវបានគេ<បង្អត់>អាហារនៅពេលលោកស្រី<>ធ្វើការ<មិនបានតាមគេកំណត់នោះ>។ លោកស្រីសូមជម្រាបជូនតុលាការ តើរឿងនេះវាកើតឡើងចំពោះលោកស្រីម្ដង ពីរដង បីដង ឬក៏យ៉ាងម៉េច? សូមពន្យល់ឲ្យបានលម្អិតបន្តិចផង?

**ផ៖** ចាស ដែលខ្ញុំមិនបានទៅធ្វើការ គេកាត់របបអាហារហ្នឹង វាច្រើនដងណាស់ ក៏ប៉ុន្តែគេកាត់ បើខ្ញុំអត់បានទៅធ្វើហ្នឹង ជួនគេកាត់ពេលព្រឹក អ៊ីចឹងថ្ងៃត្រង់អ៊ីចឹង ជួនក៏កាត់ពេលល្ងាចអ៊ីចឹងទៅ វាច្រើនដងអ៊ីចឹងដែរ។

**សៈ** ខ្ញុំយល់ហើយអំពីសក្ខីកម្មរបស់លោកស្រី ប៉ុន្តែរឿងរ៉ាវនេះវាកើតមានឡើង<ញឹកញាប់ប៉ុនណាដែរ? តើវាកើតឡើង>រាល់ខែ ឬក៏ពីរខែម្ដង ឬវាកើតឡើងរៀងរាល់សប្ដាហ៍?

[១៥:១៣:១១]

**ផ៖** ចំនួន១ខែ ឬក៏២ខែម្ដងទេ មិនមែនរាល់សប្ដាហ៍ទេ។

**សៈ** សំណួរចុងក្រោយទាក់ទងទៅនឹងបញ្ហារបបអាហារ លោកស្រីអាចជម្រាបជូនអង្គជំនុំជម្រះថា តើវាមានភាពខុសគ្នាដែរទេ រវាងរបបអាហារដែលលោកស្រីបានទទួល និងកុមារដទៃទៀតទទួល<>ពីដើមដំបូងនៃរបបនុ៎ង ហើយនិងនៅចុងនៃរបបនេះ? តើពីដំបូងវាមានរបបហូបចុកជាច្រើនហើយក្រោយមកចុងបញ្ចប់នៃរបបហូបចុកតិចតួច<នៅចុងឆ្នាំ១៩៧៨ ដែរឬទេ>?

**ផ៖** ចាស របបហូបចុកហ្នឹង កាលពីឆ្នាំ១៩៧៥-៧៦ ដើម៧៦ហ្នឹង ហូបចុកបបរមានខាប់ដល់តែពេលមកចុង៧៦ មក៧៧, ៧៨ បបររាវទាំងអស់។ សុទ្ធតែរាវ អត់មានបបរខាប់ទៀតទេ ខុសប្លែកគ្នា។

**សៈ** ដូច្នេះស្ថានភាពកាន់តែអាក្រក់ទៅៗ។ តើលោកស្រីកំពុងតែនិយាយថា ពីខាងដើមវាគ្រាន់បើ ហើយពីខាងក្រោយកាន់តែអាក្រក់ទៅៗ អ៊ីចឹងឬយ៉ាងណា?

**ផ៖** ចាស។

[១៥:១៥:០៩]

**សៈ** សំណួរចុងក្រោយបំផុតរបស់ខ្ញុំ តើលោកស្រីអាចជម្រាបជូនអង្គជំនុំជម្រះ<បានទេ សូ

វ៉ាន់ ជានរណា?> មនុស្សម្នាក់ដែលលោកស្រីថាកំពុងតែរស់នៅប្រទេសនូវែលសេឡង់<។>

**ឆ៖** ចាស ឈ្មោះ សូវ៉ាន់។

**ស៖** ហើយ<លោកស្រីថាគាត់សព្វថ្ងៃនេះរស់នៅប្រទេសនូវែលសេឡង់> --<លោកប្រធាន> គឺឯកសារ D22/86<។> តើលោកស្រីអាចរៀបរាប់អំពីបុគ្គលរូបនេះឲ្យបានលម្អិតជាងនេះបានទេ?

**ឆ៖** កាលពីខ្ញុំជួប សូវ៉ាន់ ហ្នឹង, សូវ៉ាន់ នៅជាមួយបងប្រុសរបស់ខ្ញុំ សួរខ្ញុំសួរគាត់ហ្នឹង គាត់និយាយរឿងរ៉ាវប្រាប់ខ្ញុំ ដូចខ្ញុំរៀបរាប់ហើយអ៊ីចឹង ក៏ប៉ុន្តែដល់ទៅពេលបែកវៀតណាមចូលមកហ្នឹង ពួកគាត់ក៏បាត់ទៅៗទើបតែនឹងដឹងដំណឹងថាគាត់នៅនូវែលសេឡង់ ប៉ុន្តែមិនដែលចូលមកស្រុកខ្មែរទេ មានបងប្អូនគាត់ប្រាប់ថាគាត់នៅនូវែលសេឡង់។

**ស៖** តើគាត់ជាកម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតី ឬក៏អត់ទេ?

**ឆ៖** អត់ទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកស្រី សូមអរគុណលោកប្រធាន អស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ ផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក ខៀវ សំផន។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក គង់ សំអុន៖**

**ស៖** ខ្ញុំសូមការបំភ្លឺពីអ្នកស្រីមួយចំនួនទាក់ទងទៅនឹងការផ្តល់សក្ខីកម្មរបស់អ្នកស្រីថា អ្នកស្រីបានចូលក្នុងកងចល័តនៅអាយុ៨ឆ្នាំ។ ខ្ញុំចង់សួរអ្នកស្រីថា អ្នកស្រីដឹងពីណាមក អ្នកណាអ្នកប្រាប់អ្នកស្រីថាអ្នកស្រីចូលក្នុងកងចល័តក្នុងអាយុ៨ឆ្នាំហ្នឹង?

[១៥:១៧:៥៥]

**លោកស្រី អ៊ឹម វណ្ណៈ៖**

**ឆ៖** ចាស អត់មានអ្នកណាប្រាប់ខ្ញុំទេ ពីព្រោះខ្ញុំកាលហ្នឹងខ្ញុំអាយុ៨ ទៅ៩ឆ្នាំហើយខ្ញុំ ៩ឆ្នាំ គ្មានអ្នកណាប្រាប់ទេ។

**ស៖** បាទ សូមអរគុណ។ តើអ្នកស្រីមានការច្រឡំគ្នាពាក្យថាកងចល័ត និងកងកុមារដែរទេ ឬ

មួយក៏អ្នកស្រីស្ថិតនៅក្នុងកងកុមារ មិនមែនស្ថិតក្នុងកងចល័ត?

**ឆ៖** ចាស កង -- ពាក្យទាំងពីរនេះមិនមែនខ្ញុំច្រឡំទេ កងចល័តគឺកងចល័តកុមារ កុមារដែលធំជាងគេៗដាក់កងចល័ត កុមារដែលនៅតូចល្មមគេដាក់កងកុមារ ប៉ុន្តែចេញពីកុមារដូចគ្នា។

**ស៖** ក្នុងកងកុមាររបស់លោកស្រីហ្នឹងមានអាយុចាប់ពី អាយុទាបបំផុតប៉ុនណា ហើយធំបំផុតអាយុប៉ុនណា?

**ឆ៖** ទាបបំផុតត្រឹមអាយុ៨ឆ្នាំឡើងទៅ។

**ស៖** ហើយខ្ពស់បំផុត?

**ឆ៖** ត្រឹមអាយុ១២។

**ស៖** បាទ សូមអរគុណ។ លោកស្រីរៀបរាប់ពីឈ្មោះ សារូ និងឈ្មោះ សារ៉ែម។ លោកស្រីបានបញ្ជាក់ថាឈ្មោះសារូ នេះនៅភូមិសីមា លោកស្រីដឹងថាឃុំអីទេ ហើយស្រុកអីទេ?

[១៥:១៩:៤៩]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប។

**លោកស្រី អ៊ឹម វណ្ណៈ៖**

**ឆ៖** ចាស ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវដដែល។

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ ចុះឈ្មោះ សារ៉ែម គាត់នៅឃុំណាដែរ ស្រុកណាដែរ?

**ឆ៖** នៅឃុំលាយបូរដូចគ្នា។

**ស៖** លោកស្រីដែលជួបគាត់ទាំងពីរនាក់ហ្នឹងទេ ក្រោយរំដោះ៧៩?

**ប្រធានអង្គជំនុំ៖**

តាំងសំណួរម្តងទៀតលោកមេធាវី!

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ ខ្ញុំចង់សួរថា អ្នកទាំងពីរនាក់ហ្នឹងលោកស្រីធ្លាប់ជួបទេ ក្រោយរំដោះឆ្នាំ១៩៧៩?

**លោកស្រី អ៊ឹម វណ្ណៈ៖**

**ឆ៖** ចាស ខ្ញុំជួបតែ សារូ, សារ៉ែម ខ្ញុំមិនដែលឃើញទេ។

**ស៖** អ្នកស្រីដឹងដំណឹងថា គេទាំងពីរនាក់នៅក្នុងភូមិឃុំដដែលហ្នឹង ឬមួយក៏ផ្លាស់ទីលំនៅទៅកន្លែងផ្សេង?

**ឆ៖** ខ្ញុំដឹងប្រាកដតែ សារូ ទេ ដែលរស់នៅភូមិដដែល។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងព្រឹត្តិការណ៍ដែលអ្នកស្រីរៀបរាប់ពីការមើលឃើញការសម្លាប់មនុស្ស១៥នាក់ដោយកងឈ្លបគ្នាប្រាំពីរនាក់ ដែលមានកាន់កាំភ្លើងបីនាក់ និងកាន់ដំបងបួននាក់។ ខ្ញុំចង់សួរបន្ថែមថា ក្នុងបរិវេណដែលអ្នកស្រីថាទៅបេះរពាក់ នៅក្នុងទីតាំងដែលលោកស្រីបេះរពាក់នោះ វាមានស្ថានភាពម៉េចដែរ លោកស្រីអាចរៀបរាប់បានទេ?

[១៥:២២:៤២]

**ឆ៖** ចាស ក្នុងកន្លែងដែលខ្ញុំទៅបេះរពាក់នោះមានដើមឫស្សីច្រើន គុម្ពឫស្សី ហើយនិងដើមរពាក់ ទន្រ្ទានខែត្រច្រើនជាងកន្លែងនានា។

**ស៖** ជាព្រៃក្រាស់ឬទេ ហើយមានទំហំប៉ុនណាដែរក្នុងអាបរិវេណហ្នឹង?

**ឆ៖** ចាស ព្រៃនោះមិនក្រាស់ប៉ុន្មានទេ តែទំហំខ្ញុំមិនអាចស្មានដឹងទេ ពីព្រោះខ្ញុំខ្លាចមិនអាចនឹងស្មានទំហំថាតូច ឬមួយធំទេ។

**ស៖** បាទ មុននេះអំមិញលោកស្រីបញ្ជាក់ថា លោកស្រីបានឃើញតែម្នាក់ឯងទេ នូវការសម្លាប់នោះ។ ប៉ុន្តែអ្នកស្រីបានឆ្លើយពីមុន ថាអ្នកស្រីទៅកន្លែងនោះគឺមានកុមារដទៃទៀតទៅជាមួយដែរ។ ខ្ញុំចង់សួរថា តើអ្នកដែលទៅជាមួយអ្នកស្រីនុ៎ង ដែលមិនបានឃើញហ្នឹងដោយសារហេតុអីដែរ? ដោយសារគេជាប់រវល់ធ្វើអ្វី បានជាអត់បានឃើញអាការសម្លាប់ហ្នឹង?

**ឆ៖** ចាស--

**ប្រធានអង្គជំនុំ៖**

បាទ កុំអាល់ទាន់ឆ្លើយតប! សូមអញ្ជើញមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមាន<យោបល់ បើតាមការកត់សម្គាល់របស់សហភាតាខ្ញុំដែលគាត់ស្ដាប់ដើមបណ្ដឹងជាភាសាខ្មែរ។ ខ្ញុំគិតថាគាត់មិនបាននិយាយយ៉ាងដូច្នោះទេ។> គាត់និយាយថាគាត់តែម្នាក់<ឯងទេ>នៅពេលដែលគាត់ឃើញឈ្លប។ អានេះជា<អ្វីដែល>ខ្ញុំ<បានឮ>តាមរយៈការបកប្រែជាភាសាបារាំង។ អ៊ីចឹងខាងសហភាតារបស់ខ្ញុំអាចបញ្ជាក់បាន ចំពោះការស្ដាប់ឮជាភាសាខ្មែរ

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

នោះ។

[១៥:២៤:៥៧]

**លោក ហុង គីមសួន៖**

សូមអរគុណលោកប្រធាន។ អម្បាញ់មិញខាងអ្នកស្រី អ៊ឹម វណ្ណៈ គាត់មិនមែននិយាយថា បានឃើញតែម្នាក់ឯងទេ គាត់និយាយថា ទៅមួយក្រុមបែងជាពីរ គឺប្រាំនាក់ទៅផ្សេង កន្លែងគាត់ទៅបេះរពាក់នោះប្រាំនាក់។ ហើយលោក កូប៉េ បានសួរថា តើពេលឃើញហ្នឹងកុមារដទៃៗទៀតបានឃើញឬអត់? គាត់ថា អត់ទេ។ អ៊ីចឹងក្នុងន័យនេះ មិនមែនមានន័យថា គាត់ឃើញតែម្នាក់ឯងទេ ព្រោះក្រុម គាត់មានប្រាំនាក់។ សំណួរមិនបានសួរទៅដល់ថា ចុះអ្នកប្អូននាក់ទៀតបានឃើញដូចគាត់ដែរអត់? វាអត់បានសួរត្រង់ហ្នឹងទេ។ បាទ សូមអរគុណ។

**លោក គង់ សំអុន៖**

លោកប្រធាន ខ្ញុំថាដូចអត់មានអីខុសពីសំណួររបស់ខ្ញុំទេ។

**ប្រធានអង្គជំនុំ៖**

បាទៗ អញ្ជើញសួរ បាទពេលវេលាដូចអស់ហើយណា។ អញ្ជើញបញ្ចប់សំណួរ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** លោកស្រីអាចបញ្ជាក់បានទេថា ហេតុអីបានជាគេអត់ឃើញព្រឹត្តិការណ៍ហ្នឹង អ្នកដទៃទៀតដែលទៅជាមួយអ្នកស្រី?

**លោកស្រី អ៊ឹម វណ្ណៈ៖**

**ឆ៖** មិនមែនថាគេមិនឃើញទេ គេឃើញដែរ ក៏ប៉ុន្តែបែងចែកជាពីរក្រុម។ មួយក្រុមប្រាំនាក់គេឃើញដូចខ្ញុំដែរ។

**ស៖** បាទ អ៊ីចឹងអ្នកស្រីស្គាល់ចាំឈ្មោះអ្នកដែលៗទៅក្នុងក្រុមជាមួយអ្នកស្រីហ្នឹងទេ?

**ឆ៖** ចាស ខ្ញុំស្គាល់។

**ស៖** អាចជម្រាបឈ្មោះបានទេ?

**ឆ៖** អាចជម្រាបបាន។

**ស៖** សូមអញ្ជើញ!

**ឆ៖** ទី១ឈ្មោះ សុផា, ទី២ ឈ្មោះ សុខលី, ទី៣ឈ្មោះ សុផេង, ទី៤ ឈ្មោះ សុខាន់, ទី៥ គឺរូប

ខ្ញុំឈ្មោះ អ៊ឹម វណ្ណៈ។

**ស៖** លោកស្រីដឹងថា ទាំងបួននាក់ហ្នឹងនៅឯណាទេ ឥឡូវហ្នឹង?

[១៥:២៧:៤៥]

**ឆ៖** ចាស នាងខ្ញុំអត់មានបានដឹងទេ ព្រោះតាំងពីពេលនោះមក ខ្ញុំបែកគ្នារហូតមិនដែលជួបមុខគ្នាទេ។

**ស៖** សំណួរចុងក្រោយមួយខ្ញុំចង់សួរថា ទាក់ទងទៅនឹងពេលដែលអ្នកស្រីត្រូវគេធ្វើបាបដែលមេកងបញ្ជាឲ្យកុមារដទៃទៀតមកវាយធ្វើបាបអ្នកស្រី ធ្វើម៉េចបានអ្នកស្រីដឹងថា កុមារ២០នាក់ ដែលមកវាយអ្នកស្រីហ្នឹងជាកុមារមូលដ្ឋាន?

**ឆ៖** ពីព្រោះកុមារមូលដ្ឋាននៅកងជាមួយគ្នា នៅជិតគ្នាហ្នឹង។

**ស៖** គេមានបែងចែកជាក្រុមកុមារមូលដ្ឋានផ្សេង កុមារ១៧ មេសា ផ្សេងទេ?

**ឆ៖** ចាស គេបែងចែក តាំងពីធ្វើការ តាំងពីហូបបាយ។

**ស៖** ចុះអ្នកស្រីអាចចាំបានទេ មេកងផ្សេងៗនៅក្នុងក្រុមកុមារហ្នឹងមានឈ្មោះអីខ្លះ? មិញលោកស្រីរៀបរាប់ឈ្មោះ ម៉ុម ម្នាក់ មានអ្នកផ្សេងទៀតទេ?

**ឆ៖** ចាស ខ្ញុំចាំបានតែបីនាក់ហ្នឹងទេ។

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន អស់សំណួរហើយ។

[១៥:៣០:០០]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអរគុណចំពោះលោកស្រី អ៊ឹម វណ្ណៈ ការថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងព្យសនកម្មដែលលោកស្រីអះអាងថា លោកស្រីបានទទួលរងនៅក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ បានដើរដល់ទីបញ្ចប់ហើយ។ ហើយលោកស្រីអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកស្រីមានបំណងចង់ទៅបានហើយ។ សូមលោកស្រីធ្វើដំណើរវិលត្រឡប់ប្រកបដោយសុវត្ថិភាព។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញជូនលោកស្រី អ៊ឹម វណ្ណៈ វិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលគាត់មានបំណងទៅបានហើយ។ ហើយលោកស្រី ឆាយ ម៉ារីដែន បុគ្គលិកអង្គភាពអង្គការ ធី.ភី.អូ គប្បីអង្គុយនៅទី

នោះដដែលចុះ រង់ចាំអង្គជំនុំជម្រះស្ដាប់ការរៀបរាប់ពីទុក្ខសោកវេទនារបស់សាក្សីបន្ទាប់ -- របស់ដើមបណ្ដឹងរដ្ឋប្បវេណីបន្ទាប់ទៀត។

*(ដើមបណ្ដឹងរដ្ឋប្បវេណីចាកចេញពីបន្ទប់សវនាការ)*

បង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-884 ចូលមកកាន់កន្លែងថ្លែងរៀបរាប់ទុក្ខសោកវេទនានៅចំពោះមុខអង្គជំនុំជម្រះ។

*(ដើមបណ្ដឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

[១៥:៣១:៥១]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្ដី លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី! តើលោកស្រីឈ្មោះអី?

**លោកស្រី ឡិប នាង៖**

**ឆ៖** ខ្ញុំឈ្មោះ ឡិប នាង ។

**ស៖** អរគុណ លោកស្រី ឡិប នាង ។ តើលោកស្រីកើតនៅថ្ងៃខែឆ្នាំណា លោកស្រីចាំដែរឬទេ?

**ឆ៖** ខ្ញុំអត់បានចាំ ហើយដឹងតែអាយុ។

**ស៖** តើលោកស្រីអាយុប៉ុន្មានឆ្នាំហើយ?

**ឆ៖** អាយុ៥១។

**ស៖** អរគុណលោកស្រី ឡិប នាង។ ហើយតើទីកន្លែងដែលលោកស្រីរស់នៅសព្វថ្ងៃ នៅទីកន្លែងណា?

[១៥:៣២:៤០]

**ឆ៖** នៅបឹងត្រពាំង។

**ស៖** ភូមិឃុំស្រុកខេត្ត? ភូមិណា ស្រុកណា ឃុំណា ខេត្តណា?

**ឆ៖** ស្រុកកំពត ខេត្តកំពត។

**ស៖** អរគុណ ហើយលោកស្រីប្រកបមុខរបរធ្វើអ្វីសព្វថ្ងៃនេះ?

**ឆ៖** នៅផ្ទះមើលចៅ។

**ស៖** ឪពុករបស់លោកស្រី គាត់ឈ្មោះអី?

**ឆ៖** ឈ្មោះ លី ឡិប។

**ស៖** ចុះម្ដាយបង្កើតរបស់លោកស្រីឈ្មោះអី?

**ឆ៖** គង់ ឡិប -- គង់ ណះៗ។

**ស៖** ប្ដីរបស់លោកស្រីឈ្មោះអី? ហើយលោកស្រីមានកូនប៉ុន្មាននាក់?

[១៥:៣៣:៥០]

**ឆ៖** ណុយ វ៉ែន។ កូនប្រាំមួយនាក់។

**ស៖** បាទ អរគុណ។ លោកស្រី ឡិប នាង ក្នុងនាមលោកស្រីជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសវនាការនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅលោកស្រី ដើម្បីថ្លែងរៀបរាប់ប្រាប់អង្គសវនាការ អំពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្ម ដែលកើតមានចំពោះលោកស្រីជាអាទិ៍ ការខូចខាតផ្លូវចិត្ត ផ្លូវកាយ សម្ភារៈ ដែលជាព្យសនកម្មផ្ទាល់ខ្លួន ដែលជាបច្ច័យដោយផ្ទាល់អំពីបទឧក្រិដ្ឋ ដែលបានកើត និងបានកើតមានពិតប្រាកដរហូតដល់សព្វថ្ងៃនេះ ដែលនាំឱ្យលោកស្រីតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅរឿងក្ដីនេះ។ ដែលពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋត្រូវចោទប្រកាន់លើជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ដែលលោកស្រីអះអាងថាបានប៉ះពាល់ដោយផ្ទាល់ចំពោះលោកស្រីនៅក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យចាប់ពីថ្ងៃ១៧ ខែមេសា ឆ្នាំ១០៧៥*(ស៊ីក)* រហូតដល់ថ្ងៃ០៦ ខែមករា ឆ្នាំ១៩៧៩។

ហើយតាមសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសាកសួរដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ អំពីស្ថានភាពទុក្ខសោកវេទនា និងព្យសនកម្មទាំងឡាយដែលកើតមានចំពោះគាត់។

សូមអញ្ជើញបាទ!

[១៥:៣៥:១៦]

**លោក ឡោ ជុនធី៖**

បាទ សូមអរគុណ។ សូមគោរពលោកប្រធាន។ សូមគោរពអង្គជំនុំជម្រះទាំងមូល។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** សូមជម្រាបសួរលោកស្រី ឡិប នាង។ នាពេលនេះខ្ញុំបាទ ឡោ ជុនធី ដែលជាមេធាវី

តំណាងដើមបណ្ដឹងរដ្ឋប្បវេណីនឹងជម្រាបសួរអ្នកស្រីអំពីការឈឺចាប់ដែលបានជួបប្រទះនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យក្នុងអំឡុងឆ្នាំ១៩៧៥ ទៅដល់ឆ្នាំ១៩៧៩។ សំណួរទី១ ដែលខ្ញុំសូមជម្រាបនោះ ថាតើនៅក្នុងសម័យខ្មែរក្រហមហ្នឹង លោកស្រីបានទៅរស់នៅស្រុកណាដែរបាទ?

[១៥:៣៦:១១]

**លោកស្រី ឡិប នាង៖**

**ឆ៖** ជំនាន់ខ្មែរក្រហម ខ្ញុំនៅភូមិត្នោតចាង។

**ស៖** ស្រុកអីដែរ បាទ?

**ឆ៖** ខ្ញុំនៅភូមិត្នោតចាង ស្រុកត្រាំកក់។

**ស៖** ហើយស្គាល់ខេត្តអត់?

**ឆ៖** អត់បានស្គាល់ទេ ខ្ញុំអត់បានសួរគេ។

**ស៖** បាទ អរគុណច្រើន។ តាមប្រវត្តិរបស់អ្នកស្រី គឺថាពេលដែលសម័យខ្មែរក្រហមមកដល់នោះ គឺអ្នកស្រីមានបងប្អូនទាំងអស់ប្រាំនាក់ ហើយខ្ញុំជម្រាបសួរថា តើនៅឆ្នាំដែលបន្តបន្ទាប់មកហ្នឹងដូចជាឆ្នាំ១៩៧៧ តើលោកស្រីធ្វើការនៅកន្លែងណាដែរ? ហើយមានបានជួបព្រឹត្តិការណ៍អ្វីដែលប៉ះពាល់ទៅដល់សាច់ញាតិរបស់លោកស្រី?

**ឆ៖** ខ្ញុំនៅត្នោតចាងហ្នឹង ធ្វើការនៅហ្នឹង បងខ្ញុំឈឺ។ បងប្រុសឈឺ បងស្រីឈឺ ដល់ឈឺហើយយកទៅពេទ្យ ដល់យកទៅៗបាត់រហូត។ អត់មានឃើញដឹងបងដឹងប្អូនដឹងយកទៅដល់ណា។ យកទៅពេទ្យយកទៅបាត់រហូត អត់មានឃើញយកមកវិញទេ។

[១៥:៣៨:០៩]

**ស៖** តើគាត់ឈឺអីដែរ មានដឹងទេ?

**ឆ៖** គាត់ឈឺរាក ហើយក្ដៅ។ យកទៅពេទ្យ យកទៅៗបាត់រហូត។

**ស៖** បាទ ចុះនៅពេលដែល នៅពេលមួយនោះ ថាលោកស្រីបានកំពុងតែធ្វើជីកប្រឡាយ តើប្អូនៗរបស់លោកស្រីពីរនាក់ទៀតហ្នឹង ត្រូវខាងខ្មែរក្រហមហ្នឹងចាប់បញ្ជូនទៅណាដែរ?

**ឆ៖** ខ្ញុំកំពុងតែជីកប្រឡាយ ប្អូនខ្ញុំខ្មែរក្រហមដឹករទេះសេះដាក់១២នាក់យកទៅ។ យកប្អូនខ្ញុំទៅយកទៅ ដល់ប្អូនខ្ញុំស្រែកថា បងអើយ! ខ្ញុំទៅហើយ។ ទៅយកទៅបាត់រហូតទៀត។ បាត់បងពីរ បាត់ប្អូនពីរ។ បងក៏បាត់ប្អូនក៏បាត់ បាត់អស់ ដល់អត់មានម៉ែមានឪ នៅឡោតោតែឯង។

**ស៖** ចុះឪពុកម្ដាយទៅណាអស់ដែរ?

[១៥:៣៩:៤៦]

**ឆ៖** ឪពុកម្ដាយខ្ញុំមកជាមួយគ្នា ខ្ញុំមកដល់ហ្នឹងដូចគេកាត់អស់មួយកំណាត់ទៅក្រោយ ខ្ញុំកាត់មួយកំណាត់ឲ្យខ្ញុំដើរទៅមុខ ដល់នៅហើយបងប្អូនតែប្រាំនាក់ហ្នឹង។ ដល់ទៅប្រាំនាក់ គេយកបងប្អូនទៅអស់បួននាក់ នៅខ្ញុំតែឯងនៅស្រុកហ្នឹង នៅតែឯងអត់ហ៊ានព្ញមាត់ អត់ហ៊ានអី ដឹងតែប្រឹងធ្វើការ។ ខ្ញុំមិនដឹង ដល់ទៅគេហៅទៅធ្វើណាក៏ទៅដែរ អត់ហ៊ាននៅតវ៉ាអីគេ ឲ្យហៅទៅៗបាត់ប្អូនបាត់បង ហើយអត់ហ៊ាននៅប្រកែកទេ។

**ស៖** លោកស្រីអាចបញ្ជាក់ឈ្មោះបានទេថា បងពីរនាក់ហ្នឹងគាត់ឈ្មោះអីដែរបាទ?

**ឆ៖** ឈ្មោះ ឡិប ឡេះ, ឡិប មើ។

**ស៖** ចុះអម្បាញ់មិញថា ប្អូនពីរនាក់ទៀត តើឈ្មោះអីដែរ ហើយស្រីប្រុស?

សូមទោស អម្បាញ់មិញខ្ញុំជម្រាបសួរថាអ៊ីចេះ ថាអម្បាញ់មិញបានលើកឡើងថា ឃើញប្អូនពីរនាក់ត្រូវបានកង មេកងកុមារហ្នឹងដឹកតាមរទេះទៅ។ ខ្ញុំចង់ដឹងថាតើឈ្មោះគាត់ពីរនាក់ហ្នឹងឈ្មោះអីខ្លះ?

[១៥:៤២:០៣]

**ឆ៖** ឈ្មោះ ឡិប ឡេះ, ឡិប រី។

**ស៖** បាទ អរគុណ។ ចំណុចមួយទៀត ដែលខ្ញុំចង់ជម្រាបសួរដែរថា តើនៅពេលដែលលោកស្រីទៅធ្វើការនៅទីនោះ ហើយតើមេកងរបស់លោកស្រីហ្នឹង គាត់បានដឹងថា លោកស្រីមិនពិសាសាច់ជ្រូកដែរទេ?

**ឆ៖** គាត់ដឹងៗថាខ្ញុំអត់ហូបសាច់ជ្រូក ដល់គាត់ខំនេះឲ្យល្ពៅបមកយាមឲ្យខ្ញុំខំឲ្យខ្ញុំហូបដាក់ជាមួយបបរឲ្យខ្ញុំហូបជាមួយសាច់ជ្រូក ហើយខ្ញុំបងប្អូនអស់ហើយ ខ្ញុំអត់ហ៊ានប្រកែកទេ ខ្ញុំខំហូបខំលេប។ ខ្លាចទៅបាត់ដូចបងដូចប្អូន។

**ស៖** ហើយនៅក្នុងកងហ្នឹងមានអ្នកដែលដូចលោកស្រីហ្នឹងប៉ុន្មាននាក់ដែរ?

**ឆ៖** មួយកង១០នាក់ តែគេដាក់តែពីរៗនាក់ចូលទេ។ ឲ្យតែចូលពីរនាក់អ៊ីចឹងហូបឲ្យហូបពីរនាក់ហ្នឹង កងហ្នឹងពីរនាក់ទៀតអ៊ីចឹងទៅ ដាក់ចូល។

**ស៖** លោកស្រីថា គេគំរាម តើគេមានសកម្មភាពយ៉ាងម៉េចចំពោះដែលយើងកំពុងតែហូបអាហារហ្នឹង?

[១៥:៤៣:១២]

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនច្បាស់ទេ អ៊ីចឹងហើយបានខ្ញុំឡើងជំទាស់។ គឺថាទី១ ខ្ញុំមើលឃើញសំណួរដូចពាក់ព័ន្ធ ប៉ុន្តែម៉្យាងទៀតមើលឃើញសំណួរ<មិនចំនឹងផ្នែកដែលយើងកំពុងដោះស្រាយនៅថ្ងៃនេះទេ ជាពិសេស> មិនបានផ្ដោតទៅលើប្រធានបទនេះឲ្យបានច្បាស់លាស់<ទេ>។ ដូច្នេះ ខ្ញុំសូមការជំទាស់ការតាំងសំណួរបែបនោះ គឺវាក្រៅវគ្គនៃការជំនុំជម្រះនេះហើយ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ តាមរយៈអនុស្សរណៈនោះ យើងដឹងច្បាស់ថា ដើមបណ្ដឹងរដ្ឋប្បវេណីមានសិទ្ធិផ្ដល់សក្ខីកម្មអំពីការឈឺចាប់ដែលពួកគាត់ទទួលរងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ ដូច្នេះ ខ្ញុំសូមឲ្យលោកប្រធានមេត្តាអនុញ្ញាតឲ្យគាត់និយាយអំពីការឈឺចាប់របស់គាត់ ពីព្រោះថាវាមានភាពពាក់ព័ន្ធ <ហើយម្យ៉ាងវិញទៀត>វាសមស្របទៅនឹងអនុស្សរណៈរបស់អង្គជំនុំជម្រះហើយ។

[១៥:៤៥:២០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៤៦:០០]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធនូវសេចក្ដីជំទាស់របស់មេធាវីការពារក្ដី នួន ជា។ សាក្សី -- ដើមបណ្ដឹងរដ្ឋប្បវេណីឆ្លើយតបទៅនឹងសំណួរដែលសួរឡើងដោយមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។

**លោក ឡោ ជុនធី៖**

បាទ សូមអរគុណ ខ្ញុំសូមរំឭកគាត់បន្តិច។

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** សំណួរខ្ញុំអម្បាញ់មិញដែលខ្ញុំសួរហ្នឹងថាតើនៅពេលដែលលោកស្រីហូបបាយហ្នឹង តើអាការៈនៃការគំរាមពីអ្នកដែលថាចង់ឲ្យពិសាសាច់ជ្រូកហ្នឹង តើគេធ្វើយ៉ាងម៉េចបាទ?

**លោកស្រី ឡិប នាង៖**

**ផ៖** ដាក់ជាមួយបបរៗហ្នឹងខ្ញុំហូបបបរ បើខ្ញុំមិនហូបនៅឈរយាមដល់ខ្ញុំហូប ដាក់ជាមួយលាយបបរ ហើយបបរអត់មាននេះទេ បបរទឹកកក្លូកលាយឲ្យខ្ញុំហូប ហើយឈរយាមដល់ខ្ញុំហូបៗអស់ហើយបានដើរចេញ។

[១៥:៤៧:១១]

**ស៖** អ៊ីចឹងមានន័យថានៅក្នុងមួយអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង អ្នកស្រីមានការលំបាកមែនទែនពីបញ្ហាដែលពាក់ព័ន្ធនឹងការមិនហូបសាច់ជ្រូកនេះ?

**ផ៖** ខ្ញុំពូជសាសន៍ខ្ញុំគេអត់ឲ្យហូបអាហ្នឹង ដល់ទៅបង្ខំឲ្យខ្ញុំហូបសាសន៍ខ្ញុំបង្ខំឲ្យខ្ញុំហូប ខ្ញុំអត់ហូប នៅឈរយាមបង្ខំឲ្យខ្ញុំឲ្យហូបទាល់តែបាន។ មិនឲ្យខ្ញុំហូបនៅយាមអ៊ីចឹងស្ពាយកាំភ្លើងនៅក្រោយខ្នងខ្ញុំ នៅយាមឲ្យខ្ញុំហូបដល់បាន មិនហូបអត់ដើរចេញទេ សម្លុតដល់ខ្ញុំឲ្យខ្ញុំហូប។ ហើយខ្ញុំអស់បងអស់ប្អូនហើយ ខ្ញុំខំហូបទៅនឹកឃើញឲ្យបានរស់ទៅ បានជួបមកដល់ជួបមា *(ឮមិនច្បាស់)* នៅផ្ទះឯណោះ ជួបអត់មាន *(ឮមិនច្បាស់)* នោះ អត់មាននៅផ្ទះទៀត។

[១៥:៤៨:០៩]

**ស៖** ខ្ញុំសូមសួរសំណួរចុងក្រោយរបស់ខ្ញុំថាតើរបបអាហារហ្នឹង វាជារបបអាហារយ៉ាងដូចម្ដេចដល់ពេលគេកំហិតអ៊ីចឹងទៀត អ្នកស្រីបានន័យថាការហូបចុកហ្នឹងវាតិចតួចបំផុត ឬមួយយ៉ាងម៉េច?

**ផ៖** តាំងពីបាត់បងបាត់ប្អូនមកអត់ដែលបានហូបឆ្អែតទេ បង្ខំឲ្យខ្ញុំៗតវ៉ាបានបង្ខំឲ្យតវ៉ាឲ្យខ្ញុំតវ៉ាដល់ខ្ញុំអត់តវ៉ា ខ្ញុំនឹកឃើញដល់អត់ធ្មត់ អស់បងអស់ប្អូនហើយខ្ញុំអត់ធ្មត់មិនហ៊ានតវ៉ាឲ្យអីហូប ក៏ខ្ញុំហូបដែរ អត់ហ៊ានតវ៉ា។

**ស៖** សូមមួយសំណួរទៀត ថាតើគេបង្ខំឲ្យធ្វើការហ្នឹងវាពាក់ព័ន្ធនឹងការងារលំបាកអីខ្លះបាទ?

**ផ៖** បង្ខំឲ្យខ្ញុំជីកប្រឡាយ ១០ម៉ែត្របួនជ្រុងឲ្យជីកប្រឡាយឲ្យហើយ១ថ្ងៃ១០នាក់ ជួនណាហើយ ជួនណាអត់ ដីរឹងអត់ហើយ បើដីទន់បានហើយ ១០នាក់ហ្នឹង ដល់ហើយដល់ឡើងដល់ដឹងតែហូបបបរអត់ដែលមានបានបាយខាប់ ដែលបបរខាប់ទេ មានតែបបររាវកក្លូក បបររាវ ជួនណាសម្លត្រួយដំឡូង។

[១៥:៤៩:៤៦]

**លោក ឡោ ជុនធី៖**

បាទ អរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទប្រគល់វេទិកាជូនទៅក្រុមសហព្រះរាជអាជ្ញា តំណាងសហព្រះរាជអាជ្ញាសូមអញ្ជើញ។ សូមអញ្ជើញ!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** សូមជម្រាបសួរលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំចង់សុំឱ្យលោកស្រីបំភ្លឺពីរបីចំណុចទេ។ លោកស្រីឆ្លើយថា លោកស្រីបានរស់នៅក្នុងភូមិត្នោតជុំ ស្រុកត្រាំកក់ នៅក្នុងរបបខ្មែរក្រហម។ អ៊ីចឹងមុនពេលនុ៎ង តើលោកស្រី និងគ្រួសារមកពីណា? មកពីកំពង់សោមមែនទេ?

**លោកស្រី ឡិប នាង៖**

**ឆ៖** ខ្ញុំមកពីកំពត ខេត្តកំពត ស្រុកបឹងតាព្រាម ភូមិបឹងតាព្រាម ស្រុកកំពត ខេត្តកំពត។

[១៥:៥០:៥៨]

**ស៖** សូមអរគុណ។ <ខ្ញុំសួរសំណួរនេះដោយសារតែឃើញ>នៅក្នុងទម្រង់<ស្នើសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី>របស់លោកស្រីហ្នឹង ព័ត៌មានគឺដូចជាផ្ទុយគ្នា។ អ៊ីចឹងហើយបានជាខ្ញុំសួរសុំឱ្យលោកស្រីបំភ្លឺនោះ។ តើមានរឿងអ្វីកើតឡើងចំពោះម្ដាយរបស់លោកស្រី <>ឈ្មោះ គង់ ណៈ ដែលលោកស្រីបានឆ្លើយអម្បាញ់មិញហ្នឹង?<>

**ឆ៖** គង់ ណៈ មកជាមួយគ្នាខ្ញុំ ដល់មកជាមួយគ្នានាងខ្ញុំ ដល់មកគេកាត់មួយកំណាត់មិនទៅណា ខ្ញុំចេះតែទៅមុខអ៊ីចឹងហើយ គាត់នៅក្រោយ មិនដឹងគេកាត់យកទៅណា។ បែកគ្នាកន្លែងហ្នឹង បែកគ្នាក្រោយអាពត ចូលហ្នឹង។

**ស៖** តើគាត់រស់រានមានជីវិតពីរបបខ្មែរក្រហមទេ?

**ឆ៖** អត់មានឃើញគាត់តឡូវតាំងពីនៅពីតឡូវទៅ ដល់តឡូវតាំងពីចេញមកអត់មានជួបគាត់អត់អី អត់មានឃើញដឹងគាត់ទៅណាមកណា អត់ឃើញជួបគាត់សោះ។ ក្នុង៧៩ ចេញមកដល់នេះតឡូវអត់ដែលជួប អត់មានដឹង ថាគាត់មិនសង្ឃឹមថានៅរស់ទេ បើនៅរស់ទៅរកកូនរកចៅហើយ។

**ស៖** នៅក្នុងពេញមួយរបបខ្មែរក្រហម តើលោកស្រីរស់នៅក្នុងស្រុកត្រាំកក់នេះរហូត ឬក៏យ៉ាងណា?

[១៥:៥២:៤១]

**ឆ៖** ខ្ញុំនៅជីកប្រឡាយនៅស្រុកត្រាំកក់ ហើយក្រោយហ្នឹងគេបញ្ជូនខ្ញុំដល់អត់ពីប្អូនទៅ គេបញ្ជូនខ្ញុំទៅ១០៩ ពាក់កណ្ដាលត្រាំកក់ ពាក់កណ្ដាល១០៩ហ្នឹង។

**ស៖** ដើម្បីឱ្យច្បាស់នោះ លោកស្រីពេលដែលនិយាយថា១០៩ហ្នឹង គឺស្រុកគីរីវង់នៅខេត្តតាកែវហ្នឹងមែនទេ?

**ឆ៖** នៅស្រុកត្រាំកក់ដែរ គ្រាន់តែនៅភូមិខុសគ្នា។

**ស៖** នៅពេលដែលលោកស្រីជីកប្រឡាយនោះ តើគេមានដែលដាក់ទណ្ឌកម្មទេ ដោយសារតែលោកស្រីធ្វើការងារមិនចប់តាមការកំណត់នោះ? ហើយបើសិនជាធ្លាប់នោះ តើការដាក់ទណ្ឌកម្ម<អ្វី>ខ្លះ?

**ឆ៖** ជីកហ្នឹង១០ម៉ែត្របួនជ្រុងគ្នា១០នាក់ ជីកទៅជម្រៅទៅ១០ម៉ែត្រចុះទៅក្រោម។

**ស៖** តើលោកស្រីធ្លាប់មិនអាចជីកបានគ្រប់ការកំណត់១០ម៉ែត្រការ៉េហ្នឹងទេ? ហើយបើអត់ចប់ហ្នឹង គេមានធ្វើបាប ឬក៏ដាក់ទណ្ឌកម្មអីទេ?

**ឆ៖** ជីកឱ្យខំឱ្យហើយ ដល់មិនហើយ ដល់យប់បានឱ្យឡើង។

[១៥:៥៤:៥០]

**ស៖** ប្រសិនបើខ្ញុំយល់មិនច្រឡំទេ គឺលោកស្រីបានបាត់បង់ម្ដាយ ហើយនិងបងប្អូន<ប្អូននាក់>ជាបន្តបន្ទាប់នៅពេលដែលលោកស្រីធ្វើការនៅស្រុកត្រាំកក់។ <តើលោកស្រីអាចប្រាប់បានទេ>នៅពេល<>ក្រោយ<>ឆ្នាំ១៩៧៩ នុ៎ងតើលោកស្រីមានអារម្មណ៍បែបណាដែរ ដែលត្រូវរស់នៅឯកោបែបនេះនោះ?

**ឆ៖** នៅហ្នឹង នឹងឃើញនៅតែនឹកឃើញនៅឈឺចាប់ បាត់ម៉ែបាត់ឪបាត់ប្អូនបាត់បង ឈឺចាប់រហូតឱ្យតែនឹកឃើញឈឺចាប់ៗ។

**<លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាឯល>៖**

សូមអរគុណលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។ លោកប្រធានខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្សែបកប្រែ និងខ្សែបកប្រែបន្ត។

អរគុណ ហើយសុំសួរទៅក្រុមមេធាវីការពារក្តី។ លោកវ៉ិចទ័រ កូប៉េ តើត្រូវការចំណាយពេលវេលាប៉ុន្មានទៅក្នុងការសួរដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ?

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំគិតថា ខ្ញុំមានសំណួរពីរបីសំណួរទេ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញបាទ។

[១៥:៥៦:២៣]

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ**

**ស៖** លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី លោកស្រី<ស្គាល់ឈ្មោះ>អ្នកណាដែលបង្ខំលោកស្រីឱ្យហូបសាច់ជ្រូកនោះ<ដែរឬទេ>?

**លោកស្រី ឡិប នាង៖**

**ឆ៖** ខ្ញុំអត់បានស្គាល់ឈ្មោះទេ ឈ្លបមកបង្ខំឱ្យខ្ញុំហូប ហើយមេកងបង្ខំឱ្យខ្ញុំហូប។

**ស៖** លោកស្រីចាំទេ រឿងដែលគេបង្ខំលោកស្រីឱ្យហូបសាច់ជ្រូកហ្នឹងញឹកញាប់ប៉ុន្មានដែរ? ពីរបីដងទេ ឬក៏ច្រើនដង?

**ឆ៖** ឱ្យតែគេកាប់បង្ខំឱ្យហូបៗហើយ។ ឱ្យតែពីរបីថ្ងៃកាប់អ៊ីចឹង បង្ខំឱ្យហូបៗ។

**ស៖** លោកស្រីថារឿងរាល់ពីរបីថ្ងៃគឺថា គេកាប់ជ្រូក តើគេកាប់ជ្រូកហ្នឹងចាប់តាំងពីដើម ចាប់តាំងពី<ខែមេសា>ឆ្នាំ១៩៧៥ រហូតដល់ចប់របបហ្នឹង ឬក៏យ៉ាងណា?

[១៥:៥៨:០៥]

**ឆ៖** ខ្ញុំអត់ដឹងកាប់ឆ្នាំណាប៉ុន្មានទេ ខ្ញុំដឹងថាកាប់ឱ្យតែបីបួនថ្ងៃអត់ម្ហូបកាប់ៗ ដល់បីបួនថ្ងៃអត់ម្ហូបអ៊ីចឹងកាប់ហើយ ស្លម្ហូរព្រលឹតអ៊ីចឹងទៅ ត្រួយដំឡូងអ៊ីចឹងទៅ ជួនកាលបបរបញ្ចូលជាមួយអ៊ីចឹងទៅ អត់ម្ហូបកាប់ឱ្យហូបអ៊ីចឹងទៅ។

**ស៖** បាទ នេះជាសំណួរចុងក្រោយហើយលោកស្រី។ មនុស្សជាច្រើនបានផ្តល់សក្ខីកម្ម គឺថាភាគច្រើន បើមិនទាំងអស់ទេ គឺថាបានពន្យល់ជូនអង្គជំនុំជម្រះថា <>មានតែបបររាវៗ ហើយនិងសម្ល<ត្រកួន> គេឱ្យប្រជាជនហូប។ មិនមានឱ្យអីណាសាច់ជ្រូកអ៊ីចឹង តើលោកស្រីអាចមានយោបល់ថា

ម៉េចដែរទៅនឹងចម្លើយមុនៗហ្នឹង?

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

*(គ្មានការបកប្រែ)*

[១៥:៥៩:០៦]

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណីកុំអាល់ទាន់ឆ្លើយតប។ សូមអញ្ជើញ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន ខ្ញុំដឹងថាឥឡូវល្ងាចហើយ ហើយគាត់ព្យាយាមសួរលឿន <ប៉ុន្តែសម្រាប់ខ្ញុំ គិតថាលោកមេធាវីការពារក្ដីបាននិយាយមិនត្រឹមត្រូវតាមភស្តុតាង>ដែលយើងបានស្ដាប់តាំងពីដើមសវនាការនោះទេ។ <សាក្សី>ខ្លះគាត់និយាយថា មានសាច់ អ្នកខ្លះថាមានត្រី។ ដូច្នេះការសង្ខេបរបស់មេធាវី កូប៉េ នេះគឺមិនឆ្លុះបញ្ចាំងនូវភស្តុតាងដែលយើងបានស្ដាប់តាំងពីពេលដែលចាប់ផ្ដើមសវនាការនេះដំបូងមកទេ លោកប្រធាន។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ខ្ញុំសុំសួរអំពីជំហររបស់ដើមបណ្ដឹងរដ្ឋប្បវេណី។ <លោកប្រធាន>តាមខ្ញុំដឹង សាក្សីជាច្រើនដែលបានផ្ដល់សក្ខីកម្ម គឺថាបានហូបតែបបររាវៗ <>និង<>សម្លត្រកួន<តែប៉ុណ្ណោះ>។ ដូច្នេះខ្ញុំអាចតាំងសំណួរបែបនេះទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ហើយសួរមើលថា តើគាត់មានប្រតិកម្មយ៉ាងដូចម្ដេចដែរ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធនូវសេចក្ដីជំទាស់ ហើយដើមបណ្ដឹងរដ្ឋប្បវេណីឆ្លើយតបនឹងសំណួររបស់មេធាវីការពារក្ដីចុងក្រោយអម្បាញ់មិញនេះ។

[១៦:០០:៤៤]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំនឹងសួរលោកស្រីម្ដងទៀត។ លោកស្រីទើបតែបានឆ្លើយអម្បាញ់មិញថា រៀងរាល់បីបួនថ្ងៃម្ដង គេ<កាប់>ជ្រូក ហើយលោកស្រីត្រូវគេបង្ខំឲ្យហូបសាច់ជ្រូក។ ប៉ុន្តែដើមបណ្ដឹងរដ្ឋ

ប្បវេណី និងសាក្សីដែលបានមកឆ្លើយនៅចំពោះមុខតុលាការ ភាគច្រើនឆ្លើយថាមានតែបបរវាវៗ <> និងសម្លត្រកួន<ហូបតែប៉ុណ្ណោះ>។ អ៊ីចឹង បានខ្ញុំសួរថា តើលោកស្រីមានប្រតិកម្ម ឬយល់ថាម៉េច ចំពោះចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងសាក្សីដទៃទៀត<ពីមុនមកដែរឬទេ>?

**លោកស្រី ឡិប នាង៖**

**ឆ៖** ចាស ខ្ញុំ នាងខ្ញុំហូបបបរជាមួយសាច់ជ្រូក គេឃើញថាពួកខ្ញុំខាងសាសន៍ខ្ញុំគេឲ្យអត់ហូប គេធ្វើខាងហ្នឹងឲ្យហូប គេកាប់អ៊ីចឹងទៅ យកមកបបរឲ្យពួកសាសន៍ខ្ញុំហូបទៅ។ ជួនណាស្លជាមួយត្រកួនអ៊ីចឹងទៅ ជួនណាបបរដាក់ជាមួយសាច់ហ្នឹងឲ្យពួកខ្ញុំហូបទៅ។ ពួកនាងខ្ញុំអត់ហូបអាហ្នឹង បង្ខំឲ្យខ្ញុំ ពួកនាងខ្ញុំហូបអាហ្នឹង។ បបរទឹកកក្លុកដាក់លាយឲ្យពួកនាងខ្ញុំហូប។ ហើយសាសន៍ខ្ញុំអត់ហូបអាហ្នឹង។

[១៦:០២:០៥]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមប្រគល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន បាទ។

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ ក្រុមការពារក្ដីលោក ខៀវ សំផន អត់មានសំណួរទេបាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយសវនាការថ្ងៃនេះ ដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកកំណត់តធ្វើនៅថ្ងៃអង្គារ ទី២១ ខែមេសា ឆ្នាំ២០១៥ ចាប់ផ្ដើមធ្វើពីម៉ោងប្រាំបួនព្រឹក។ សវនាការនៅថ្ងៃអង្គារ ទី២១ ខែមេសា ឆ្នាំ២០១៥ អង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី ចាន់ ធីម។ សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាកំណត់នេះ។

ឯកាលវិភាគដំណើរការសវនាការស្ដាប់បន្តបន្ទាប់សម្រាប់សប្ដាហ៍ពីថ្ងៃទី២១ ដល់ ថ្ងៃទី២៤ ហើយនិងសប្ដាហ៍បន្ទាប់នោះ អង្គជំនុំជម្រះនឹងជម្រាបជូនទៅភាគីបន្ថែមទៀតនៅដើមសប្ដាហ៍ក្រោយ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

តាមរយៈអ៊ីម៉ែលរបស់មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង។ សូមភាគីជ្រាប។

[១៦:០៣:១៦]

អង្គជំនុំជម្រះ សូមអរគុណចំពោះលោកស្រី ឡិប នាង ការថ្លែងរៀបរាប់អំពីទុក្ខសោកវេទនារបស់លោកស្រីដែលបានអះអាងថា លោកស្រីបានទទួលរងនៅក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យបានដល់ទីបញ្ចប់ហើយ។ លោកស្រីអាចវិលត្រឡប់ទៅកាន់ទីលំនៅរបស់លោកស្រី ឬក៏គោលដៅណាដែលលោកស្រីមានបំណងចង់ទៅបានហើយ។ លោកស្រីធ្វើដំណើរត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញជូនលោកស្រី ឡិប នាង វិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណា ដែលគាត់មានបំណងចង់ទៅបានហើយ។ ហើយអង្គជំនុំជម្រះក៏សូមអរគុណចំពោះលោកស្រី ឆាយ ម៉ារីដែន បុគ្គលិកអង្គការ ធី.ភី.អូ ។ ហើយឥឡូវនេះគឺលោកស្រីអាចសម្រាកបានហើយ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនពួកគាត់ត្រឡប់ចូលរួមសវនាការវិញនៅថ្ងៃអង្គារ ទី២១ ខែមេសា ឆ្នាំ២០១៥ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង១៦:០៤ នាទី)*

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*